ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 14-Jan-2014, 13:46
CMS/CFO: Sann Rada

**សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក.–ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៤**

ភាសាដើម ៖ **អង់គ្លេស**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបដិសេធការតែងតាំងសហមេធាវី ដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីដែលត្រូវបានចាត់តាំង**
អាង ឧត្តម
Michael KARNAVAS

**ប្រធានអង្គភាពគាំពារការពារក្តី**
Isaac ENDELEY

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
គឹម ម៉េងឃី
គង់ ផល្លៈ
ម៉ុច សុវណ្ណារី
សំ សុគង់
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Mahdev MOHAN
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

**បានឃើញ** ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ (“ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក”)។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទាក់ទងនឹងសំណុំរឿង ០០៣[១] ដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ [២]។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទិននឹងការចោទប្រកាន់អំពីការរំលោភបំពានលើ**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងត្រូវផ្ដន្ទាទោសតាមមាត្រា ៣, ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងមាត្រា ៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦។

**បានឃើញ** វិធាន ២១, ២២ និង ៧២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”) ។

**បានឃើញ** មាត្រា ៦,៧ និង ៩ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្ដី ស្ដីពីការចាត់តាំងមេធាវី (“បទបញ្ជារដ្ឋបាល អ.គ.ក”)។

**បានឃើញ** សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន (“*សំណើសុំបដិសេធ*”)[៣] ។

[១] សំណុំរឿង០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[២] សំណុំរឿង០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

[៣] សំណុំរឿង០០៣ ឯកសារD56/1 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន* ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២(*សំណើសុំបដិសេធ*)។

**បានឃើញ**ថា នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចៅក្រម យូ ប៊ុនឡេង ("សហចៅក្រមស៊ើបអង្កេតជាតិ") និងចៅក្រម Harmon ("សហចៅក្រមស៊ើបអង្កេតអន្តរជាតិ") បានចុះហត្ថលេខាលើកំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ពាក់ព័ន្ធ ដូចជា ដីកាសម្រេចនេះ។

# មាតិកា

**មាតិកា** .......... **4**

**ក. ប្រវត្តិនីតិវិធី** .......... **7**

**ខ. សង្ខេបអំពីសេចក្តីសន្និដ្ឋាន និងសារណា** .......... **13**

**I. សំណើសុំបដិសេធ និងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា** .......... **13**

*ក. អត្ថិភាពនៃទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធរវាងអៀង សារី ជាមួយជនសង្ស័យ* .......... *14*

*ខ. ការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍* .......... *16*

i. គ្មានលទ្ធភាព និងគ្មានឆន្ទៈស្វែងរកវិធីការពារក្តីណាមួយ៉ាង រួមមាន ការសហការ និងការផ្តល់ទទ្ធីករណ៍សម្រាប់កក្តាស្ថានសម្រាលណាមួយ៉ាង .......... 16

ii. ការលាតត្រដាងព័ត៌មានសម្ងាត់ដែលផ្តល់ឲ្យដោយ អៀង សារី .......... 18

*គ. ទំនាស់ផលប្រយោជន៍ទាំងនេះមិនអាចលះបង់ទេដោយសារប៉ះពាល់ដល់កិច្ចការរដ្ឋបាលតុលាការ* .. *19*

*ឃ. ការលះបង់សិទ្ធិ មានវិការៈ និងមិនអាចផ្សះផ្សារបាន* .......... *21*

**II. សារណា និងសារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង** .......... **21**

*ក. គ្មានទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានចោទ* .......... *22*

*ខ. គ្មានទំនាស់ផលប្រយោជន៍* .......... *24*

*គ. លទ្ធភាព និងឆន្ទៈស្វែងរកវិធីការពារក្តីណាមួយ៉ាង រួមទាំងការសហការ និងកក្តាស្ថានសម្រាលណាមួយ៉ាង* .......... *24*

*ឃ. ការប្រើប្រាស់ព័ត៌មានសម្ងាត់* .......... *25*

*ង. នឹងគ្មានការប៉ះពាល់ដល់កិច្ចការរដ្ឋបាលតុលាការ* .......... *26*

*ច. សុពលភាពនៃការលះបង់សិទ្ធិ* .......... *27*

**III. ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ** .......... **29**

**IV.សំណើបន្ទាន់ ........ 30**

**V. ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់ ........ 32**

**VI. ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំងទៅនឹងការឆ្លើយតបទៅនឹងសំណើបន្ទាន់ ........ 34**

**គ. ច្បាប់ជាធរមាន ........ 35**

**I. បទប្បញ្ញត្តិក្របខ័ណ្ឌកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ........ 35**

**II. បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង អ.វ.ត.ក ស្តីពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាន មេធាវីតាមជម្រើសរបស់ខ្លួន ........ 36**

**III. បទបញ្ជារដ្ឋបាលជាប់ពាក់ព័ន្ធរបស់អង្គភាពគាំពារការពារក្តី ស្តីពីការតែងតាំងមេធាវី ........ 36**

**IV.បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធានផ្ទៃក្នុងស្តីពីការទទួលខុសត្រូវវិជ្ជាជីវៈរបស់មេធាវី នៅចំពោះមុខអ.វ.ត.ក ........ 37**

**V. បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី និងបទប្បញ្ញត្តិកម្ពុជាស្តីពីទំនាស់ផលប្រយោជន៍ ........ 37**

**ឃ. បញ្ហាបឋម ........ 38**

*ក.យុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការសម្រេចលើសំណើសុំបដិសេធ និងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា ........ 38*

*ខ.សំណើសុំអនុញ្ញាតបន្ថែមចំនួនពាក្យ និងដាក់ឯកសារជាភាសាអង់គ្លេសមុន ហើយដាក់ភាសាខ្មែរនៅតាមក្រោយ ........ 41*

**ង. ការចោទប្រកាន់អំពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ........ 43**

**I. ការត្រួតពិនិត្យលើការចោទប្រកាន់អំពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍ ........ 43**

*ក. និយមន័យអំពីទំនាស់ផលប្រយោជន៍ ........ 43*

*ខ. ករណីយកិច្ចរក្សាការសម្ងាត់ និងភាពស្មោះត្រង់របស់មេធាវី ........ 45*

*គ. បទដ្ឋានជាធរមានសម្រាប់ត្រួតពិនិត្យលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍ ........ 47*

00968676



**II. ការចោទប្រកាន់អំពីអត្ថិភាពនៃទំនាក់ទំនងអង្គហេតុរវាង ការចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ និងដីកាចោទប្រកាន់ប្រឆាំងនឹងអៀង សារី ........ 49**

*ក. តួនាទីរបស់ជនសង្ស័យ និងអៀង សារី ជាប់ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ...... 49*

*ខ. ភាពត្រួតស៊ីគ្នារវាងរឿងក្តីប្រឆាំងនឹងជនសង្ស័យ និងអៀង សារី ........ 50*

i. ភាពត្រួតស៊ីគ្នានៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទ ........ 50

ii. ភាពត្រួតស៊ីគ្នានៅក្នុងការចោទប្រកាន់អំពីទម្រង់នៃទទួលខុសត្រូវ៖ សហឧក្រិដ្ឋកម្មរួម ........ 51

iii. ភស្តុតាងជាក់ស្តែងអំពីការជាប់ពាក់ព័ន្ធរួមនៅក្នុងការចោទប្រកាន់ត្រួតស៊ីគ្នាមួយចំនួន ........ 51

iv. ភស្តុតាងអំពីទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមរវាងជនសង្ស័យ ជាមួយអៀង សារី ........ 55

v.សេចក្តីសន្និដ្ឋានលើអត្ថិភាពនៃទំនាក់ទំនងអង្គហេតុ និងទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមជាក់ស្តែង រវាងអៀង សារី ជាមួយជនសង្ស័យ ........ 56

**III. អាច** ឬមិនអាចព្យាករណ៍ជាមុនដោយសមហេតុផលថា ទំនាក់ទំនងអង្គហេតុ និងទំនាក់ទំនង ថ្នាក់លើ-ថ្នាក់ក្រោមជាក់ស្តែង នឹងនាំឲ្យមានទំនាស់ផលប្រយោជន៍ ........ **57**

ក.លទ្ធភាពរបស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការស្វែងរកវិធីស៊ើបអង្កេតនិងយុទ្ធសាស្ត្រការពារក្តីទាំងអស់ដែលអាចមាន ........ *59*

ខ. ការសហការជាមួយ អ.វ.ត.ក ........ *61*

គ. ករណីកិច្ចរបស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការរក្សាការសម្ងាត់ឲ្យ អៀង សារី ........ *64*

ឃ.សេចក្តីសន្និដ្ឋានលើអត្ថិភាពនៃទំនាស់ផលប្រយោជន៍ ........ *65*

**IV. ទំនាស់ផលប្រយោជន៍ អាចលះបង់បាន ឬអត់ ........ 66**

**V. សុពលភាពនៃការលះបង់សិទ្ធិដែលធ្វើដោយសហមេធាវីដែលត្រូវបានចាត់តាំង ........ 69**

**ច. សេចក្តីសន្និដ្ឋាន ........ 70**

## ក. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ ប្រធានអង្គភាពគាំពារការពារក្តី បានជូនដំណឹង សហចៅក្រមស៊ើបអង្កេតថា គាត់បានចាត់តាំងលោក អាង ឧត្តម និងលោក Michael Karnavas ("សហមេធាវីដែលត្រូវបានចាត់តាំង") តំណាង មាស មុត ("ជនសង្ស័យ") ដែលជាជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៣ [4]។ គាត់ក៏បានជូនដំណឹង សហចៅក្រមស៊ើបអង្កេត ថា គាត់បានជួបជនសង្ស័យ ដើម្បីបញ្ជាក់ជនសង្ស័យអំពីការជ្រើសរើសមេធាវី ហើយគាត់បានទទួលការលះបង់សិទ្ធិពីជនសង្ស័យ និងអៀង សារី(នៅពេលនោះ អៀង សារី គឺជាជនជាប់ចោទម្នាក់នៅក្នុងសំណុំរឿង០០២)ដោយការលះបង់សិទ្ធិទាំងនោះទាក់ទងនឹងទំនាស់ផលប្រយោជន៍ណាដែលកើតចេញពីសហមេធាវីដែលត្រូវបានចាត់តាំងតំណាងបុគ្គលទាំងពីរនាក់ក្នុងពេលដំណាលគ្នា[5]។

២. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់*សំណើសុំឱ្យបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន "សំណើសុំបដិសេធ"* [6]។ នៅក្នុង *សំណើសុំបដិសេធ* សហព្រះរាជអាជ្ញាអន្តរជាតិបានចោទថា សហមេធាវីដែលត្រូវបានចាត់តាំង តំណាងឱ្យអៀង សារី និងជនសង្ស័យក្នុងពេលដំណាលគ្នា នឹងបង្កឱ្យមាន "*ទំនាស់ផលប្រយោជន៍ជាច្រើន ធ្ងន់ធ្ងរ និងមិនអាចផ្សះផ្សាបាន ដែលនឹងប៉ះពាល់ជាអចិន្ត្រៃយ៍ដល់កិច្ចការរដ្ឋបាលនៅចំពោះមុខ អ.វ.ត.ក*"[7]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើ ការិយាល័យសហចៅក្រមស៊ើបអង្កេត សុំបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង[8]។

---

[4] សំណុំរឿង០០៣ ឯកសារ D56 *ការចាត់តាំងមេធាវីឱ្យធ្វើជាតំណាងលោកមាស មុត ដែលជាជនសង្ស័យនៅក្នុងសំណុំរឿង ០០៣* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ១១។

[5] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៣-៤។

[6] សំណុំរឿង០០៣ ឯកសារD56/1 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន* ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២(*សំណើសុំបដិសេធ*)។

[7] *សំណើសុំបដិសេធ* កថាខណ្ឌ ១។

[8] *ដូចដើងទំព័រខាងលើ*។

៣. នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ប្រធានអង្គភាពគាំពារការពារក្តី បានដាក់ *សំណើសុំបញ្ជាក់* ដោយស្នើសុំការទទួលស្គាល់ ឬឆ្លើយថាទទួលស្គាល់ ឬក៏បដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំងឱ្យតំណាងជនសង្ស័យ[9] ។

៤. នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចបង្គាប់សហមេធាវីដែលត្រូវបានចាត់តាំង ឱ្យផ្អាកការប្រាស្រ័យទាក់ទងជាមួយនឹងជនសង្ស័យ រហូតដល់ពេលចេញដីកាសម្រេចបញ្ជាក់ទៅជនសង្ស័យអំពីការតែងតាំងមេធាវី និងឱ្យបង្ហាញជូនសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញានូវការលះបង់សិទ្ធិដែលទទួលបានពីអៀង សារី និងជនសង្ស័យ[10]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានអញ្ជើញ សហមេធាវីដែលត្រូវបានចាត់តាំងឱ្យដាក់សារណាស្តីពីលទ្ធភាពទំនាស់ផលប្រយោជន៍ ហើយអញ្ជើញ សហព្រះរាជអាជ្ញា ដាក់ការឆ្លើយតប[11]។

៥. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដោយឃើញថា សហមេធាវីដែលត្រូវបានចាត់តាំង មិនទាន់អាចអនុវត្តបានតាមដីកាសម្រេចខាងលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពន្យារពេលកាលបរិច្ឆេទកំណត់ឱ្យសហមេធាវីដែលត្រូវបានចាត់តាំង បង្ហាញការលះបង់សិទ្ធិ និងដាក់សារណា[12]។

៦. នៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ សហមេធាវីដែលត្រូវបានចាត់តាំង បានដាក់ *សារណារបស់សហមេធាវីស្តីពីលទ្ធភាពទំនាស់ផលប្រយោជន៍នៅក្នុងការតំណាងលោក មាស មុត នៅក្នុងសំណុំរឿង ០០៣ ("សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង")* [13]។ សហមេធាវីដែលត្រូវបានចាត់តាំងបានអះអាងថា គ្មានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបានកើតឡើងដោយសារតំណាងឱ្យ

---

[9] សំណុំរឿង០០៣ ឯកសារ D56/56 *សំណើសុំបញ្ជាក់* ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[10] សំណុំរឿង០០៣ ឯកសារ D56/3 *ដីកាសម្រេច និងដីកាកំណត់កាលបរិច្ឆេទទាក់ទងនឹងសំណើសុំតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង* ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ (*"ដីកាសម្រេច"*) កថាខណ្ឌ ២៥-២៦។

[11] *ដូចដើងទំព័រខាងលើ*។

[12] សំណុំរឿង០០៣ ឯកសារ D56/4 *ដីកាកំណត់កាលបរិច្ឆេទឡើងវិញទាក់ទងនឹងសំណើសុំតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង* ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[13] សំណុំរឿង០០៣ ឯកសារ D56/4/1 *សំណើសុំបន្ថែមចំនួនទំព័រ និងសារណារបស់សហមេធាវី ស្តីពីលទ្ធភាពទំនាស់ផលប្រយោជន៍នៅក្នុងការតំណាងលោកមាស មុត នៅក្នុងសំណុំរឿង ០០៣* ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣(*"សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង"*)។

អៀង សារី និង ជនសង្ស័យ ក្នុងពេលដំណាលគ្នាឡើយ ហើយកូនក្តីទាំងពីរនាក់ បានផ្តល់ការយល់ព្រមជាលាយលក្ខណ៍អក្សរទៅលើការតំណាងពេលដំណាលគ្នានេះ[14] ។ ដោយសារមូលហេតុទាំងនេះហើយទើប សហមេធាវីដែលត្រូវបានចាត់តាំង ស្នើថា *សំណើសុំបដិសេធ* ត្រូវច្រានចោល[15]។

៧. នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ២០១៣ អៀង សារី បានទទួលមរណភាព។ នៅថ្ងៃដដែលនោះ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចបង្គាប់ឲ្យបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់[16]។

៨. នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ *សំណើសុំកំណត់កាលបរិច្ឆេទជាថ្មីសម្រាប់ការដាក់សេចក្តីសន្និដ្ឋាន* ពីព្រោះថា កាលៈទេសៈបានប្រែប្រួលដោយសារមរណភាពរបស់ អៀង សារី [17]។

៩. នៅថ្ងៃដដែលនោះ សហមេធាវីដែលត្រូវបានចាត់តាំង បានដាក់*ការជូនដំណឹងអំពីការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី នៅក្នុងសំណុំរឿង ០០២* ដោយបានបញ្ជាក់ថា មរណភាពរបស់អៀង សារី ធ្វើឲ្យ *សំណើសុំបដិសេធ* អស់សុពលភាព ហើយបានស្នើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សុំលុបចោលដីកាសម្រេចដែលហាមឃាត់មិនឲ្យប្រាស្រ័យទាក់ទងជាមួយជនសង្ស័យ[18]។

---

[14] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* ទំព័រ ១។

[15] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤៥។

[16] សំណុំរឿង ០០៣ ឯកសារ D56/4/2.1.1 *សេចក្តីសម្រេចលើការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង សារី* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៣។

[17] សំណុំរឿង ០០៣ ឯកសារ D56/4/3 *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំកំណត់កាលបរិច្ឆេទជាថ្មីសម្រាប់ការដាក់សេចក្តីសន្និដ្ឋាន* ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣។

[18] សំណុំរឿង ០០៣ ឯកសារ D56/4/2 *ការជូនដំណឹងអំពីការបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងលោក អៀង សារី នៅក្នុងសំណុំរឿង ០០២* ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៣។

១០. នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបដិសេធសំណើពីសហមេធាវីដែលត្រូវបានចាត់តាំង ដោយបានបញ្ជាក់រក្សាការហាមឃាត់មិនឱ្យប្រាស្រ័យទាក់ទងជាមួយជនសង្ស័យ ហើយបានកំណត់កាលបរិច្ឆេទថ្មីសម្រាប់ការដាក់ឯកសារពីភាគីផ្សេងៗ[19]។

១១. នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញា បានដាក់ *សេចក្តីសន្និដ្ឋានបន្ថែមស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានចាត់តាំង ("សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ")* ដោយក្នុងនោះ សហព្រះរាជអាជ្ញា បានលើកឡើងជាថ្មីអំពីសំណើសុំបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយផ្អែកលើមូលដ្ឋានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ឬក៏ដោយសារការលះបង់សិទ្ធិគ្មានប្រសិទ្ធភាព[20] ។

១២. នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០១៣ សហមេធាវីដែលត្រូវបានចាត់តាំង បានដាក់*សារណាឆ្លើយតបរបស់សហមេធាវីទៅនឹងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានចាត់តាំង* ("*សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង*")[21] ។

១៣. នៅថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានលុបចោលផ្នែកខ្លះនៃការហាមឃាត់មិនឱ្យប្រាស្រ័យទាក់ទងជាមួយជនសង្ស័យ ហើយបានអនុញ្ញាតឱ្យសហមេធាវីដែលត្រូវបានចាត់តាំង ប្រាស្រ័យទាក់ទងជាមួយជនសង្ស័យ ទាក់ទងនឹងការអះអាងរបស់ជនសង្ស័យថាខ្លួនគឺជាជនក្រីក្រ និងសំណើសុំអត្ថប្រយោជន៍ពីគម្រោងជំនួយផ្នែកច្បាប់របស់ អ.វ.ត.ក[22]។ សហ

---

[19]សំណុំរឿង ០០៣ ឯកសារ D56/5 *ដីកាសម្រេច និងដីកាកំណត់កាលបរិច្ឆេទឡើងវិញលើកទីពីរទាក់ទងនឹងសំណើសុំតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង* ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៣("*ដីកាកំណត់កាលបរិច្ឆេទលើកទីពីរ*")។

[20]សំណុំរឿង ០០៣ ឯកសារ D56/7 *សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានចាត់តាំង* ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៣ ( *"សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ")* កថាខណ្ឌ ៨៤។

[21]សំណុំរឿង ០០៣ ឯកសារ D56/9 *សំណើសុំបន្ថែមចំនួនទំព័រ និងសារណាឆ្លើយតបរបស់សហមេធាវីទៅនឹងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានចាត់តាំង* ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ ("*សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង*")។

[22]សំណុំរឿង ០០៣ ឯកសារ D56/12 *ដីកាសម្រេចលើការប្រាស្រ័យទាក់ទងរវាងសហមេធាវីដែលត្រូវបានចាត់តាំង ជាមួយជនសង្ស័យ* ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ១៥-១៦។

ចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្អាកគម្រោងកាលបរិច្ឆេទសម្រាប់ការដាក់ឯកសារដូចបានកំណត់នៅក្នុងដីកាសម្រេច ដោយរង់ចាំការសម្រេចលើបញ្ហាភាពក្រីក្រនេះ[23]។

១៤. នៅថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣ នៅពេលដែល អង្គភាពគាំពារការពារក្តី បានសម្រេចកំណត់លើឋានៈរបស់ជនសង្ស័យថាជាអ្នកក្រីក្រ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានលុបចោលការផ្អាកកាលបរិច្ឆេទសម្រាប់ការដាក់ឯកសារស្តីពីលទ្ធភាពទំនាស់ផលប្រយោជន៍ ហើយបានអញ្ជើញ សហព្រះរាជអាជ្ញា ដាក់ការឆ្លើយតបទៅនឹង*សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង*[24]។

១៥. នៅថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ បានដាក់*ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានចាត់តាំង (“ការឆ្លើយតប”)* [25]។

១៦. នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហមេធាវីដែលត្រូវបានចាត់តាំង បានដាក់*សំណើបន្ទាន់របស់មាស មុត ស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត សុំពិចារណាឡើងវិញថាតើខ្លួនមាន ឬក៏មិនមានយុត្តាធិការសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍*(“*សំណើបន្ទាន់*”) ដោយក្នុងសំណើនេះ សហមេធាវីដែលត្រូវបានតែងតាំង បានបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត មិនមានយុត្តាធិការលើបញ្ហាទំនាស់ផលប្រយោជន៍ទេ[26] ។

---

[23] *ដូចជើងទំព័រខាងលើ*។

[24] សំណុំរឿង ០០៣ ឯកសារ 003-D56/14 *ដីកាសម្រេចបន្តឡើងវិញនូវកាលបរិច្ឆេទសម្រាប់ការដាក់ឯកសារស្តីពីបញ្ហាចោទប្រកាន់អំពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍នៅក្នុងការតំណាងផ្លូវច្បាប់របស់មាស មុត* ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣ កថាខណ្ឌ ៩-១០។

[25] សំណុំរឿង ០០៣ ឯកសារ D56/15 *ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានចាត់តាំង* ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៣ *(“ការឆ្លើយតប”)*។

[26] សំណុំរឿង ០០៣ ឯកសារ D56/17 *សំណើបន្ទាន់របស់ មាស មុត ស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត សុំពិចារណាឡើងវិញថាតើខ្លួនមាន ឬក៏មិនមានយុត្តាធិការសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍* ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៣ (“*សំណើបន្ទាន់*”)។

១៧. នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា *សំណើបន្ទាន់* ត្រូវបានទទួលយកជាសារណាបន្ថែមស្តីពីបញ្ហាចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍ ហើយបាន អនុញ្ញាតឲ្យ សហព្រះរាជអាជ្ញា នូវពេលចំនួនប្រាំងថ្ងៃ ដើម្បីឆ្លើយតប[27] ។

១៨. នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ *ការឆ្លើយតបទាក់ទងនឹងសំណើបន្ទាន់របស់ មាស មុត ស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត សុំពិចារណាឡើងវិញថាតើខ្លួនមាន ឬក៏មិនមានយុត្តាធិការសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍* (“*ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់*”)[28] ។

១៩. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៣ សហមេធាវីដែលត្រូវបានចាត់តាំង បានដាក់ *សំណើរបស់មាស មុត សុំអនុញ្ញាតឆ្លើយតបទៅនឹង ចម្លើយតបទាក់ទងនឹងសំណើបន្ទាន់របស់ មាស មុត ស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត សុំពិចារណាឡើងវិញថាតើខ្លួនមាន ឬក៏មិនមានយុត្តាធិការសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍* (“*ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង*”)[29]។

២០. នៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុញ្ញាតឲ្យសហមេធាវីដែលត្រូវបានចាត់តាំង ឆ្លើយតបទៅនឹង*ចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់*[30]។

---

[27]សំណុំរឿង ០០៣ ឯកសារ D56/16 *ដីកាសម្រេចលើសំណើបន្ទាន់របស់មាស មុត ស្តីពីយុត្តាធិការរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចលើទំនាស់ផលប្រយោជន៍* ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

[28]សំណុំរឿង ០០៣ ឯកសារ D56/16/1 *ការឆ្លើយតបទាក់ទងនឹងសំណើបន្ទាន់របស់ មាស មុត ស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត សុំពិចារណាឡើងវិញថាតើខ្លួនមាន ឬក៏មិនមានយុត្តាធិការសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍* ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១៣ (“*ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់*”)។

[29]សំណុំរឿង ០០៣ ឯកសារ D56/16/2 *សំណើរបស់មាស មុត សុំអនុញ្ញាតឆ្លើយតបទៅនឹងការឆ្លើយតបទាក់ទងនឹងសំណើបន្ទាន់របស់ មាស មុត ស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត សុំពិចារណាឡើងវិញថាតើខ្លួនមាន ឬក៏មិនមានយុត្តាធិការសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៣។

[30]សំណុំរឿង ០០៣ ឯកសារ D56/16/3 *ដីកាសម្រេចលើសំណើរបស់មាស មុត សុំអនុញ្ញាតឆ្លើយតបលើបញ្ហាយុត្តាធិការ* ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៣ ទំព័រ ៣។

២១. នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣ សហមេធាវីដែលត្រូវបានចាត់តាំង បានដាក់*ការឆ្លើយតបរបស់មាស មុត ទៅនឹងការឆ្លើយតបទាក់ទងនឹងសំណើបន្ទាន់របស់ មាស មុត ស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត សុំពិចារណាឡើងវិញថាតើខ្លួនមាន ឬក៏មិនមានយុត្តាធិការសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍* ("*ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង*")[31]។

## ខ. សង្ខេបអំពីសេចក្តីសន្និដ្ឋាន និងសារណា

២២. *សំណើសុំបដិសេធ*របស់សហព្រះរាជអាជ្ញាអន្តរជាតិ និង *សារណា*របស់សហមេធាវីដែលត្រូវបានចាត់តាំង ត្រូវបានដាក់មុនពេលមរណភាពរបស់ អៀង សារី។ នៅពេលដែលអៀង សារី ស្លាប់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាបង្គាប់ឱ្យភាគីទាំងពីរ ដាក់សេចក្តីសន្និដ្ឋាន និងសារណាបន្ថែមស្តីពីផលប៉ះពាល់ដោយសារការផ្លាស់ប្តូរកាលៈទេសៈអង្គហេតុទាំងនេះមកលើបញ្ហាផ្សេងៗដែលបានលើកឡើងនៅក្នុង *សំណើសុំបដិសេធ*[32] ។ បន្ទាប់ពីមានការដាក់សេចក្តីសន្និដ្ឋាន និងសារណាលើកទីពីរមក ទទ្បីករណ៍ដែលនៅប្រើប្រាស់បានក្រោយពីមរភាពរបស់ អៀង សារី ត្រូវបានសង្ខេបដូចខាងក្រោម៖.

### I. សំណើសុំបដិសេធ និងសេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា

២៣. សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើ សហចៅក្រមស៊ើបអង្កេត សុំបដិសេធការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ដោយសារមូលហេតុដូចខាងក្រោម៖ ទីមួយ មានទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធរវាងឧក្រិដ្ឋកម្មដែលអៀង សារី និងជនសង្ស័យ ត្រូវបានចោទថាបានទទួលខុសត្រូវ[33] ។ ទីពីរ អាចព្យាករណ៍ដោយសមហេតុផលថា ទំនាក់ទំនងអង្គហេតុនេះនឹងបង្កើតឱ្យមានទំនាស់ផលប្រយោជន៍

---

[31] សំណុំរឿង ០០៣ ឯកសារ D56/16/4 *ការឆ្លើយតបរបស់មាស មុត ទៅនឹងការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណើបន្ទាន់របស់ មាស មុត ស្នើការិយាល័យសហចៅក្រមស៊ើបអង្កេត សុំពិចារណាឡើងវិញថាតើខ្លួនមាន ឬក៏មិនមានយុត្តាធិការសម្រេចលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍* ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៣។

[32] *ដីកាកំណត់កាលបរិច្ឆេទលើកទីពីរ* ទំព័រ ៦-៧។

[33] *សំណើសុំបដិសេធ* កថាខណ្ឌ ៣៥-៤១។ *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៤៩-៥៣។

ជាច្រើនដែលមិនអាចផ្សះផ្សាបាន ប្រសិនបើសហមេធាវីដែលត្រូវបានចាត់តាំង នៅបន្តតំណាងឱ្យជនសង្ស័យ ព្រោះថាករណីយកិច្ច និងទំនាក់ទំនងរបស់សហមេធាវីដែលត្រូវបានចាត់តាំងជាមួយ អៀង សារី ដែលបានស្លាប់ហើយនោះ នៅតែមានជាធរមាន[34]។ ទីបី ទំនាស់ផលប្រយោជន៍ទាំងនេះមានសក្ដានុពលអាចប៉ះពាល់ជាអចិន្ត្រៃយ៍ដល់កិច្ចការរដ្ឋបាលតុលាការ [35] ។ ទីបួន ទំនាស់ផលប្រយោជន៍ទាំងនេះ មិនបានផ្សះផ្សា ហើយក៏មិនអាចផ្សះផ្សាបានតាមរយៈការលះបង់សិទ្ធិដែលកូនក្ដីទាំងពីរបានចុះហត្ថលេខាដែរ ពីព្រោះថា អ្នកទាំងពីរមិនមានលក្ខណៈល្អឡើយខាងអង្គសេចក្ដី និងនីតិវិធី ហើយមិនអាចផ្សះផ្សាបានឡើយបន្ទាប់ពីមរណភាពរបស់ អៀង សារី [36] ។

ក. អត្ថិភាពនៃទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធរវាងអៀង សារី ជាមួយជនសង្ស័យ

២៤. សហព្រះរាជអាជ្ញាអន្តរជាតិ ផ្ដល់ទឡ្ហីករណ៍ថា ការចោទប្រកាន់អំពី“ទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធ”មានអត្ថិភាពលើបីចំណុច[37] ។ ទីមួយ ទាំង អៀង សារី និងជនសង្ស័យ ត្រូវបានចោទថាមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើ ឬអំពើអកម្មព្រហ្មទណ្ឌដូចគ្នាទាក់ទងនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំ ការចាប់ខ្លួន និងការបោសសម្អាតកម្មាភិបាលកងពលលេខ ១៦៤ និងជនបរទេសនៅ ស-២១ ព្រមទាំងការវាយប្រហារយោធាលើដែនដីវៀតណាម [38] ។ ទីពីរ ទាំង អៀង សារី និងជនសង្ស័យ ត្រូវបានចោទថាបានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដូចគ្នា [39] ។ ទីបី អៀង សារី និងជនសង្ស័យ ស្ថិតនៅក្នុងទំនាក់ទំនងមុខងារ និងឋានានុក្រមយ៉ាងជិតស្និទ្ធ ព្រោះថា ជនសង្ស័យ

[34] *សំណើសុំបដិសេធ* កថាខណ្ឌ ៤២-៥០។ *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៥៧-៥៩។

[35] *សំណើសុំបដិសេធ* កថាខណ្ឌ ៥២-៥៣។ *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧០-៧៧។

[36] *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧៨-៨៣។ *សូមមើលផងដែរ សំណើសុំបដិសេធ* កថាខណ្ឌ ៥១។

[37] *សំណើសុំបដិសេធ* ផ្នែក VI កថាខណ្ឌ ៣៥-៤១។ *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៤៩-៥៣ និង ៥៧-៦២។

[38] *សំណើសុំបដិសេធ* កថាខណ្ឌ ៣៥-៣៧។ *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៤៩-៥០។ ទាក់ទងនឹងការចាប់ខ្លួនទាំងនោះ សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ថា សមាជិកចំនួន ៣៩៦នាក់នៃកងពលលេខ ១៦៤ ដែលស្ថិតនៅក្រោមការបញ្ជារបស់ជនសង្ស័យ ត្រូវបានឃុំឃាំងនៅ ស-២១។ *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៤៩ *ដោយដកស្រង់*សំណុំរឿង ០០២ ឯកសារ D427 *ដីកាដំណោះស្រាយ* ត្រង់កថាខណ្ឌ ៤២៤។

[39] *សំណើសុំបដិសេធ* កថាខណ្ឌ ៣៨។ *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៤៩ និង៥១។

ក្នុងនាមជាលេខាកងពលលេខ ១៦៤ [40] រាយការណ៍ទៅ អៀង សារី ដោយផ្ទាល់ និងដោយប្រយោល តាមរយៈ សុន សេន[41] ។ ក្នុងការគាំទ្រការអះអាងនេះ សហព្រះរាជអាជ្ញាអន្តរជាតិពឹងផ្អែកលើ ទូរលេខយោធាផ្សេងៗ និងសារទូរសព្ទសម្ងាត់មួយ[42]។

២៥. ដើម្បីបង្ហាញភស្តុតាងបន្ថែមទៀតអំពីទំនាក់ទំនងតាមឋានានុក្រមរវាងអៀង សារី និងជនសង្ស័យ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងពីបទសម្ភាសន៍មួយជាមួយជនសង្ស័យ ដោយក្នុងនេះបទ សម្ភាសន៍នេះ ជនសង្ស័យបានបញ្ជាក់ថា៖

> *"ប្រសិនបើអ្នកចង់ដឹងរឿងរ៉ាវគ្រប់យ៉ាងនៅក្នុងសម័យនោះ សូមទៅសួរ អៀង សារី ទៅ។ កុំសួរខ្ញុំ ឬមន្ត្រីមានឋានៈទាបៗផ្សេងទៀត។ អៀង សារី គឺជាអ្នកដឹកនាំ។ សម្រាប់ខ្ញុំ ខ្ញុំគ្មានបញ្ហាជាមួយនឹងតុលាការឡើយ។ ខ្ញុំនឹងនិយាយរឿងរ៉ាវសព្វយ៉ាង៖ អ្វីដែលខ្ញុំបានដឹង និងបានធ្វើ។ មន្ត្រីមានឋានៈទាបត្រូវតែគោរពបញ្ជា"*[43]។

ចុងក្រោយបំផុត សហព្រះរាជអាជ្ញាអន្តរជាតិ រំឭកថា នៅក្នុង*ដីកាសម្រេច និងដីកាកំណត់កាលបរិច្ឆេទទាក់ទងនឹងសំណើសុំការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង ("ដីកាសម្រេចថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣")* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកត់សម្គាល់លើការជាប់ពាក់ព័ន្ធរបស់ អៀង សារី នៅក្នុងការចរចាដោះលែងអ្នកនេសាទថៃដែលចាប់បានដោយមន្ត្រីកងពលលេខ ១៦៤ ដែលស្ថិតនៅក្រោមការបញ្ជារបស់ជនសង្ស័យ[44] ។

---

[40] *សំណើសុំបដិសេធ* កថាខណ្ឌ ៣៥ ដោយដកស្រង់សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីររបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ត្រង់កថាខណ្ឌ ៤៣ និង ៥២។

[41] *សំណើសុំបដិសេធ* កថាខណ្ឌ ៣៩-៤០។ *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៥០, ៥២, និង៦០។

[42] *សំណើសុំបដិសេធ* កថាខណ្ឌ ៤០។ *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៥២។

[43] *សំណើសុំបដិសេធ* ជើងទំព័រ ៧៧។ *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៤១ និង*ការឆ្លើយតប* កថាខណ្ឌ ៣១។

[44] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៥៣ *ដោយដកស្រង់*សំណុំរឿង ០០៣ ឯកសារ D56/3 *ដីកាសម្រេច និងដីកាកំណត់កាលបរិច្ឆេទទាក់ទងនឹងសំណើសុំតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង* ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ ២២។ នៅក្នុងដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកលើឯកសារដូចខាងក្រោម៖ សំណុំរឿង ០០២ ឯកសារ E3/1751 សារព័ត៌មាន ចំណងជើង "ទស្សនកិច្ចរបស់រដ្ឋមន្ត្រីក្រសួងការបរទេសថៃមកកម្ពុជា" សំណុំរឿង ០០២ ឯកសារD108/28.222 សារព័ត៌មាន ចំណងជើង "កម្ពុជា យល់ព្រមដោះលែងអ្នកនេសាទថៃ" សំណុំរឿង ០០២ ឯកសារ E3/928 (ឯកសារ D1.3.30.25 នៅក្នុងសំណុំរឿង ០០៣) និងសំណុំរឿង ០០២ ឯកសារ E3/1752 ។

ខ. ការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍

២៦. សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ថា ទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធនេះ បង្ហាញថា ប្រយោជន៍ផ្នែកច្បាប់របស់ជនសង្ស័យក្នុងការលើកឡើងពីវិធីការពារក្តីសំខាន់ៗរបស់ខ្លួន គឺផ្ទុយគ្នាជាសត្យានុម័តទៅនឹងប្រយោជន៍ដែលត្រូវបានលើកឡើងសម្រាប់ អៀង សារី នៅក្នុងកិច្ចដំណើរការនីតិវិធីដែលមានទំនាក់ទំនងគ្នាទាំងស្រុង[45]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ ផ្តល់ទឡ្ហីករណ៍ថា មិនត្រឹមតែអាចព្យាករណ៍បានទេ ប៉ុន្តែស្ទើរតែច្បាស់ថា ទំនាស់ផលប្រយោជន៍ជាច្រើននឹងលេចចេញនៅពេលដែលការស៊ើបអង្កេតដំណើរការទៅមុខ[46] ។ ជាពិសេស សហមេធាវីដែលត្រូវបានចាត់តាំង នឹងប្រឈមមុខបញ្ហាលំបាកទាក់ទងនឹងលទ្ធភាព និងឆន្ទៈស្វែងរកវិធីការពារក្តីណាមួយ៉ាង និងបង្ហាញកត្តាស្ថានសម្រាលណាមួយ៉ាង ព្រមទាំងបញ្ហាលំបាកទាក់ទងនឹងករណីយរបស់ខ្លួនក្នុងការលាតត្រដាងព័ត៌មានឯកសិទ្ធិ [47]។

*i. គ្មានលទ្ធភាព និងគ្មានឆន្ទៈស្វែងរកវិធីការពារក្តីណាមួយ៉ាង រួមមាន ការសហការ និងការផ្តល់ទឡ្ហីករណ៍សម្រាប់កត្តាស្ថានសម្រាលណាមួយ៉ាង*

២៧. សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ថា ករណីយរបស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការរក្សាភាពស្មោះត្រង់ជាមួយអៀង សារី គឺនៅតែមាន ទោះបីជាក្រោយពេលមរណភាពរបស់គាត់ក៏ដោយ[48] ហើយ បញ្ជាក់ទៀតថា ចំណុចនេះនឹងរារាំង សហមេធាវីដែលត្រូវបានចាត់តាំង មិនឲ្យស្វះស្វែងរកវិធីការពារក្តីណាមួយ៉ាង តាងនាមឲ្យជនសង្ស័យ[49] ។ ដោយសារថាជនទាំងពីរនាក់ត្រូវបានចោទពីបទឧក្រិដ្ឋកម្មដូចគ្នា និងមានប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌឋានានុក្រម ទើប សហមេធាវីដែលត្រូវបានចាត់តាំង តាងនាមឲ្យជនសង្ស័យ នឹងមិនអាចស្វះស្វែងរកវិធីការពារក្តីដែលពាក់ព័ន្ធនឹងថ្នាក់លើរបស់គាត់ រួមទាំង អៀង សារី ផងដែរ[50]។

---

[45] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦២។

[46] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៥៧-៦២។ *សំណើសុំបដិសេធ* កថាខណ្ឌ ៤២-៥០។

[47] *សំណើសុំបដិសេធ* កថាខណ្ឌ ៤២។

[48] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ១៥។

[49] *សំណើសុំបដិសេធ* កថាខណ្ឌ ៤៣-៤៤ និង ៤៧-៥០។ *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦២។

[50] *សំណើសុំបដិសេធ* កថាខណ្ឌ ៤៣។

២៨. ឧទាហរណ៍ សហមេធាវីដែលត្រូវបានចាត់តាំង នឹងមិនអាចផ្តល់ប្រឹក្សាឯករាជ្យដល់ជនសង្ស័យ អំពីគោលការណ៍នៃការសហការជាមួយ អ.វ.ត.ក ពីព្រោះថា ប្រសិនបើធ្វើដូច្នេះ ពួកគាត់អាចរំលោភលើករណីយកិច្ចដែលនៅមានស្រាប់របស់ខ្លួនក្នុងការរក្សាភាពស្មោះត្រង់ ដោយសារឆ្លើយដាក់ អៀង សារី ដែលជាថ្នាក់លើរបស់ជនសង្ស័យ[51]។ បន្ថែមពីលើនេះទៀត អាចជាប្រយោជន៍របស់ជនសង្ស័យដែលត្រូវបញ្ជាក់ថា គាត់បានអនុវត្តសកម្មភាពដោយសារការបង្ខិតបង្ខំ ឬដោយផ្អែកលើមូលដ្ឋានថាតាមបញ្ជាថ្នាក់លើមកពីគណៈកម្មាធិការអចិន្ត្រៃយ៍ ដែល អៀង សារី ស្ថិតនៅក្នុងគណៈកម្មាធិការនេះ ប៉ុន្តែ សហមេធាវីដែលត្រូវបានចាត់តាំងនឹងនៅតែមិនអាចតស៊ូមតិបែបនោះបានឡើយ ប្រសិនបើមិនបានរំលោភលើករណីយកិច្ចរក្សាភាពស្មោះត្រង់របស់ខ្លួនជាមួយអៀង សារី[52]។

២៩. ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ ផ្តល់ទឡ្ហីករណ៍ថា នៅក្នុងបទសម្ភាសន៍ដែលជនសង្ស័យ បានបញ្ជាក់ថា "*អៀង សារី គឺជាអ្នកដឹកនាំ*" និងបានបង្ហាញថាអ្នកសម្ភាសន៍គាត់ បាននិយាយជាមួយគាត់ដើម្បី "*ដឹងរឿងរ៉ាវគ្រប់យ៉ាងនៅក្នុងសម័យនោះ*" ហើយជនសង្ស័យ ឆ្លើយដាក់ អៀង សារី ដោយផ្ទាល់ និងស្វះស្វែងឲ្យខ្លួនឯង រួចផុតពីការទទួលខុសត្រូវណាមួយ[53]។ ផ្ទុយមកវិញ សហមេធាវីដែលត្រូវបានចាត់តាំងនៅក្នុងសំណុំរឿង ០០២ បានស្វះស្វែងបញ្ជាក់ថា អៀង សារី "*មិនបានដឹងអ្វីទាំងអស់...ទាក់ទងនឹងការចាប់ខ្លួនទណាម្នាក់*"[54]។ ដូច្នេះ មេធាវីរបស់អៀង សារី នឹងមានប្រយោជន៍ក្នុងការបង្អាប់ការអះអាងបែបនេះ។ប្រសិនបើការអះអាងបែបនេះគឺជាការពិត វានឹងឲ្យជនសង្ស័យរួចផុតពីការទទួលខុសត្រូវ ហើយជួយការពារក្តីឬទឡ្ហីករណ៍អំពីបញ្ជាបញ្ជាថ្នាក់លើដូចមានខាងក្រោម[55]។

៣០. សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ផងដែរថា សហមេធាវីដែលត្រូវបានចាត់តាំង បន្តការពារផលប្រយោជន៍របស់ អៀង សារី "ដែលការណ៍នេះនាំឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការអនុវត្តភារកិច្ច

---

[51] *សំណើសុំបដិសេធ* កថាខណ្ឌ ៤៩។

[52] *សំណើសុំបដិសេធ* កថាខណ្ឌ ៤៧-៥០។

[53] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦១-៦២។

[54] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦២ *ដោយដកស្រង់* សំណុំរឿង ០០២ ឯលសារ E1/61.1 *ប្រតិចារឹក* ថ្ងៃទី ៩ ខែមេសា ឆ្នាំ ២០១២ ទំព័រ ២៦។

[55] *ដូចជើងទំព័រខាងលើ*។

ជាប់សន្ទារបស់ខ្លួនជាមួយជនសង្ស័យ"[56] ។ សហព្រះរាជអាជ្ញាអន្តរជាតិ គូសបញ្ជាក់ថា នៅក្នុងពិធីបុណ្យសពរបស់ អៀង សារី សហមេធាវីដែលត្រូវបានចាត់តាំង Michael Karnavas បានថ្លែងជាសាធារណៈថា គាត់"នៅជាប់ពាក់ព័ន្ធ"ជាមួយកូនក្តីរបស់គាត់ដែលបានស្លាប់ទៅ[57] ។ សហព្រះរាជអាជ្ញាអន្តរជាតិ ក៏បញ្ជាក់ថា ក្រោយពីមរណភាពរបស់អៀង សារី សហមេធាវីដែលត្រូវបានចាត់តាំងបានផ្សព្វផ្សាយគេហទំព័រមួយដែលមានបំណងបង្ហាញថា *"ការអនុវត្តបច្ចុប្បន្ន...របស់ អ.វ.ត.ក ដែលគាបសង្កត់លើការដាក់សារណាររបស់ក្រុមការពារក្តី... មិនឱ្យលោក អៀង សារី ទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌* [58]។ បើពិចារណាទៅលើអង្គហេតុទាំងនេះ សហមេធាវីដែលត្រូវបានចាត់តាំង នឹងមិនអាចផ្តល់យោបល់ជូន ជនសង្ស័យ ដោយផ្អែកលើគោលការណ៍រក្សាការសម្ងាត់នៃការស៊ើបអង្កេតបានទេ ប្រសិនបើមិនបានប៉ះពាល់ដល់ករណីយកិច្ចដែលគាត់នៅមានក្នុងការរក្សាភាពស្មោះត្រង់ជាមួយអៀង សារី និងប្រសិនបើមិនបានប៉ះពាល់ដល់ការយល់ឃើញអំពីសច្ចភាពនៃការអះអាងដែលបានធ្វើឡើងនៅលើគេហទំព័ររបស់ក្រុមការពារក្តី[59]។ ដូច្នេះ ទំនាស់ផលប្រយោជន៍មួយកើតឡើងដោយសារសហមេធាវីដែលត្រូវបានចាត់តាំង មានផលប្រយោជន៍ផ្ទាល់ខ្លួនខាងកេរ្តិ៍ឈ្មោះវិជ្ជាជីវៈរបស់ខ្លួន ករណីយកិច្ចរក្សាភាពស្មោះត្រង់ជាមួយអៀង សារី និងការជាប់ពាក់ព័ន្ធផ្ទាល់ខ្លួនជាមួយអៀង សារី ដែលបានស្លាប់ទៅ[60] ។

ii. ការលាតត្រដាងព័ត៌មានសម្ងាត់ដែលផ្តល់ឱ្យដោយ អៀង សារី

៣១. សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ថែមទៀតថា សហមេធាវីដែលត្រូវបានចាត់តាំង នៅតែបន្តជាប់ករណីយកិច្ចរក្សាការសម្ងាត់ឱ្យអៀង សារី ទោះបីក្រោយពេលមរណភាពរបស់គាត់ក៏ដោយ[61]។ បើពិចារណាទៅលើ"ទំនាក់ទំនងអង្គហេតុជាប់ពាក់ព័ន្ធគ្នា"រវាងសំណុំរឿងទាំងពីរនោះ គឺ"អាចព្យាករណ៍

[56] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦៥។

[57] *ដូចជើងទំព័រខាងលើ*។

[58] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦៦។

[59] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦៨។

[60] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦៥-៦៨។

[61] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៨។

ទុកជាមុន... សមហេតុផល”ថា ព័ត៌មានសម្ងាត់ដែល អៀង សារី បានផ្តល់ជូនសហមេធាវីដែលត្រូវបានចាត់តាំង អាចត្រូវប្រើប្រាស់ឲ្យខាតប្រយោជន៍របស់អៀង សារី ឬចំណេញប្រយោជន៍ក្នុងការការពារក្តីជនសង្ស័យ នៅក្នុងកាលៈទេសៈដែលផលប្រយោជន៍របស់ អៀង សារី និងជនសង្ស័យមានភាពផ្ទុយគ្នាជាសត្យានុម័ត[62]។ នេះនឹងបង្កើតឲ្យមានទំនាស់ផលប្រយោជន៍ធ្ងន់ធ្ងរនៅពេលដែលតំណាងជនសង្ស័យ[63]។

គ. ទំនាស់ផលប្រយោជន៍ទាំងនេះមិនអាចលះបង់ទេដោយសារប៉ះពាល់ដល់កិច្ចការរដ្ឋបាលតុលាការ

៣២. សហព្រះរាជអាជ្ញាអន្តរជាតិ ផ្តល់ទឡ្ហីករណ៍ថា ទំនាស់ផលប្រយោជន៍រៀបរាប់ខាងលើ មិនអាចលះបង់បានទេ ដោយសារអាចប៉ះពាល់ដល់កិច្ចការរដ្ឋបាលតុលាការនៅ អ.វ.ត.ត [64] ។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិ ផ្តល់ទឡ្ហីករណ៍ថា៖

i) ផលប៉ះពាល់ជាអចិន្ត្រៃយ៍ដល់កិច្ចការរដ្ឋបាលនឹងកើតឡើងប្រសិនបើជនសង្ស័យនិងជនជាប់ចោទមិនទទួលបានមេធាវីឯករាជ្យ ដែលអាចការពារក្តីឲ្យបានពេញលេញ តាងនាមឲ្យខ្លួន[65]។

ii) ផលប៉ះពាល់នឹងកើតឡើង ពីព្រោះថា ជនសង្ស័យ ត្រូវបានអង្គជំនុំជម្រះសាលាដំបូង កំណត់អត្តសញ្ញាណថាជាសាក្សីនៅក្នុងសំណុំរឿង ០០២ ហើយជនសង្ស័យនៅតែជាសាក្សីសក្តានុពលនៅក្នុងសំណុំរឿង ០០២/០២ ដែលនឹងរួមមានការចោទប្រកាន់ត្រួតស៊ីគ្នាជាមួយនឹងវិសាលភាពនៃការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣[66]។ មានហានិភ័យដែលថា សេចក្តីអះអាងឬភស្តុតាងពីមុនរបស់ជនសង្ស័យ អាចប្រើប្រាស់ដើម្បីឆ្លើយដាក់ថ្នាក់ដឹកនាំមជ្ឈិម ដោយផ្ទុយទៅនឹងប្រយោជន៍របស់អៀង សារី[67]។ បន្ថែមពីលើនេះទៀត ក្នុងនាមជាមេធាវីតំណាងជនសង្ស័យ

---

[62] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៦៣។

[63] *ដូចជើងទំព័រខាងលើ*។

[64] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧០។

[65] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧០-៧២។.

[66] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧៣។

[67] *ការឆ្លើយតប* កថាខណ្ឌ ៣៣។

នៅក្នុងសំណុំរឿង ០០៣ សហមេធាវីដែលត្រូវបានចាត់តាំង នឹងមានលទ្ធភាពទៅជួប និងមានឥទ្ធិពលទៅលើសាក្សីណាម្នាក់នៅក្នុងសំណុំរឿងណាមួយដែលពួកគាត់ មានប្រយោជន៍ផ្ទាល់ខ្លួន និងវិជ្ជាជីវៈនៅពេលចេញលទ្ធផល[68]។

iii) អង្គហេតុដែលថាជនសង្ស័យ បានជូនដំណឹងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការសម្រេចរបស់គាត់នៅស្ងៀមមិនឆ្លើយតប បង្ហាញថា ការសម្រេចនេះត្រូវបានធ្វើឡើងដើម្បីកាត់បន្ថយលទ្ធភាពទំនាស់ផលប្រយោជន៍[69]។ តាមវិធីនេះ សហមេធាវីដែលត្រូវបានចាត់តាំង បានធ្វើឱ្យប៉ះពាល់រួចហើយដល់កិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២, ០០៣ និង ០០៤[70] ។ ជាងនេះទៀត "ការយល់ឃើញដ៏លើសលុប"ដែលថា ជនសង្ស័យបានធ្វើសេចក្ដីសម្រេចនេះដើម្បីជាប្រយោជន៍ដល់មេធាវីរបស់ខ្លួន ជាជាងប្រយោជន៍របស់គាត់នោះ នឹងកាត់បន្ថយជំនឿជាសាធារណៈមកលើ អ.វ.ត.ក និងប៉ះពាល់ដល់កិច្ចការរដ្ឋបាលតុលាការ[71]។

៣៣. យោងតាមសហព្រះរាជអាជ្ញាអន្តរជាតិ បានឱ្យដឹងថា ការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំងនាំឱ្យមានហានិភ័យប្ដឹងឧទ្ធរណ៍ដោយផ្អែកលើជំនួយផ្ដល់មេធាវីមិនមានប្រសិទ្ធភាព[72]។ បន្ថែមពីលើនេះទៀត បើពិចារណាលើភាពមិនគ្រប់គ្រាន់នៃការលះបង់សិទ្ធិ ប្រសិនបើជនសង្ស័យដកការយល់ព្រមរបស់គាត់វិញ គាត់នឹងអាចពន្យារពេលកិច្ចដំណើរការនីតិវិធីបានច្រើនខណៈដែលរង់ចាំការតែងតាំងមេធាវី ថ្មី[73]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេត គួរតែបដិសេធមិនបញ្ជាក់ពីការតែងតាំងនេះ ដែលជាផ្នែកមួយនៃអំណាចមានស្រាប់របស់សហចៅក្រមស៊ើបអង្កេត ដើម្បីការពារប្រយោជន៍របស់ អ.វ.ត.ក ក្នុងនាមជាស្ថាប័នមួយ[74]។

---

[68] *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧៣-៧៤ និង *ការឆ្លើយតប* កថាខណ្ឌ ៣២-៣៣។

[69] *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧៦។

[70] *ដូចជើងទំព័រខាងលើ*។

[71] *ដូចជើងទំព័រខាងលើ*។

[72] *សំណើសុំបដិសេធ* កថាខណ្ឌ ៥១ និង ៥៣។

[73] *សំណើសុំបដិសេធ* កថាខណ្ឌ ៥៣។

[74] *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧០-៧៧។

ឃ. ការលះបង់សិទ្ធិ មានវិការៈ និងមិនអាចផ្សះផ្សារបាន

៣៤. ជាជម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ថា ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ស្របថា ទំនាស់ផលប្រយោជន៍ដែលបានរៀបរាប់ខាងលើ មិនអាចផ្សះផ្សាបានទេ នោះការលះបង់សិទ្ធិពីក្រុមការពារក្តី គឺមានលក្ខណៈទូទៅ និងទូលំទូលាយពេកមិនអាចបង្ហាញពីការយល់ព្រមដែលបានធ្វើឡើងដោយទទួលបានព័ត៌មានពេញលេញឡើយ[75]។ ការតែងតាំងសហមេធាវីដោយគ្មានការលះបង់សិទ្ធិសមស្រប នឹងមិនអាចជំទាស់បានឡើយទៅលើការប្តឹងតវ៉ាអំពីជំនួយគ្មានប្រសិទ្ធភាពពីមេធាវី។ បន្ថែមពីលើនេះទៀត ក្រោយពីមរណភាពរបស់អៀង សារី ការលះបង់សិទ្ធិរបស់គាត់ លែងផ្សះផ្សាបានហើយ[76]។

## II. សារណា និងសារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង

៣៥. សហមេធាវីដែលត្រូវបានចាត់តាំង បានសង្កត់ធ្ងន់ទៅលើលក្ខណៈជាសារវ័ន្តនៃសិទ្ធិទទួលបានមេធាវីតាមជម្រើសរបស់ខ្លួន បន្ទាប់មក ជំទាស់ទៅនឹងអត្ថិភាពនៃទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធរវាងការចោទប្រកាន់អំពីការប្រព្រឹត្តរបស់ អៀង សារី និង មាស មុត និងអត្ថិភាពនៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន[77]។ នៅក្នុង *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* សហមេធាវី ក៏ជំទាស់ទៅលើការបញ្ចូលទន្នីករណ៍ "ប្រលោមលោក"នៅក្នុងសេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ" ទាក់ទងនឹងការធ្វើឱ្យប៉ះពាល់ដល់ជំនឿទុកចិត្តសាធារណៈមកលើ អ.វ.ត.ក និងកិច្ចការរដ្ឋបាលតុលាការ ដោយបញ្ជាក់ថាការបញ្ចូលទន្នីករណ៍នោះគឺហួសពីក្របខ័ណ្ឌនៃដីកាសម្រេចលើកាលកំណត់កាលបរិច្ឆេទលើកទី ២[78]។

---

[75] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៧៨-៧៩។

[76] *សេចក្តីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ* កថាខណ្ឌ ៨៣។

[77] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* ទំព័រ ១ កថាខណ្ឌ ៤៥។ *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៥៣។

[78] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ១។

00968692



ក. គ្មានទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានចោទ

៣៦. ទាក់ទងនឹងអត្ថិភាពនៃទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធរវាងរឿងក្ដីរបស់អៀង សារី និង ជនសង្ស័យ សហមេធាវីដែលត្រូវបានចាត់តាំង ឆ្លើយថា ខ្លួនបានស្វែងរកយ៉ាងស្វិតស្វាញនូវវិធីការពារក្ដីដែល បង្ហាញថា អៀង សារី គ្មានការជាប់ពាក់ព័ន្ធជាមួយនឹង ស-២១ ឬបញ្ហាការពារជាតិ ដូចដែលអាចរក ឃើញតាមរយៈការសួរដេញដោលរបស់ខ្លួនទៅលើ ឌុច និង David Chandler នៅក្នុងសំណុំរឿង ០០២[79] ។ អៀង សារី និងជនសង្ស័យ បញ្ជាក់ថា ពួកគាត់ "គ្មានទំនាក់ទំនងជាមួយគ្នា ឬដឹងពីតួនាទីគ្នា ឬការប្រព្រឹត្តដែលបានចោទនោះទេ។ តួនាទី មុខងារ និងការប្រព្រឹត្តរបស់ពួកគាត់ គឺនៅដោយឡែកពី គ្នា ដាច់ពីគ្នា និងខុសគ្នាពីឆ្នាំ ១៩៧៥-១៩៧៩[80] ។ ដូច្នេះ គ្មានកូនក្ដីណាម្នាក់ ពឹងផ្អែក ឬបានពឹងផ្អែកទៅលើក្រុមការពារក្ដីដែលនឹងឆ្លើយដាក់កូនក្ដីផ្សេងទៀតទេ[81]។

៣៧. សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថែមទៀតថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបញ្ជាក់ បង្ហាញពីអត្ថិភាពនៃទំនាក់ទំនងមុខងារ និងឋានានុក្រមយ៉ាងជិតស្និទ្ធរវាង អៀង សារី ជាមួយ ជនសង្ស័យ[82]។ គណៈកម្មាធិការមជ្ឈិម មានសមាជិកប្រហែល ៣០ នាក់ ហើយជួបប្រជុំគ្នា ៦ខែម្ដង[83] ហើយគ្មានភស្តុតាងបង្ហាញថា អៀង សារី និងជនសង្ស័យ មានទំនាក់ទំនងជាមួយគ្នា ក្នុងនាមជាសមាជិកគណៈកម្មាធិការមជ្ឈិមដែរ[84]។ បន្ថែមពីលើនេះទៀត អង្គហេតុដែលថា ឈ្មោះ របស់អៀង សារី មាននៅក្នុងឯកសារដូចដែលបានចម្លងនៅលើទូរលេខ ឬសេចក្ដីរាយការណ៍នោះ គឺមិនមែនជាភស្តុតាងបញ្ជាក់ថា គាត់ពិតជាទទួលបានឯកសារទាំងនោះទេ[85]។ ភស្តុតាងនៅក្នុងសំណុំ រឿង ០០២ បង្ហាញថា ទូរលេខទាំងអស់ ត្រូវបានផ្ញើជូនទៅ ប៉ុល ពត ដែលនៅពេលនោះគឺជា អ្នកសម្រេចថាតើបុគ្គលណានឹងទទួលបានឯកសារទាំងនោះពិតប្រាកដ[86]។

---

[79] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ២៧។

[80] *ដូចជើងទំព័រខាងលើ*។

[81] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣២។

[82] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ២៩។

[83] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣០។

[84] *ដូចជើងទំព័រខាងលើ*។

[85] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ២៩-៣០ និង៤៣។

[86] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ២៩។

៣៨. សហមេធាវីដែលត្រូវបានចាត់តាំង ក៏ជំទាស់ទៅនឹងការដកស្រង់សម្ដីទាក់ទងនឹងអៀង សារី ដែលសារព័ត៌មានមួយ បានដកស្រង់ពីជនសង្ស័យ ហើយសហព្រះរាជអាជ្ញាអន្តរជាតិ បានប្រើជាមូលដ្ឋាន[87]។ សហមេធាវីដែលត្រូវបានចាត់តាំង អះអាងថា "[មិន]គប្បីត្រូវថ្លឹងថ្លែង ឬពិចារណាឲ្យបានដិតដល់ទៅលើការដកស្រង់សេចក្ដីមួយចំនួនពីសារព័ត៌មានដែលមានការចុះកាលបរិច្ឆេទ ជាពិសេសពេលដែលមិនដឹងប្រាកដពីការដកស្រង់សេចក្ដីទាំងអស់" រួមមានការណ៍ដែលមិនដឹងពី "អ្វីដែលបានលើកឡើង មិនដឹងពីបរិបទ និងមិនដឹងមូលហេតុ[88]។

៣៩. ទាក់ទងនឹងឯកសារដែលបានលើកឡើងនៅក្នុង*ដីកាសម្រេចថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣* ដែលសំដៅលើសេចក្ដីថ្លែងការណ៍ដែលគេចោទថាអៀង សារី បានធ្វើឡើងទាក់ទងនឹងការចាប់ខ្លួន និងសម្លាប់អ្នកនេសាទថៃនោះ សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា សេចក្ដីថ្លែងការណ៍ទាំងនោះមានតម្លៃភស្តុតាងតិចតួច ពីព្រោះថាវាគ្មានកំណត់សម្គាល់បង្ហាញពីភាពគួរឲ្យជឿជាក់ ភាពត្រឹមត្រូវ ភាពគួរឲ្យទុកចិត្ត ឬពេញលេញឡើយ[89]។ គ្មានការបង្ហាញពីកាលបរិច្ឆេទ និងទីកន្លែងដែលអៀង សារី បានធ្វើសេចក្ដីថ្លែងការណ៍ដែលបានចោទទាំងនោះឡើយ[90]។ បន្ថែមពីលើនេះទៀត ទាំងអត្ថបទសង្ខេបព័ត៌មាន និងអត្ថបទសារព័ត៌មាននោះ មិនមានការបង្ហាញទាក់ទនឹងអ្នកនិពន្ធអត្ថបទទាំងនោះឡើយ ដូច្នេះមិនអាចឲ្យជនសង្ស័យ អនុវត្តសិទ្ធិតទល់ដេញដោលបានឡើយ[91]។ ទោះបីជាសន្មតថា អៀង សារី អាចបានទាក់ទងរដ្ឋាភិបាលថៃក៏ដោយ ក៏គ្មានអ្វីអាចទទួលបានក្រៅពីអង្គហេតុតែមួយគត់ដែលថាគាត់អាចបញ្ជូនសារមួយដោយសារតួនាទីរបស់គាត់តែប៉ុណ្ណោះ[92]។ ចុងក្រោយបំផុត សហមេធាវីដែលត្រូវបានចាត់តាំង ផ្ដល់ទឡ្ហីករណ៍ថា ឯកសារទាំងនេះ មិនបញ្ជាក់ថា គាត់ជាប់ពាក់ព័ន្ធនឹងដំណើរការធ្វើសេចក្ដីសម្រេចណាមួយឡើយ[93]។

---

[87] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣៥។

[88] *ដូចជើងទំព័រខាងលើ*។

[89] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣១។

[90] *ដូចជើងទំព័រខាងលើ*។

[91] *ដូចជើងទំព័រខាងលើ*។

[92] *ដូចជើងទំព័រខាងលើ*។

[93] *ដូចជើងទំព័រខាងលើ*។

ខ. គ្មានទំនាស់ផលប្រយោជន៍

៤០. សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា ទឡ្ហីករណ៍ដែលបានលើកឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ស្តីពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍ គឺជាការស្មានទាំងស្រុង។ សហព្រះរាជអាជ្ញាអន្តរជាតិ មិនមានការយល់ឃើញពីយុទ្ធសាស្ត្ររបស់សហមេធាវីដែលត្រូវបានចាត់តាំង ក្នុងការការពារជនសង្ស័យ ហើយគាត់គ្រាន់តែ "បង្កើតការយល់ឃើញ"តែប៉ុណ្ណោះ[94] ។

គ. លទ្ធភាព និងឆន្ទៈស្វែងរកវិធីការពារក្តីណាមួយ៉ាង រួមទាំងការសហការ និងកត្តាស្ថានសម្រាលណាមួយ៉ាង

៤១. ទាក់ទងនឹងលទ្ធភាពសហការជាមួយនឹងតុលាការ សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា ជនសង្ស័យ *"ត្រូវបានជូនដំណឹងពេញលេញអំពីចំណុចវិជ្ជមាន និងអវិជ្ជមាននៃការសហការនៅក្នុងសំណុំរឿង ០០៣...។ ដោយមានការយល់ដឹង និងពិចារណាពេញលេញ ហើយបន្ទាប់ពីទទួលបានយោបល់ប្រឹក្សាដំបូងពីអង្គភាពគាំពារការពារក្តី ក្រោយមក ពីក្រុមការពារក្តី [...] គាត់បានចុះហត្ថលេខាលើការជូនដំណឹងទាមទារសិទ្ធិនៅស្ងៀមមិនឆ្លើយតប"*[95] ។ ដូច្នេះ ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងដែលថាការសហការរបស់ឌុច គឺជាកត្តាស្ថានសម្រាលមួយនោះ គឺមិនជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៣ ឡើយ[96]។ បន្ថែមពីលើនេះទៀត ជនសង្ស័យ មានបំណងជំទាស់ទាំងស្រុងទៅនឹងការចោទប្រកាន់ប្រឆាំងនឹងគាត់ និងបង្ហាញការពារក្តីដ៏រឹងមាំ[97]។ ទាំង អៀង សារី និងជនសង្ស័យ បញ្ជាក់ថា គ្មានទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមរវាងពួកគាត់ឡើយ ដែលឲ្យជនសង្ស័យអាចផ្តល់ទឡ្ហីករណ៍អំពីការបង្ខិតបង្ខំ ឬការបញ្ជាថ្នាក់លើទាក់ទងនឹងអៀង សារី[98]។

---

[94] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣៣។

[95] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣៩។

[96] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣៧។

[97] *ដូចជើងទំព័រខាងលើ*។

[98] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤១។

៤២. សហមេធាវីដែលត្រូវបានចាត់តាំង ក៏បញ្ជាក់ថា មានឧទាហរណ៍ជាច្រើន ដែលមេធាវីការពារក្តី បានតំណាងកូនក្តី នៅក្នុងរឿងក្តីដែលមានទំនាក់ទំនងអង្គហេតុ នៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ("ICTY") ដូចជា ការជំនុំជម្រះរឿងក្តី Srebrenica[99] ។

៤៣. បន្ថែមពីនេះទៀត សហមេធាវីដែលត្រូវបានចាត់តាំង ក៏បញ្ជាក់ថា ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការចូលរួមរបស់លោក Karnavas នៅក្នុងពិធីបញ្ចុះសពរបស់អៀង សារី និងគេហទំព័រសាធារណៈដែលបង្កើតឡើងដោយសហមេធាវីដែលត្រូវបានចាត់តាំង គឺជាការវាយប្រហារលក្ខណៈទស្សនៈបុគ្គលដែលគ្មានមូលដ្ឋាន[100]។ ការចូលរួមរបស់សហមេធាវីដែលត្រូវបានចាត់តាំង និងសេចក្តីថ្លែងការណ៍ដែលបានរាយការណ៍ដោយសារព័ត៌មាន គ្រាន់តែបង្ហាញពីការគោរពគ្នាទៅវិញទៅមក និងបង្ហាញពីកម្រិតនៃការប្តេជ្ញាចិត្ត ដែលសហមេធាវីដែលត្រូវបានចាត់តាំង ផ្តល់ជូនកូនក្តីរបស់ខ្លួន[101]។ សហមេធាវីដែលត្រូវបានចាត់តាំង ក៏បញ្ជាក់ទៀតថា ជាគោលការណ៍បឋម គេហទំព័ររបស់ខ្លួន ដែលបានបង្កើតឡើងនៅឆ្នាំ ២០០៩ ក្នុងគោលបំណងចង់មានតម្លាភាពនោះ គឺគ្រាន់តែជាឧបករណ៍ស្រាវជ្រាវមួយតែប៉ុណ្ណោះ។ ទោះបីជាវាមានអត្ថបទ និងសេចក្តីប្រកាសព័ត៌មានមួយចំនួនក៏ដោយ ក៏គេហទំព័រនេះមិនមែនតស៊ូមតិ តាងនាមឲ្យអៀង សារី ដែរ[102]។

ឃ. ការប្រើប្រាស់ព័ត៌មានសម្ងាត់

៤៤. ទាក់ទងនឹងការប្រើប្រាស់នៅក្នុងសំណុំរឿង ០០៣ នូវព័ត៌មានសម្ងាត់ទទួលបានពីអៀង សារី សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា គ្មានកូនក្តីម្នាក់ណា មានព័ត៌មានដែលអាចប៉ះពាល់ដល់កូនក្តីម្នាក់ទៀតឡើយ ហើយការស្មានអំពីបញ្ហានេះ មិនគួរបង្កើតជាមូលដ្ឋានសម្រាប់ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំង[103]។ ទោះថាករណីយកិច្ចរក្សាការសម្ងាត់អាចប៉ះពាល់ដល់ករណីយកិច្ចរបស់មេធាវីណាម្នាក់ចំពោះកូនក្តីផ្សេងទៀតក៏ដោយ ក៏

---

[99] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣៧។

[100] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ២៩-៣២ និងកថាខណ្ឌ ៣៥។

[101] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣០។

[102] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣១-៣២ និង ៣៥។

[103] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣៥។

00968696



វាមិនប្រាកដជាមានន័យថារឿងនេះនឹងតែងតែកើតឡើងដូច្នេះឡើយ [104]។ សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា ដោយផ្អែកលើមូលដ្ឋានយុទ្ធសាស្ត្ររឿងក្តីដែលបានប្រើប្រាស់ដើម្បីការពារទាំងជនសង្ស័យ និងអៀង សារី សហមេធាវីដែលត្រូវបានចាត់តាំង មានមូលដ្ឋានហួសពីសុទ្ធចិត្តដើម្បីបញ្ជាក់ថា គ្មានព័ត៌មានដែលទទួលបានពីកូនក្តីណាម្នាក់នឹងត្រូវប្រើប្រាស់ឲ្យប៉ះពាល់ដល់កូនក្តីម្នាក់ទៀតឡើយ[105]។ យ៉ាងណាក៏ដោយ ក៏ជនសង្ស័យ នឹងទទួលបានប្រយោជន៍ពីបទពិសោធន៍ និងការយល់ដឹងរបស់សហមេធាវីដែលត្រូវបានចាត់តាំង អំពីហេតុការណ៍ជាប់ពាក់ព័ន្ធ[106]។

ង. នឹងគ្មានការប៉ះពាល់ដល់កិច្ចការរដ្ឋបាលតុលាការ

៤៥. សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើការបញ្ជាក់អះអាងជាលក្ខណៈសម្មិតកម្មតែប៉ុណ្ណោះថាតើ ការតំណាងពេលមុនឲ្យអៀង សារី មាន ឬក៏មិនមានហានិភ័យខ្លាំងអាចប៉ះពាល់ធ្ងន់ធ្ងរដល់ជនសង្ស័យ[107] ថាតើសហមេធាវីដែលត្រូវបានចាត់តាំង នឹងព្យាយាមដាក់ឥទ្ធិពលទៅលើជនសង្ស័យ ទាក់ទងនឹងសំណុំរឿង ០០២ ឬអត់[108] និងថាតើ ជនសង្ស័យ នឹងទទួលបាន ឬក៏មិនទទួលបានការពារក្តីដ៏ខ្លាំងក្លាពីសហមេធាវីដែលត្រូវបានចាត់តាំង[109]។

៤៦. សហមេធាវីដែលត្រូវបានចាត់តាំង ក៏ជំទាស់ទៅនឹងជំហររបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សហមេធាវីដែលត្រូវបានចាត់តាំង បានអនុវត្តដោយគ្មានក្រមសីលធម៌ និងបង្កគ្រោះថ្នាក់ដល់កិច្ចការរដ្ឋបាលតុលាការ ដោយសារបានជូនដំណឹងទៅ ជនសង្ស័យ អំពីសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[110]។ សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា ជនសង្ស័យ មានសិទ្ធិអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតប[111]។ ដូច្នេះ មិនសមស្របដែលបង្ហាញថា កិច្ចការរដ្ឋបាល

---

104 *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៧-១១។

105 *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ១៨។

106 *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ១៩។

107 *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ២០។

108 *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤៥-៤៦។

109 *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤១។

110 *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤៨-៤៩។

111 *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤២-៤៥, ៤៨-៤៩ និង ៥៣។

00968697



តុលាការ ត្រូវបានស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ ដោយសារជនសង្ស័យត្រូវបានផ្តល់ប្រឹក្សាឱ្យប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប ហើយបានពិតជាបានប្រើប្រាស់សិទ្ធិនោះ[112]។

៤៧. សហមេធាវីដែលត្រូវបានចាត់តាំង ចាត់ទុកថាជាការចោទប្រកាន់ដែលគ្មានមូលដ្ឋានចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា ជនសង្ស័យមិនគួរមានមធ្យោបាយយុទ្ធវិធីដើម្បីពន្យារពេលកិច្ចដំណើរការនីតិវិធី[113]។ សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានផ្តល់ភស្តុតាងបញ្ជាក់ថា សហមេធាវីដែលត្រូវបានចាត់តាំង បានចូលរួមក្នុងសំណុំរឿង ០០២ ឬនឹងចូលរួមក្នុងសំណុំរឿង ០០៣ ក្នុងរបៀបយុទ្ធវិធីណាមួយម្យ៉ាងដែលអាចមានមន្ទិល ឬគ្មានក្រមសីលធម៌ឡើយ[114]។

ច. សុពលភាពនៃការលះបង់សិទ្ធិ

៤៨. ចុងក្រោយបំផុត សហមេធាវីដែលត្រូវបានចាត់តាំង ផ្តល់ទឡ្ហីករណ៍ថា ការលះបង់សិទ្ធិដែល អៀង សារី និងជនសង្ស័យ ទទួលបាន គឺមានសុពលភាព ហើយការតវ៉ារបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងសុពលភាពនៃការលះបង់សិទ្ធិទាំងនេះ គឺពឹងផ្អែកលើមូលដ្ឋាននៃការប្រមាណ និងការស្មាន[115]។ ការលះបង់សិទ្ធិ តាមលក្ខណៈរបស់វា គឺមិនមានអង្គហេតុច្បាស់លាស់អំពីរឿងក្តីណាមួយ ឬអំពីអ្វីដែលបានពិភាក្សាពិតប្រាកដឡើយ[116]។ វាអាស្រ័យទៅលើ មេធាវី ក្នុងការផ្តល់យោបល់ពេញលេញទៅឱ្យកូនក្តី អំពីបញ្ហាជាប់ពាក់ព័ន្ធនៃការយល់ព្រមទទួលយកតំណាងមេធាវី ហើយរឿងនេះបានធ្វើរួចហើយនៅក្នុងសំណុំរឿងនេះ[117] ។

---

[112] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤៨។

[113] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤៤។

[114] *ដូចជើងទំព័រខាងលើ*។

[115] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤២ និង*សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៥០-៥២។

[116] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៥០។

[117] *ដូចជើងទំព័រខាងលើ* និង*សូមមើលផងដែរ សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៥។

៤៩. សហមេធាវីដែលត្រូវបានចាត់តាំង ទទួលស្គាល់ថា អាជ្ញាធរតុលាការ ត្រូវតែជឿជាក់ថា លក្ខណៈវិនិច្ឆ័យណាម្យ៉ាងត្រូវបានអនុវត្តមុនពេលទទួលយកការលះបង់សិទ្ធិ[118]។ ប៉ុន្តែ តាមទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ មេធាវីណាម្នាក់របស់ជនសង្ស័យ នឹងត្រូវលាតត្រដាងព័ត៌មានឯកសិទ្ធិទាក់ទងនឹងខ្លឹមសារនៃការតំណាងកូនក្តី ឬមេធាវីនោះ នឹងត្រូវផ្តល់ព័ត៌មានអំពីយុទ្ធសាស្ត្ររបស់គាត់ដើម្បីធ្វើឲ្យអាជ្ញាធរតុលាការជឿជាក់[119]។ លក្ខខណ្ឌ"*ចម្លែក*"នេះ មិនមែនជាលក្ខខណ្ឌតម្រូវតាមយុត្តិសាស្ត្ររបស់ អ.វ.ត.ក ឡើយ[120] ។

៥០. បន្ថែមពីលើនេះទៀត សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា គ្មានលក្ខខណ្ឌតម្រូវតាមនីតិវិធីនៅ អ.វ.ត.ក ដែលត្រូវណែនាំកូនក្តីណាម្នាក់ ទៅរកយោបល់ប្រឹក្សាឯករាជ្យមុនពេលលះបង់សិទ្ធិអំពីទំនាស់ណាមួយឡើយ[121]។ ប្រធានអង្គភាពគាំពារការពារក្តី បានពិភាក្សាការតែងតាំង និងការលះបង់សិទ្ធិនេះជាមួយជនសង្ស័យ[122]។

៥១. ទាក់ទងនឹងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា ការលះបង់សិទ្ធិរបស់អៀង សារី មិនគ្រប់គ្រាន់ ដោយសារមរណភាពរបស់គាត់នោះ សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា ជំហរនេះមិនមានការគាំទ្រតាមច្បាប់ជាធរមានទេ[123]។ ការស្មានថាសហមេធាវីដែលត្រូវបានចាត់តាំងនឹងចាំបាច់ត្រូវស្នើសុំការណែនាំបន្ថែមទៀតពីអៀង សារី គឺជាមូលដ្ឋានមិនគ្រប់គ្រាន់ដែលប្រកាសថាការលះបង់សិទ្ធិបច្ចុប្បន្ននេះ គ្មានសុពលភាព ឬមិនគ្រប់គ្រាន់[124]។

---

[118] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ២៧។

[119] *ដូចជើងទំព័រខាងលើ*។

[120] *ដូចជើងទំព័រខាងលើ*។

[121] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ២៨។

[122] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៥១។

[123] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៥២។

[124] *ដូចជើងទំព័រខាងលើ*។

## III. ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ

៥២. នៅក្នុង*ការឆ្លើយតប* សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ[125] បញ្ជាក់ថា សហមេធាវីដែលត្រូវបានចាត់តាំង ប្រើប្រាស់ការតេស្តពិនិត្យបែបអត្តនោម័តនៅក្នុងរឿងក្តី "*ដោយតវ៉ាថាទំនាស់ផលប្រយោជន៍នឹងមិនកើតមានឡើងឡើយឲ្យតែគេបានពិចារណាថាខ្លួនឯងពេញចិត្តថា ទំនាស់ផលប្រយោជន៍ពិតជាមិនមាន និងឲ្យតែអះអាងផ្ទាល់ថា ទំនាស់នោះនឹងមិនកើតមាន*"[126]។

៥៣. សហមេធាវីដែលត្រូវបានចាត់តាំង បានអះអាងថា គ្មានហានិភ័យអាចមានទំនាស់ផលប្រយោជន៍ឡើយ ដោយផ្អែកលើទ្រឹស្តីយុទ្ធសាស្ត្ររឿងក្តី ដែលជនសង្ស័យ និងអៀង សារី បានណែនាំមេធាវី ឲ្យបន្តនីតិវិធីទៅមុខ។ ទាក់ទងនឹងការអះអាងនេះ សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ អង្កេតថា ទ្រឹស្តីយុទ្ធសាស្ត្ររឿងក្តី ជារឿយៗវិវត្តនៅពេលដែលកិច្ចដំណើរការនីតិវិធីដំណើរការទៅមុខ[127]។ បើពិចារណាទៅលើភាពជិតស្និទ្ធនៃទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមរវាងអៀង សារី ជាមួយជនសង្ស័យ ឃើញថា ប្រយោជន៍របស់ពួកគាត់ គឺអាចព្យាករណ៍ជាមុនដោយសមហេតុផលថា មានភាពផ្ទុយគ្នា ឬនឹងមានភាពផ្ទុយគ្នានៅក្នុងកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនសង្ស័យ[128]។ ទំនាក់ទំនងរបស់ពួកគាត់ក៏ជិតស្និទ្ធដូច ឬជិតស្និទ្ធជាងទំនាក់ទំនងរវាងចុងចោទនៅក្នុងយុត្តិសាស្ត្ររឿងក្តីរបស់តុលាការ ICTY ដែលក្នុងរឿងក្តីនេះ មេធាវីត្រូវបានហាមឃាត់ ដោយសារទំនាស់ផលប្រយោជន៍[129]។

៥៤. សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ ជំទាស់ទៅនឹងការលើកឡើងរបស់ សហមេធាវីដែលត្រូវបានចាត់ចែងអំពីការអនុវត្តរបស់តុលាការ ICTY នៅក្នុងការតែងតាំងមេធាវីការពារក្តី[130]។ សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ ផ្តល់ទឡ្ហីករណ៍ថា សហមេធាវីដែលត្រូវបានចាត់តាំង ខកខានមិនបានបែងចែកឲ្យដាច់ស្រលះរវាងរឿងក្តីរបស់តុលាការ ICTY ដែលមេធាវីការពារក្តី ពីមុនធ្លាប់ធ្វើជាសមាជិក

---

[125] ឥឡូវនេះ សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ Nicholas KOUMJIAN ត្រូវបានតែងតាំងជា សហព្រះរាជអាជ្ញាអន្តរជាតិ។

[126] *ការឆ្លើយតប* កថាខណ្ឌ ៦ *ដោយដកស្រង់*កថាខណ្ឌ ១៧ នៃ*សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង*។

[127] *ការឆ្លើយតប* កថាខណ្ឌ ១១។

[128] *ការឆ្លើយតប* កថាខណ្ឌ ១៣។

[129] *ដូចជើងទំព័រខាងលើ*។

[130] *ការឆ្លើយតប* កថាខណ្ឌ ១៥។

រដ្ឋអាជ្ញា ជាមួយនឹងរឿងក្តីផ្សេងៗដែលជាប់ពាក់ព័ន្ធនឹងមេធាវីការពារក្តី តំណាងកូនក្តីច្រើននាក់ដែលត្រូវបានចោទបញ្ជូនទៅជំនុំជម្រះចំពោះអង្គហេតុស្រដៀងគ្នា[131]។ បទដ្ឋានភស្តុតាងនៅក្នុងរឿងក្តីទីមួយគឺមានកម្រិតទាបសមហេតុផលជាងបទដ្ឋានភស្តុតាងនៅក្នុងរឿងក្តីស៊ីណារីយ៉ូទីពីរ ដែលទាក់ទងនឹងមេធាវីការពារក្តីតំណាងកូនក្តីច្រើននាក់[132] ។

៥៥. សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ ធ្វើសេចក្តីសន្និដ្ឋានដោយបញ្ជាក់ឡើងវិញថា ប្រសិនបើទំនាស់ផលប្រយោជន៍មិនត្រូវបានដោះស្រាយនៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធីទេ នោះកិច្ចការរដ្ឋបាលតុលាការអាចត្រូវប៉ះពាល់ជាអចិន្ត្រៃយ៍[133]។ វានឹងប៉ះពាល់ដល់សេចក្តីសម្រេចណាមួយរបស់ជនសង្ស័យ ក្នុងការផ្តល់ភស្តុតាងជូនសហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ០០៣ និងអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២[134]។ ក៏មានហានិភ័យផងដែរថា សហមេធាវីដែលត្រូវបានចាត់តាំង អាចដកខ្លួននៅដំណាក់កាលណាមួយនៃការស៊ើបអង្កេតដោយសារទំនាស់ផលប្រយោជន៍ដូច្នេះនឹងពន្យារពេលកិច្ចដំណើរការនីតិវិធី[135]។

## IV.សំណើបន្ទាន់

៥៦. សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា *ដីកាសម្រេចលើញត្តិ និងសារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* [136] ចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងសំណុំរឿង ០០៤ មានចំណុចអង្គច្បាប់ពាក់ព័ន្ធនឹងយុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតលើការចោទប្រកាន់

---

[131] *ការឆ្លើយតប* កថាខណ្ឌ ១៧។

[132] *ការឆ្លើយតប* កថាខណ្ឌ ១៧-១៨។

[133] *ការឆ្លើយតប* កថាខណ្ឌ ៣៣។

[134] *ការឆ្លើយតប* កថាខណ្ឌ ៣២-៣៣។

[135] *ការឆ្លើយតប* កថាខណ្ឌ ៣១។

[136] សំណុំរឿង ០០៤ ឯកសារ D122/6 *ដីកាសម្រេចលើញត្តិ និងសារណាបន្ថែមស្តីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣។

អំពីទំនាស់ផលប្រយោជន៍នៅក្នុងសំណុំរឿង ០០៣ ដែលសហមេធាវីដែលត្រូវបានចាត់តាំងមិនបាន ទទួលនៅពេលដែលដាក់សារណារបស់ខ្លួន[137]។

៥៧. សហមេធាវីដែលត្រូវបានចាត់តាំង អះអាងថា តាមរយៈដីកាសម្រេចនេះ សហចៅក្រមស៊ើបអង្កេត អន្តរជាតិ បានបញ្ជាក់ថាបញ្ហាទាក់ទងនឹងទំនាស់គឺស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់អង្គភាពគាំពារ ការពារក្ដី ហើយដំណោះស្រាយនេះ ត្រូវបានគាំទ្រដោយច្បាប់កម្ពុជា និងបារាំង[138]។

៥៨. សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា អាជ្ញាធរសមស្របសម្រាប់សម្រេចលើទំនាស់ផល ប្រយោជន៍ គឺអង្គភាពគាំពារការពារក្ដី និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា(“គណៈមេធាវី”) ដែលបានសម្រេចរួចហើយថា គ្មានទំនាស់ផលប្រយោជន៍ទេ[139]។ អង្គភាពគាំពារការពារក្ដី នៅតែរក្សា សមត្ថកិច្ចពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់ខ្លួន ទាក់ទងនឹងមេធាវី ហើយប្រសិនបើ អង្គភាពគាំពារការពារក្ដី បានពិចារណាថាទំនាស់ផលប្រយោជន៍ បានប៉ះពាល់ដល់ការតំណាងផ្លូវ ច្បាប់នោះ “អង្គភាពគាំពារការពារក្ដីនឹងបានចាត់វិធានការហើយ” [140]។ សហមេធាវីដែលត្រូវបានចាត់ តាំង ក៏បញ្ជាក់ថា ស្ថាប័នសមត្ថកិច្ចដោះស្រាយបណ្ដឹងឧទ្ធរណ៍ដែលមានយុត្តាធិការលើបញ្ហាទាក់ទង នឹងទំនាស់ផលប្រយោជន៍ គឺអង្គបុរេជំនុំជម្រះ[141]។

៥៩. សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា នៅក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរ ជាតិ បានសម្រេចថាខ្លួនមានយុត្តាធិការលើទំនាស់ផលប្រយោជន៍របស់មេធាវី ដោយក្នុងដីកាសម្រេច នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកលើយុត្តិសាស្ត្រតុលាការបារាំង ដែលមិនអាចអនុវត្ត បាននៅ អ.វ.ត.ក ហើយយុត្តិសាស្ត្រនោះក៏ពាក់ព័ន្ធនឹងស្ថានភាពមួយដែលខុសពីរឿងក្ដីបច្ចុប្បន្ន[142]។

---

137 *សំណើបន្ទាន់* កថាខណ្ឌ ២។

138 *សំណើបន្ទាន់* កថាខណ្ឌ២៦-២៧៖ “ក្រុមប្រឹក្សាគណៈមេធាវី ត្រូវពិនិត្យ និងដោះស្រាយបញ្ហាទាំងអស់ពាក់ព័ន្ធនឹងការអនុវត្ត វិជ្ជាជីវៈច្បាប់” ដោយដកស្រង់មាត្រា ១៩ នៃ *ច្បាប់ស្ដីពីលក្ខន្តិកៈគណៈមេធាវី ឆ្នាំ ១៩៩៥*។

139 *សំណើបន្ទាន់* កថាខណ្ឌ ៥ និង ២៨។

140 *សំណើបន្ទាន់* កថាខណ្ឌ ២៩។

141 *សំណើបន្ទាន់* ទំព័រ ១ និងកថាខណ្ឌ ២៧ និង ៣១។

142 *សំណើបន្ទាន់* កថាខណ្ឌ ៣០-៣១ និង France, Cour d’Appel de Pau, 1ère Chambre ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៨។

៦០. សហមេធាវីដែលត្រូវបានចាត់តាំង បញ្ជាក់ថា គ្មានរបៀបនីតិវិធីមួយណាដែលបានបង្ហាញដោយសហព្រះរាជអាជ្ញាអន្តរជាតិ អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានយុត្តាធិការលើទំនាស់ផលប្រយោជន៍ឡើយ[143]។ ទាក់ទងនឹងការទទួលយក*សំណើសុំបដិសេធ* ជាបណ្ដឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃវិធានផ្ទៃក្នុង ១១(៦) សហមេធាវីដែលត្រូវបានចាត់តាំង ផ្ដល់ទឡ្ហីករណ៍ថា ដូចដែលសម្រេចដោយអង្គបុរេជំនុំជម្រះ វិធានផ្ទៃក្នុង ៧៤(២) គ្រាន់តែផ្ដល់សិទ្ធិឱ្យសហព្រះរាជអាជ្ញា ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាក់ទងនឹងការស៊ើបអង្កេតព្រហ្មទណ្ឌ និងផ្ដល់ទឡ្ហីករណ៍ទៀតថា វិធានផ្ទៃក្នុង ១១(៦) ផ្ដល់សិទ្ធិឱ្យប្ដឹងឧទ្ធរណ៍ ឱ្យទៅតែចុងចោទណាដែលការអះអាងថាខ្លួនជាជនក្រីក្រត្រូវបានបដិសេធតែប៉ុណ្ណោះ[144]។ ទាក់ទងនឹងលទ្ធភាពទទួលយក*សំណើសុំបដិសេធ* ជា "សំណើសេរី" សហមេធាវីដែលត្រូវបានចាត់តាំង ផ្ដល់ទឡ្ហីករណ៍ថា សហព្រះរាជអាជ្ញា គួរត្រូវបានដាក់កំហិតមិនឱ្យធ្វើសំណើបែបនោះឡើយក្នុងករណីដែលសំណើទាំងនោះមិនជាប់ទាក់ទងនឹងរឿងក្ដី ឬការស៊ើបអង្កេតព្រហ្មទណ្ឌដែលកំពុងបន្តដំណើរការ[145]។

៦១. នៅក្នុងសារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង អង្គភាពគាំពារការពារក្ដី ទទួលបន្ទុកការតែងតាំងមេធាវី ហើយសហចៅក្រមស៊ើបអង្កេត មិនមានយុត្តាធិការបដិសេធការសម្រេចរបស់អង្គភាពគាំពារការពារក្ដីឡើយ[146]។

## V. ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើបន្ទាន់

៦២. នៅក្នុងការឆ្លើយតបរបស់ ក.ស.ព ទៅនឹង*សំណើបន្ទាន់* សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ បញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត អនុវត្ត *"យុត្តាធិការក្នុងការប្ដឹងតវ៉ាបានទាំងស្រុងលើការកំណត់បែបបទរដ្ឋបាលរបស់ផ្នែកគាំពារការពារក្ដី ទាក់ទងនឹងការចាត់តាំងមេធាវីការពារក្ដី"*[147] ។ សហព្រះរាជ

---

[143] *សំណើបន្ទាន់* កថាខណ្ឌ ៣២-៤១។

[144] *សំណើបន្ទាន់* កថាខណ្ឌ ៣៣-៣៦។

[145] *សំណើបន្ទាន់* កថាខណ្ឌ ៣៨ និង៤១។

[146] *សំណើបន្ទាន់* កថាខណ្ឌ ៣៩-៤១។

[147] *ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់* កថាខណ្ឌ ៦-១១។

អាជ្ញាអន្តរជាតិ រំឭកផងដែរថា នៅក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា ខ្លួនមានយុត្តាធិការត្រួតពិនិត្យឡើងវិញលើការជំទាស់ណាមួយផ្អែកលើលទ្ធភាពទំនាស់ផលប្រយោជន៍[148]។ ជាជម្រើសមួយផ្សេងទៀត សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ បញ្ជាក់ថា សហចៅក្រមស៊ើបអង្កេត អនុវត្តសិទ្ធិអំណាចផ្ដាច់មុខលើសំណើដោយសេរី តាមមាត្រា ២១(១)នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ៤២(៣)នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដូចមានចែងបញ្ញត្តិបន្ថែមតាមមាត្រា៦.២ និង ៧.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្ដី[149]។ តាមបទប្បញ្ញត្តិទាំងនេះ ការចុះកិច្ចសន្យា/ការចាត់តាំងសហមេធាវីដែលធ្វើឡើងដោយអង្គភាពគាំពារការពារក្ដី ដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង គឺនៅតែការចុះកិច្ចសន្យា/ការចាត់តាំងបណ្ដោះអាសន្ន ដោយរង់ចាំអង្គភាពគាំពារការពារក្ដី ធ្វើការវាយតម្លៃលើមធ្យោបាយហិរញ្ញវត្ថុ និងដាក់សំណើទៅសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះជាប់ពាក់ព័ន្ធ ដើម្បីចេញ "ដីកាសម្រេចមួយ*បញ្ជាក់* អំពីការចាត់តាំងមេធាវីការពារក្ដីបណ្ដោះអាសន្ន ដើម្បីឱ្យអង្គជំនុំជម្រះវិសាមញ្ញទទួលស្គាល់ថា ខ្លួនក្លាយជាមេធាវីការពារក្ដី ស្របតាមមាត្រា ២១(១)នៃកិច្ចព្រមព្រៀង"[150]។ បន្ថែមពីលើនេះ មាត្រា ៧.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្ដី ទាក់ទងនឹងការដកមេធាវី ចែងថា "អង្គជំនុំជម្រះវិសាមញ្ញអាចសំរេចថា សហមេធាវីអស់សិទ្ធិក្នុងការការពារជនសង្ស័យ ... នៅអង្គជំនុំជម្រះវិសាមញ្ញ" [151] ។

៦៣. ចុងក្រោយបំផុត សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ ជំទាស់ទៅនឹងជំហររបស់សហមេធាវីដែលត្រូវបានចាត់តាំង ដែលថា បញ្ហាទំនាស់ផលប្រយោជន៍អាចត្រូវដោះស្រាយដោយអង្គភាពគាំពារការពារក្ដី និងប្រធានគណៈមេធាវីតែប៉ុណ្ណោះ។ វិធាននីតិវិធីដែលបានបង្កើតនៅថ្នាក់អន្តរជាតិ ចែងអំពី

---

[148] *ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់* កថាខណ្ឌ ៨។

[149] *ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់* កថាខណ្ឌ ១២។

[150] *ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់* កថាខណ្ឌ ១៣ *ដោយដកស្រង់*បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្ដី ត្រង់មាត្រា ៦.២(ខ)(សង្កត់ធ្ងន់)។

[151] *ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់* កថាខណ្ឌ ១៤ ដោយដកស្រង់បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្ដី ត្រង់មាត្រា ៧.៤។

កិច្ចដំណើរការនីតិវិធីស្តីពីទំនាស់ផលប្រយោជន៍[152]។ ដូច្នេះ សហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ ស្នើសហចៅក្រមស៊ើបអង្កេត សុំបដិសេធសំណើបន្ទាន់ និងសុំសម្រេចលើ *សំណើសុំបដិសេធ*[153]។

## VI. ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំងទៅនឹងការឆ្លើយតបទៅនឹងសំណើបន្ទាន់

៦៤. សហមេធាវីដែលត្រូវបានចាត់តាំង ជំទាស់ទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា សហព្រះរាជអន្តរជាតិ មានមូលដ្ឋានដាក់*សំណើសុំបដិសេធ* អនុលោមតាមវិធានផ្ទៃក្នុង ១១ (៦) ដោយសហមេធាវីដែលត្រូវបានចាត់តាំង បានផ្តល់ទឡ្ហីករណ៍ថា វិធានផ្ទៃក្នុងនេះគ្រាន់តែផ្តល់សិទ្ធិឱ្យ ជនដែលអះអាងថាខ្លួនជាជនក្រីក្រ ដើម្បីប្តឹងតវ៉ាប្រឆាំងនឹងសេចក្តីសម្រេចទាក់ទងនឹងការអះអាងរបស់ខ្លួនថាជនក្រីក្រតែប៉ុណ្ណោះ[154]។

៦៥. សហមេធាវីដែលត្រូវបានចាត់តាំង ផ្តល់ទឡ្ហីករណ៍ថែមទៀតថា នៅក្នុងសំណុំរឿង ០០៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា ខ្លួនមានយុត្តាធិការត្រួតពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចណាមួយរបស់សហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Kasper-Ansermet ប៉ុន្តែមិនមែនពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចរបស់អង្គភាពគាំពារការពារក្តីលើការតែងតាំងមេធាវីឡើយ[155]។

៦៦. សហមេធាវីដែលត្រូវបានចាត់តាំង ក៏ជំទាស់ថា សហចៅក្រមស៊ើបអង្កេត មិនមានយុត្តាធិការសម្រេចលើ *សំណើសុំបដិសេធ* អនុលោមតាមវិធានផ្ទៃក្នុង ២១(១)នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ៧.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី។ សហមេធាវីដែលត្រូវបានចាត់តាំង ផ្តល់ទឡ្ហីករណ៍ថា វិធាន ៧.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី ចែងថា "អ.វ.ត.ក" មានអំណាចដកមេធាវី ហើយប្រធាន អ.វ.ត.ក បង្ហាញថា អង្គភាពដែលត្រូវបានផ្តល់នូវអំណាចនេះ គឺ អង្គភាពគាំពារការពារក្តី មិនមែនសហចៅក្រមស៊ើបអង្កេតទេ[156]។

---

[152] *ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់* កថាខណ្ឌ ១៥។

[153] *ការឆ្លើយតបរបស់ ស.ព.អ ទៅនឹងសំណើបន្ទាន់* កថាខណ្ឌ ១៦។

[154] *ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ១-៣ និង ៦-១៣។

[155] *ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៤-៥។

[156] *ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ១៤-១៨។

៦៧. ចុងក្រោយបំផុត បទបញ្ញារដ្ឋបាលរបស់អង្គភាពគាំពារការពារក្ដី ជំទាស់ទៅលើការប្រើប្រាស់ការអនុវត្តអន្តរជាតិដែលមានរួចហើយ ទាក់ទងនឹងបញ្ហាចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍ ពីព្រោះថាបញ្ហានេះត្រូវដាក់កំណត់បញ្ញត្តិរួចហើយដោយវិធានផ្ទៃក្នុង និងបទបញ្ញារដ្ឋបាលរបស់អង្គភាពគាំពារការពារក្ដី ដែលកំណត់ថា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គភាពគាំពារការពារក្ដី គឺជាអង្គភាពមានសមត្ថកិច្ចសម្រេចលើបញ្ហាទាំងនេះ[157]។

## គ. ច្បាប់ជាធរមាន

### I. បទប្បញ្ញត្តិក្របខ័ណ្ឌកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក

៦៨. មាត្រា ១២ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង អ.វ.ត.ក") ចែងថា នីតិវិធីរបស់ អ.វ.ត.ក "ត្រូវសមស្របជាមួយច្បាប់កម្ពុជា" ហើយក្នុងករណីដែលមិនមានចែង "អាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។ បន្ថែមពីលើនេះទៀត អ.វ.ត.ក ត្រូវ "អនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ"។

៦៩. ដូចគ្នានេះដែរ មាត្រា ២៣(ថ្មី)នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងថា ប្រសិនបើ "នីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្ត... សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ"។

---

[157] *ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ១៩-២៣។

## II. បទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង អ.វ.ត.ក ស្តីពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាន មេធាវីតាមជម្រើសរបស់ខ្លួន

៧០. តាមមាត្រា ១៣ នៃកិច្ចព្រមព្រៀង អ.វ.ត.ក ជន "ជាប់ចោទ"នៅចំពោះមុខ អ.វ.ត.ក ត្រូវមានសិទ្ធិ "ជ្រើសរើសរកមេធាវីដោយខ្លួនឯង" អនុលោមតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

៧១. មាត្រា២១(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា"រាជរដ្ឋាភិបាលមិនត្រូវដាក់មេធាវីរបស់ជនសង្ស័យ *[...]* ដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញឲ្យស្ថិតនៅក្រោមវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញតួនាទីដោយសេរី និងឯករាជ្យរបស់ពួកគេ នៅក្រោមកិច្ចព្រមព្រៀងនេ "។

## III. បទបញ្ជារដ្ឋបាលជាប់ពាក់ព័ន្ធរបស់អង្គភាពគាំពារការពារក្តី ស្តីពីការតែងតាំងមេធាវី

៧២. មាត្រា ៦.២(ខ)នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី ចែងថា អង្គភាពគាំពារការពារក្តីត្រូវ *"បញ្ជូនទម្រង់លេខ ៧ ស្តីពីសំណើសុំតែងតាំង/ចាត់តាំងសហមេធាវីទៅចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះពាក់ព័ន្ធ ដើម្បីចេញដីកាយល់ព្រមការចាត់តាំងមេធាវីបណ្តោះអាសន្ន ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញ ទទួលស្គាល់ ដូចកំណត់នៅក្នុងមាត្រា ២១(១)នៃកិច្ចព្រមព្រៀង"* ។

៧៣. មាត្រា ៧.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី បញ្ជាក់ថា ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ អាចដាក់ពាក្យសុំទៅ អ.វ.ត.ក ស្នើផ្លាស់ប្តូរសហមេធាវីទាំងពីរ ឬសហមេធាវីណាម្នាក់ ហើយសំណើសុំផ្លាស់ប្តូរនេះ អាចត្រូវអនុញ្ញាតតែក្នុងកាលៈទេសៈប៉ុណ្ណោះ។ ស្រដៀងគ្នានេះដែរ មាត្រា ៧.៣ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី អនុញ្ញាតឲ្យ សហមេធាវី តែក្នុងកាលៈទេសពិសេសប៉ុណ្ណោះ ធ្វើការដាក់ពាក្យសុំទៅ អ.វ.ត.ក ស្នើសុំដកខ្លួនពីរឿងក្តីដែលខ្លួនត្រូវបានជ្រើសរើសជាប់កិច្ចសន្យា ឬចាត់តាំង។

៧៤. មាត្រា ៧.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី បញ្ជាក់ថា អង្គជំនុំជម្រះវិសាមញ្ញអាចសម្រេចថា សហមេធាវីអស់សិទ្ធិការពារជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទនៅអង្គជំនុំជម្រះវិសាមញ្ញ។

## IV.បទបញ្ញត្តិនៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធានផ្ទៃក្នុងស្តីពីការទទួលខុសត្រូវវិជ្ជាជីវៈរបស់មេធាវី នៅចំពោះមុខអ.វ.ត.ក

៧៥. មាត្រា២១(៣)នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា មេធាវីនៅអ.វ.ត.ក"ត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី បទដ្ឋាននិង សីលធម៌វិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់"។

៧៦. វិធានផ្ទៃក្នុង ២២(៤) នៃ អ.វ.ត.ក ចែងថា " មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និងបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈ ដែលបានទទួលស្គាល់"។

## V. បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី និងបទប្បញ្ញត្តិកម្ពុជាស្តីពីទំនាស់ផលប្រយោជន៍

៧៧. មាត្រា ៩ បទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី ត្រង់ចំណងជើង "ទំនាស់ផលប្រយោជន" ចែងថា៖

*៩.១ សហមេធាវីមិនត្រូវចូលរួមក្នុងសកម្មភាពដែលមានវិសមតិភាពជាមួយការបំពេញតួនាទីជាតំណាងផ្លូវច្បាប់របស់ជនជាប់ចោទឡើយ ។ ជាពិសេស សហមេធាវីមិនត្រូវទទួលសេចក្តីណែនាំពី រដ្ឋាភិបាលណាមួយ ទាក់ទងទៅនឹងកិច្ចការពារជនជាប់ចោទឡើយ ។*

*៩.២ សហមេធាវីត្រូវបំពេញភារកិច្ចដោយប្រុងប្រយ័ត្ន ដើម្បីបញ្ចៀសឲ្យបាននូវជម្លោះផលប្រយោជន៍ ពួកគេត្រូវដំកល់ផលប្រយោជន៍កូនក្តីឲ្យខ្ពស់ជាងផលប្រយោជន៍របស់ខ្លួន ឬផលប្រយោជន៍របស់បុគ្គលណាម្នាក់ អង្គការ ឬរដ្ឋណាមួយ និងគោរពឲ្យបានត្រឹមត្រូវនូវច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង បទបញ្ជារដ្ឋបាលនេះ និងក្រមសីលធម៌ដែលពួកគេប្រតិបត្តិតាម ។*

*៩.៣ នៅពេលមានជម្លោះផលប្រយោជន៍កើតឡើង សហមេធាវីត្រូវជូនដំណឹងជាបន្ទាន់អំពីសក្តានុភាពដែលបះពាល់ដល់កូនក្តី ដែលបណ្តាលមកពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍ ហើយអាចដកខ្លួនចេញពីកិច្ចការពារកូនក្តីម្នាក់ ឬច្រើននាក់ ឬស្វែងរកការយល់ព្រមពេញ*

*លេញ ឬជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីសក្ដានុពលភាព ដែលបានប៉ះពាល់ដល់កូនក្ដី ដើម្បីបន្តការការពារក្ដី ។*

៧៨. មាត្រា ២៥ នៃក្រមសីលធម៌នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចែងពីផ្នែកជាប់ពាក់ព័ន្ធថា៖

*"មេធាវី មិនត្រូវទទួលរឿងក្ដីទាំងឡាយដូចខាងក្រោម៖ [...]*

*នៅពេលដែលផលប្រយោជន៍របស់អតិថិជនម្នាក់ មានទំនាស់ជាមួយផលប្រយោជន៍អតិថិជនម្នាក់ទៀតនៅក្នុងរឿងក្ដីដែលមេធាវី ឬក្រុមមេធាវីរបស់ខ្លួនកំពុងកាន់ [...]*

*ករណីដែលមេធាវី ឬក្រុមមេធាវី ជាទីប្រឹក្សា ឬធ្លាប់ជាទីប្រឹក្សារបស់អតិថិជនច្រើនគ្នានោះ មេធាវីនឹងអាចទទួលការពារប្រយោជន៍ភាគីណាមួយបានលុះត្រាតែត្រូវជម្រាបទៅភាគីឯទៀត និងបន្ទាប់ពីទទួលបានការយល់ព្រមសិន ហើយត្រូវប្រុងប្រយ័ត្នកុំឱ្យបាត់បង់នូវភាពថ្លៃថ្នូរ កិត្តិយស និងការសម្ងាត់វិជ្ជាជីវៈ។*

## ឃ. បញ្ហាបឋម

ក. យុត្តាធិការរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការសម្រេចលើសំណើសុំបដិសេធ និងសេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា

៧៩. ដូចបានចែងនៅក្នុងមាត្រា ១៣ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក និងមាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សិទ្ធិជ្រើសរើសមេធាវី គឺជាសិទ្ធិជាសារវ័ន្តនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ[158]។ ទោះយ៉ាងណា ទោះបីជាសិទ្ធិនេះមានលក្ខណៈជាសារវ័ន្តយ៉ាងណាក៏ដោយ ក៏សិទ្ធិនេះមិនមែនដាច់ខាតដែរ[159]។

---

[158] *សូមមើលផងដែរ រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង* *Mejakić និងអ្នកផ្សេងទៀត* ឯកសារ IT-02-65-AR73.1 *ដីកាសម្រេចលើបណ្ដឹងតវ៉ារបស់រដ្ឋអាជ្ញា ដើម្បីដោះស្រាយទំនាស់ផលប្រយោជន៍ ទាក់ទងនឹងមេធាវី Jovan Simić* ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០០៤("ដីកាសម្រេចលើបណ្ដឹងតវ៉ា *Mejakić* ") កថាខណ្ឌ ៨។

[159] *ដូចជើងទំព័រខាងលើ*។

៨០. អនុលោមតាមមាត្រា ២១(១)នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធាន ៦.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី សហចៅក្រមស៊ើបអង្កេត ត្រូវតែបញ្ជាក់ទៅជនសង្ស័យណាម្នាក់ អំពីការចាត់តាំងមេធាវីបណ្តោះអាសន្នដែលធ្វើឡើងដោយអង្គភាពគាំពារការពារក្តី។ វិធាន ៧.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី ចែងថា អ.វ.ត.ក អាចសម្រេចថា មេធាវីណាម្នាក់ "អស់សិទ្ធិ"ការពារជនសង្ស័យណាម្នាក់។

៨១. លទ្ធភាពអត្ថិភាពនៃទំនាស់ផលប្រយោជន៍ ត្រូវបានទទួលស្គាល់ជាទូទៅដោយបទដ្ឋាន និងការអនុវត្តអន្តរជាតិ ថាជាការរាំងស្ទះមួយដល់តំណាងផ្លូវច្បាប់ [160] រួមមានការរាំងស្ទះដល់ជនសង្ស័យក្នុងការជ្រើសរើសមេធាវីតាមជម្រើសរបស់ខ្លួន[161]។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានបញ្ជាក់ថា៖

> ការការពារប្រយោជន៍យុត្តិធម៌ តម្រូវឲ្យមានការទប់ស្កាត់មិនឲ្យមានទំនាស់ផលប្រយោជន៍ មុនពេលដែលទំនាស់ផលប្រយោជន៍កើតឡើង។ ប្រសិនបើ អង្គជំនុំជម្រះណាមួយ សម្រេចថា ហានិភ័យ និងព្យសនកម្មដែលអាចកើតឡើង [ដោយសារទំនាស់ផលប្រយោជន៍] ឧទាហរណ៍ ត្រូវបំផ្លាញសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីយ៉ាងឆាប់រហ័ស និងប្រកបដោយយុត្តិធម៌ ឬកិច្ចការ

---

[160] *សូមមើល* មាត្រា ១៤ នៃក្រមសីលធម៌មេធាវី នៅចំពោះមុខសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២00៩ ("ក្រមសីលធម៌របស់តុលាការ ICTY")។ មាត្រា ១២ និង ១៦នៃក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២00៥។ មាត្រា ១១ នៃក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីការពារក្តី និងតំណាងផ្លូវច្បាប់របស់ជនរងគ្រោះ នៅចំពោះមុខសាលាក្តីពិសេសសម្រាប់លីបង់(STL) ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២0១២។ មាត្រា ៩ នៃក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីការពារក្តីនៅចំពោះមុខសាលាក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ាវ៉ាន់ដា (ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២00៨ ("ក្រមសីលធម៌របស់តុលាការICTR")។ មាត្រា ១៥ នៃក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីដែលមានសិទ្ធិចូលរួមសវនាការនៅចំពោះមុខតុលាការពិសេសសម្រាប់ស៊ីរ៉ាឡេអូន ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២00៦។ និងវិធាន ១.៧ ដល់ ១.១0 នៃវិធានគំរូសម្រាប់ការអនុវត្តវិជ្ជាជីវៈរបស់គណៈមេធាវីអាមេរិក។

[161] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ante Gotovina និងអ្នកផ្សេងទៀត* ឯកសារ It-06-90-AR73.2 *ដីកាសម្រេចលើបណ្តឹងតវ៉ាបន្ទាន់របស់ Ivan Čermak ប្រឆាំងនឹងទំនាស់ផលប្រយោជន៍របស់មេធាវី Čedo Prodanović និង Jadranka Sloković* ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២00៧ ("ដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina*") កថាខណ្ឌ ៥៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Jadranko Prlić និងអ្នកផ្សេងទៀត* ឯកសារ IT-04-74-AR73.1 *ដីកាសម្រេចលើបណ្តឹងតវ៉ារបស់ Bruno Stojić ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំតែងតាំងមេធាវី* ថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២00៤ ("ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić*") កថាខណ្ឌ ១៩។

រដ្ឋបាលតុលាការត្រឹមត្រូវ នោះ អង្គជំនុំជម្រះចាត់វិធានសមស្របដើម្បីស្តារឡើងវិញ និងការពារភាពយុត្តិធម៌នៃការជំនុំជម្រះក្តី និងភាពសុចរិតនៃកិច្ចដំណើរការនីតិវិធី។ [វិធានការបែបនេះ] អាចរួមមានដីកាសម្រេចឲ្យដកមេធាវី[162]។

៨២. មាត្រា ២៣(ថ្មី)នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចាត់តាំង សហចៅក្រមស៊ើបអង្កេត ឲ្យទទួលខុសត្រូវចំពោះការស៊ើបអង្កេតទាំងអស់។ ការទទួលខុសត្រូវនេះ រួមមានកាតព្វកិច្ចការពារភាពសុចរិតនៃការស៊ើបអង្កេត ហើយធានាឲ្យមានការអនុវត្តបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងដំណើការសមស្របនៃច្បាប់។ កាតព្វកិច្ចនេះ រួមមានការត្រួតពិនិត្យទៅលើការចាត់តាំងមេធាវី[163]។ សហចៅក្រមស៊ើបអង្កេតក៏មានអំណាចរួចជាស្រេចដើម្បីសម្រេចលើបញ្ហាចៃដន្យដែលកើតឡើង ដោយសារលទ្ធផលផ្ទាល់ពីនីតិវិធី ដែលសហចៅក្រមស៊ើបអង្កេត ទទួលបាន ដោយហេតុថាបញ្ហានោះស្ថិតនៅក្រោមយុត្តាធិការបឋមរបស់ខ្លួន[164]។ ស្របតាមកាតព្វកិច្ចនេះ នៅពេលបញ្ជាក់ទៅ

---

[162]ដីកាសម្រេចលើបណ្តឹងតវ៉ា*Gotovina* កថាខណ្ឌ១៦។ *សូមមើលផងដែរ* ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* កថាខណ្ឌ២០ និង ២២។

[163] ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* កថាខណ្ឌ ២១។ តុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Hadžihasanović* ឯកសារ IT-01-47-PT*ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលតុលាការក្នុងការចាត់តាំងលោក Rodney Dixon ជាសហមេធាវី ឲ្យជនជាប់ចោទ Kubura* ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២ ("ដីកាសម្រេច *Hadžihasanović*") កថាខណ្ឌ ១៩, ២១, និង ៥៥។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* *Delić* ឯកសារ IT-04-83-PT *ដីកាសម្រេចលើសំណើសុំត្រួតពិនិត្យឡើងវិញទៅសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលតុលាការ ដែលបញ្ជាក់ថា លោក Stephane Bourgon មិនអាចចាត់តាំងឲ្យតំណាង Rasim Delić* ថ្ងៃទី ១០ ខែ ឧសភា ឆ្នា ២០០៥ ("សេចក្តីសម្រេច*Delić*") ទំព័រ ២។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Popović និងអ្នកផ្សេងទៀត* ឯកសារ IT-05-88-T *ដីកាសម្រេចលើសំណើលើកទីបីសុំពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលតុលាការលើការចាត់តាំងសហមេធាវីតំណាង Radivoje Miletić* ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៧ ទំព័រ ៤។

[164]គោលការណ៍ស្តីពីយុត្តាធិការមានរួចស្រេច ត្រូវបានទទួលស្គាល់ និងអនុវត្តយ៉ាងទូលំទូលាយដោយសាលាក្តីអន្តរជាតិផ្សេងៗ។ ការអនុវត្តគោលការណ៍នេះនៅ អ.វ.ត.ក ក៏ត្រូវបានទទួលស្គាល់ផងដែរតាមរយៈអង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក៖ *ឧទាហរណ៍ សូមមើល* សំណុំរឿង ០០២ ឯកសារD14/1/2 *ដីកាសម្រេចព្យួរការអនុវត្ត "ដីកាសម្រេចស្តីពីសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿង ០០៣"* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៤។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាកា ICTY បានបញ្ជាក់ថា ក្នុងការអនុវត្តអំណាចនេះ អាជ្ញាធរតុលាការណាមួយ អាចមិនយកប្រើជារបស់ខ្លួននូវអំណាចណាមួយដែលត្រូវបានអនុញ្ញាតនៅកន្លែងផ្សេងឡើ។ *សូមមើល* ដីកាសម្រេចលើបណ្តឹងតវ៉ា *Mejakić* កថាខណ្ឌ ៧។

ជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៤ អំពីការតែងតាំងមេធាវី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានវាយតម្លៃជាពិសេសទៅលើលទ្ធភាពអត្ថិភាពនៃទំនាស់ផលប្រយោជន៍[165]។

៨៣. ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធទឡ្ហីករណ៍របស់សហមេធាវីដែលត្រូវបានចាត់តាំងដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានយុត្តាធិការពិចារណាទៅលើ*សំណើសុំបដិសេធ* និងទឡ្ហីករណ៍របស់សហមេធាវីដែលត្រូវបានចាត់តាំងដែលថា បញ្ហាទាក់ទងនឹងទំនាស់ផលប្រយោជន៍របស់សហមេធាវី ត្រូវសម្រេចដោយអង្គភាពគាំពារការពារក្ដី ឬគណៈមេធាវី តែប៉ុណ្ណោះ ហើយនៅពេលប្ដឹងតវ៉ា ត្រូវសម្រេចដោយអង្គបុរេជំនុំជម្រះ។ ទោះជា អង្គភាពគាំពារការពារក្ដី មានការទទួលខុសត្រូវបឋមក្នុងការតែងតាំងមេធាវី ដោយអនុលោមបទបញ្ជាផ្ទៃក្នុង យ៉ាងណាក៏ដោយ ក៏នៅក្នុងច្បាប់អន្តរជាតិ មានមូលដ្ឋានរឹងមាំដែលចែងថា អាជ្ញាធរតុលាការ មានអំណាចត្រួតពិនិត្យលើសេចក្ដីសម្រេចបែបបទរដ្ឋបាល នៅពេលដែលសេចក្ដីសម្រេចនោះអាចប៉ះពាល់ដល់ភាពយុត្តិធម៌នៃការជំនុំជម្រះក្ដី ឬក៏ប៉ះពាល់ដល់កិច្ចការរដ្ឋបាលតុលាការ[166]។

៨៤. ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា *សំណើសុំបដិសេធ* ត្រូវបានទទួលយក។

ខ. សំណើសុំអនុញ្ញាតបន្ថែមចំនួនពាក្យ និងដាក់ឯកសារជាភាសាអង់គ្លេសមុន ហើយដាក់ភាសាខ្មែរនៅតាមក្រោយ

៨៥. ទាំង សហមេធាវីដែលត្រូវបានចាត់តាំង និងសហព្រះរាជអាជ្ញា បានស្នើសុំអនុញ្ញាតបន្ថែមចំនួនពាក្យនៅក្នុង*សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង*[167] *សេចក្ដីសន្និដ្ឋានបន្ថែមរបស់ ស.ព.អ*[168]

[165] សំណុំរឿង ០០៤ ឯកសារ D122/6 *ដីកាសម្រេចលើញត្តិ និងសារណាបន្ថែមស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣ កថាខណ្ឌ ៨២ និង៩៩។

[166] *សូមមើលជើងទំព័រខាងលើលេខ* 153 ។

[167] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* ទំព័រ ១។

[168] *សេចក្ដីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា* កថាខណ្ឌ ៦។

*សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង*[169] *ចម្លើយតបរបស់របស់សហមេធាវីដែលត្រូវបានចាត់តាំង*[170]។

៨៦. ដោយអនុលោមតាមមាត្រា ៥.៤ នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក ចំនួនទំព័រកំណត់ដាក់ឯកសារ អាចបន្ថែមបានក្នុងករណី "ពិសេស"។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាទៅលើភាពស្មុគស្មាញនៃបញ្ហាទាក់ទងនឹងការបង្ហាញទឡ្ហីករណ៍ ពិចារណាទៅលើកង្វះខាតបទបញ្ញាតិចែងពីការដកមេធាវី ក្នុងករណីមានទំនាស់ផលប្រយោជន៍ នៅក្នុងវិធានផ្ទៃក្នុង និងតម្រូវការស្វែងរកការអនុវត្ត និងបទដ្ឋានអន្តរជាតិស្តីពីបញ្ហានេះ និងចុងក្រោយ ពិចារណាទៅលើភាពសំខាន់នៃបញ្ហានេះសម្រាប់ជនសង្ស័យ និងកិច្ចការរដ្ឋបាលតុលាការត្រឹមត្រូវ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថា កត្តាទាំងនេះបង្កើតឲ្យមានកាលៈទេសៈពិសេស ហើយអនុញ្ញាតឲ្យបន្ថែមចំនួនទំព័រ។

៨៧. សហព្រះរាជអាជ្ញា និងសហមេធាវីដែលត្រូវបានចាត់តាំង ក៏បានស្នើសុំអនុញ្ញាតដាក់ទឡ្ហីករណ៍របស់ខ្លួនជាភាសាអង់គ្លេសមុន ហើយដាក់ភាសាខ្មែរនៅតាមក្រោយ[171]។ ដោយពិចារណាទៅលើភាពសំខាន់នៃបញ្ហាជម្លោះផ្លូវច្បាប់ឲ្យបានឆាប់បំផុតតាមការជាក់ស្តែងក្នុងគោលបំណងដើម្បីរក្សាសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុញ្ញាតតាមមាត្រា ៧.២ នៃសេចក្តីណែនាំអនុវត្តន៍ ឲ្យដាក់ឯកសារជាភាសាអង់គ្លេសមុន ហើយដាក់ភាសាខ្មែរនៅតាមក្រោយ។

---

[169] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* ទំព័រ ១។

[170] *ការឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* ទំព័រ ១។

[171] *សំណុំសុំបដិសេធ* កថាខណ្ឌ ៧។ *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* ទំព័រ ១។ *សេចក្តីសន្និដ្ឋានបន្ថែមរបស់សហព្រះរាជអាជ្ញា* កថាខណ្ឌ ៥។ *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* ទំព័រ ១។

# ខ. ការចោទប្រកាន់អំពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន

## I. ការត្រួតពិនិត្យលើការចោទប្រកាន់អំពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍

៨៨. កិច្ចព្រមព្រៀង អ.វ.ត.ក និងវិធានផ្ទៃក្នុង មានបទប្បញ្ញត្តិទូទៅ ដែលតម្រូវឲ្យមេធាវី អនុវត្តតាមដូចជា បទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈច្បាប់ដែលត្រូវបានទទួលស្គាល់[172] ។ មាត្រា ៩ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី និងមាត្រា ២៥ នៃក្រមសីលធម៌របស់គណៈមេធាវី ចែងពីកាតព្វកិច្ចរបស់មេធាវី ក្នុងករណីមានទំនាស់ផលប្រយោជន៍ ប៉ុន្តែមិនមានចែងអំពីការដកមេធាវីដែលមានទំនាស់ផលប្រយោជន៍ដែលធ្វើឡើងដោយអាជ្ញាធរតុលាការដែលទទួលបន្ទុកធានាឲ្យមានភាពយុត្តិធម៌ និងភាពសុចរិតនៃកិច្ចដំណើរការនីតិវិធីឡើយ។ ដូច្នេះ នៅក្នុងការវិភាគបញ្ហាដែលបានបង្ហាញដោយ*សំណើសុំបដិសេធ* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នឹងស្វែងរកការណែនាំនៅក្នុងវិធាននីតិវិធីដែលមាននៅថ្នាក់អន្តរជាតិ ហើយពិចារណាទៅលើយុត្តិសាស្ត្រជាតិ និងអន្តរជាតិដែលជាប់ពាក់ព័ន្ធ[173]។

ក. និយមន័យអំពីទំនាស់ផលប្រយោជន៍

៨៩. និយមន័យអំពីអ្វីដែលបង្កើតឲ្យទំនាស់ផលប្រយោជន៍ មានលក្ខណៈខុសគ្នាពីយុត្តាធិការមួយ ទៅយុត្តាធិការមួយ។ ទោះយ៉ាងណា ជាទូទៅ វិធានប្រឆាំងនឹងទំនាស់ផលប្រយោជន៍ មានគោលបំណងការពារទំនាក់ទំនងជាប់កិច្ចសន្យារវាងមេធាវី ជាមួយកូនក្តីបច្ចុប្បន្ន និងកូនក្តីពីមុនរបស់ខ្លួន ហើយធានាថានៅពេលដែលតំណាងឲ្យកូនក្តី មេធាវី មិនមានការរាំងស្ទះក្នុងការស្វះស្វែងរកដាច់ខាតនូវប្រយោជន៍ល្អបំផុតឲ្យកូនក្តី។

---

[172] *សូមមើល* មាត្រា ២១(៣)នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងវិធានផ្ទៃក្នុង ២២(៤)។

[173] មាត្រា ១២ នៃកិច្ចព្រមព្រៀង អ.វ.ត.ក និងមាត្រា ២៣(ថ្មី)នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

៩០. ឧទាហរណ៍ យោងតាមគោលការណ៍អន្តរជាតិសម្រាប់ការអនុវត្តវិជ្ជាជីវៈច្បាប់អនុម័តដោយគណៈមេធាវីអន្តរជាតិ បានឱ្យដឹងថា ជាគោលការណ៍រួម មេធាវីមិនអាចកាន់តំណែងមួយដែលប្រយោជន៍របស់កូនក្ដីណាម្នាក់ មានទំនាស់ជាមួយនឹងប្រយោជន៍របស់ខ្លួន ឬប្រយោជន៍របស់កូនក្ដីបច្ចុប្បន្ន និងពីមុន ប្រសិនបើកូនក្ដីដែលជាប់ពាក់ព័ន្ធ មិនយល់ព្រមជាមួយនឹងការតំណាងបែបនោះ ក្នុងករណីដែលអនុញ្ញាតឱ្យមានយល់ព្រមបែបនោះក៏ដោយ[174]។ ក្រមសីលធម៌មេធាវី នៅរដ្ឋអង់គ្លេស និងវែលស៍ ចែងថា " *ទំនាស់ផលប្រយោជន៍កើតឡើងនៅពេលដែល "ករណីយកិច្ចដាច់ដោយឡែករបស់ [មេធាវី]ខ្លួនឯងផ្ទាល់ដែលត្រូវអនុវត្តដើម្បីជាប្រយោជន៍ល្អបំផុតសម្រាប់កូនក្ដីពីរនាក់ ឬច្រើននាក់ទាក់ទងនឹងបញ្ហាដូចគ្នា ឬជាប់ពាក់ព័ន្ធគ្នា ហើយករណីយកិច្ចទាំងនោះ មានទំនាស់ ឬក៏មានហានិភ័យខ្លាំងដែលថាករណីយកិច្ចទាំងនោះអាចមានទំនាស់*" [175]។

៩១. ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវីអនុវត្តនៅចំពោះមុខតុលាការ ICTY និង ICTR មាននិយមន័យលម្អិតអំពីទំនាស់ផលប្រយោជន៍ ដែលបញ្ជាក់ថានឹងកើតឡើង៖

- នៅពេលដែលការតំណាងឱ្យកូនក្ដីណាម្នាក់ នឹងត្រូវ ឬអាចព្យាករណ៍ជាមុនដោយសមហេតុផលថានឹងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការតំណាងឱ្យកូនក្ដីម្នាក់ផ្សេងទៀត។
- នៅពេលដែលការតំណាងឱ្យកូនក្ដីម្នាក់ផ្សេងទៀត នឹងត្រូវ ឬអាចព្យាករណ៍ជាមុនដោយសមហេតុផលថានឹងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការតំណាងបែបនោះ។
- នៅពេលដែលបញ្ហាដូចគ្នា ឬជាប់ពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងបញ្ហាផ្សេងទៀត ក្នុងនោះ មេធាវីធ្លាប់តំណាងឱ្យកូនក្ដីម្នាក់ផ្សេងទៀត ហើយផលប្រយោជន៍របស់កូនក្ដីបច្ចុប្បន្ន គឺផ្ទុយស្រឡះជាសត្យានុម័តទៅនឹងផលប្រយោជន៍របស់កូនក្ដីមុន។

---

[174] *សូមមើល* កថាខណ្ឌ ៣ នៃខ្លឹមសារគោលការណ៍របស់គណៈមេធាវីអន្តរជាតិ៖ គោលការណ៍របស់គណៈមេធាវីអន្តរជាតិពិចារណាទៅលើវិធានវិជ្ជាជីវៈជាតិរបស់រដ្ឋនានានៅទូទាំងពិភពលោក គោលការណ៍ជាមូលដ្ឋានស្ដីពីតួនាទីរបស់មេធាវី ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី ៨ ស្ដីពីការទប់ស្កាត់ឧក្រិដ្ឋកម្ម និងការប្រព្រឹត្តទៅលើជនល្មើស ធ្វើឡើងនៅហាវ៉ាណា (គុយបា) ថ្ងៃទី ២៧ ខែ សីហា ដល់ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩០ និងសេចក្ដីប្រកាសសកលស្ដីពីសិទ្ធិមនុស្ស *សូមមើល* ខ្លឹមសារគោលការណ៍របស់គណៈមេធាវីអន្តរជាតិ សេចក្ដីផ្ដើម កថាខណ្ឌ ២-៤។

[175] សិទ្ធិអំណាចបទបញ្ជារបស់មេធាវី ក្រមសីលធម៌ ឆ្នាំ ២០១១ សន្ទានុក្រម។

- ឬនៅពេលដែលការវិនិច្ឆ័យវិជ្ជាជីវៈរបស់មេធាវី តាងនាមឱ្យកូនក្តី នឹងត្រូវ ឬអាចព្យាករណ៍ជាមុនដោយសមហេតុផលថានឹងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារ ដូចជា ការទទួលខុសត្រូវរបស់មេធាវីចំពោះភាគីទីបី ឬដោយសារផលប្រយោជន៍ខាងភាគីទីបី[176]។

៩២. យោងតាមយុត្តិសាស្ត្ររបស់តុលាការ ICTY ទំនាស់ផលប្រយោជន៍រវាងមេធាវី និងកូនក្តី កើតឡើងនៅពេលដែលការតំណាងឱ្យកូនក្តីប៉ះពាល់ ឬអាចប៉ះពាល់ដល់ប្រយោជន៍របស់កូនក្តីបច្ចុប្បន្ន ឬកូនក្តីពីមុន និងនៅពេលដែលការតំណាងនេះអាចប៉ះពាល់ដល់ប្រយោជន៍យុត្តិធម៌កាន់តែខ្លាំងថែមទៀត ដោយហេតុផលកាលៈទេសៈមួយចំនួន[177]។

ខ.ករណីយកិច្ចរក្សាការសម្ងាត់ និងភាពស្មោះត្រង់របស់មេធាវី

៩៣. នៅពេលដែលតំណាងកូនក្តីណាម្នាក់ មេធាវីត្រូវតម្រូវឱ្យចាត់ទុកប្រយោជន៍របស់កូនក្តីនោះ សំខាន់លើសលុប ហើយគ្មានឥទ្ធិពលណាដែលអាចមានទំនាស់ជាមួយនឹងប្រយោជន៍ល្អបំផុតរបស់កូនក្តីឡើយ[178]។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានបញ្ជាក់ថា មេធាវី គប្បីអាចផ្តល់យោបល់ប្រឹក្សា និងតំណាងឱ្យកូនក្តី "*ដោយគ្មានការរឹតត្បិត ឥទ្ធិពល សម្ពាធ ឬក្រោមការជ្រៀតជ្រែកពីប្រភពណាឡើយ*"[179]។

៩៤. កាតព្វកិច្ចរបស់មេធាវីចំពោះកូនក្តី រួមមានករណីយកិច្ចរក្សាភាពស្មោះត្រង់ និងការសម្ងាត់[180]។ ករណីយកិច្ចទាំងនេះ អនុវត្តចំពោះអតីតកូនក្តី និងកូនក្តីបច្ចុប្បន្ន[181]។ សហមេធាវីដែលត្រូវបាន

---

[176] មាត្រា ១៤ នៃក្រមសីលធម៌របស់តុលាការ ICTY និងមាត្រា ៩ នៃក្រមសីលធម៌របស់តុលាការ ICTR។

[177] ដីកាសម្រេចលើបណ្តឹងតវ៉ា*Prlić* កថាខណ្ឌ ២២ និងដីកាសម្រេច*Delić* ទំព័រ ៣។

[178] *សូមមើល* ដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina* កថាខណ្ឌ ២៨។ ខ្លឹមសារនៃគោលការណ៍អន្តរជាតិស្តីពីការអនុវត្តសម្រាប់វិជ្ជាជីវៈច្បាប់ គណៈមេធាវីអន្តរជាតិ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១១( "គោលការណ៍គណៈមេធាវីអន្តរជាតិ") កថាខណ្ឌ ១.២ និង ៣.២។

[179] គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ *មតិយោបល់រួមលេខ ៣២* ឯកសារ UN Doc CCPR/C/GC/32 កថាខណ្ឌ ៣៤។

[180] ក្រមសីលធម៌របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១២ មាត្រា ៧។ ដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina* កថាខណ្ឌ ៤៤-៤៦ និង ៤៨។ ខ្លឹមសារគោលការណ៍របស់គណៈមេធាវីអន្តរជាតិ កថាខណ្ឌ ៣.២។

ចាត់តាំង យល់ស្របថា ខ្លួនត្រូវរក្សាករណីយកិច្ចរក្សាភាពស្មោះត្រង់ និងការសម្ងាត់ឲ្យអៀង សារី និង មាស មុត[182]។

៩៥. អត្ថិភាពនៃករណីយកិច្ចរបស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការរក្សាភាពស្មោះត្រង់ និង ការសម្ងាត់ឲ្យអៀង សារី គឺស្របនឹងគោលការណ៍ដែលសង្កត់ធ្ងន់លើទំនាក់ទំនងជាប់កិច្ចសន្យារវាង មេធាវីម្នាក់ជាមួយកូនក្តី។ វាក៏ស្របនឹងយុត្តិសាស្ត្ររឿងក្តីរបស់សហរដ្ឋអាមេរិក ដែលយោងតាម យុត្តិសាស្ត្រនេះ ករណីយកិច្ចទាំងនេះនៅតែមានអត្ថិភាពក្រោយពីមរណភាពរបស់អៀង សារី [183]

---

[181] ដីកាសម្រេចលើបណ្តឹងតវ៉ា*Gotovina* កថាខណ្ឌ ៥៤-៥៦។ ប្រទេសអូស្ត្រាលី តុលាការកំពូល Victoria រឿងក្តី *Spincode Pty Ltd តទល់នឹង Look Software Pty Ltd & Ors* ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០១ ឯកសារ [2001] *VSCA* 248 កថាខណ្ឌ ៥៩ និង កថាខណ្ឌបន្ទាប់។ ចក្រភពអង់គ្លេស ព្រឹទ្ធសភា/តុលាការកំពូល រឿងក្តី ព្រះអង្គម្ចាស់ *Jefri Bolkiah តទល់នឹង KPMG* ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ Lord Hope of Craighead។ សហរដ្ឋអាមេរិក តុលាការកំពូល រឿងក្តី*Swidler & Berlin និង James Hamilton តទល់នឹងសហរដ្ឋអាមេរិក* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៨ ឯកសារ 524 *U.S.* 399 (1998) ទំព័រ ៤០០ និងទំព័រ បន្ទាប់។ សហរដ្ឋអាមេរិក សាលាឧទ្ធរណ៍ ស្រុកលេខ២ តំបន់៥ រដ្ឋកាលីហ្វរញ៉ា រឿងក្តី*Goldstein* តទល់នឹង *Lees* ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៧៥ ឯកសារ 46 *Cal.App.3d* 614 (1975) ទំព័រ ៦២០។ *សូមមើលផងដែរ* កថាខណ្ឌ ៤ នៃខ្លឹមសារ គោលការណ៍របស់គណៈមេធាវីអន្តរជាតិ ដែលចែងថា ជាធម្មតា កាតព្វកិច្ចរក្សាការសម្ងាត់គ្មានពេលកំណត់ និងនៅបន្តមាន ក្រោយពីការបញ្ចប់ទំនាក់ទំនងរវាងមេធាវី និងកូនក្តី។

[182] *សារណាឆ្លើយតបរបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ១៦។

[183]យោងតាមគណៈកម្មការគោលនយោបាយផ្តន្ទាទោសរបស់សហរដ្ឋអាមេរិក(USSC) *"ការដឹងថា ការប្រាស្រ័យទាក់ទងនឹងនៅតែ រក្សាការសម្ងាត់ទោះបីជាក្រោយពីមរណភាពក៏ដោយ គឺជំរុញទឹកចិត្តកូនក្តី ឲ្យធ្វើការប្រាស្រ័យទាក់ទងយ៉ាងពេញលេញ និងដោយ ស្មោះត្រង់ជាមួយនឹងមេធាវី។ ការភ័យខ្លាចអំពីការលាតត្រដាងព័ត៌មាន ហើយការទប់ស្កាត់មិនឲ្យមេធាវីលាតត្រដាងព័ត៌មាន អាច ត្រូវបានកាត់បន្ថយប្រសិនបើការលាតត្រដាងព័ត៌មាន ត្រូវដាក់កំហិតនៅត្រឹមការលាតត្រដាងព័ត៌មានក្រោយមរណភាពទើបអាច ធ្វើបាននៅក្នុងបរិបទព្រហ្មទណ្ឌ ទោះយ៉ាងណា ហាក់ដូចជាមិនសមហេតុផលដែលសន្មតថា បាត់មានការភ័យខ្លាច និង ការទប់ស្កាត់បែបនេះទាំងអស់ក្រោយពីមរណភាពរបស់កូនក្តី។ កូនក្តីអាចព្រួយបារម្ភអំពីកេរ្តិ៍ឈ្មោះ ការទទួលខុសត្រូវរដ្ឋប្បវេណី ឬព្យសនកម្មដែលអាចកើតដល់មិត្តភក្តិ ឬគ្រួសារ។ ការលាតត្រដាងព័ត៌មានប្រាស្រ័យទាក់ទងបែបនេះក្រោយមរណភាព អាចមាន ការភ័យខ្លាចដូចការលាតត្រដាងព័ត៌មាននៅពេលដែលកូនក្តីនៅរស់ដែរ"*។ (សហរដ្ឋអាមេរិក តុលាការកំពូល រឿងក្តី *Swidler & Berlin និង James Hamilton តទល់នឹងសហរដ្ឋអាមេរិក* ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៨ ឯកសារ 524 U.S. 399 (1998)) ។ ទាក់ទងនឹងករណីយកិច្ចរក្សាភាពស្មោះត្រង់ តុលាការកំពូលរបស់រដ្ឋ Illinois បានបញ្ជាក់ថា "ច្បាស់ណាស់ មរណភាពរបស់កូនក្តី ណាម្នាក់ មិនលុបបំបាត់ករណីយកិច្ចរក្សាភាពស្មោះត្រង់របស់មេធាវីឡើយ។ កូនក្តីក៏មិនឲ្យមេធាវី មានសេរីភាពតំណាងឲ្យ ប្រយោជន៍ដែលផ្ទុយពីកូនក្តីដែរ"។ (តុលាការកំពូលរបស់រដ្ឋ Illinois រឿងក្តី *In re Williams* ឯកសារ 57 Ill.2d 63, 67 (1974) និងរឿងក្តី *In re Michal* ឯកសារ 415 Ill. 150, 112 N.E.2d 603)។

ហើយក៏ស្របនឹងយុត្តិសាស្ត្ររបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប និងតុលាការជាតិផ្សេងទៀត ដែលយោងតាមយុត្តិសាស្ត្រទាំងនេះ ក្រោយពីមរណភាព មនុស្សនៅតែមានសិទ្ធិរក្សាកេរ្តិ៍ឈ្មោះ និងភាពថ្លៃថ្នូររបស់ខ្លួន ហើយសិទ្ធិទាំងនេះបន្តទៅទាយាទរបស់អ្នកស្លាប់[184]។

គ. បទដ្ឋានជាធរមានសម្រាប់ត្រួតពិនិត្យលើការចោទប្រកាន់អំពីទំនាស់ផលប្រយោជន៍

៩៦. ករណីយកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងការធានាឱ្យមានតំណាងផ្លូវច្បាប់ដោយគ្មានទំនាស់ និងការពារភាពសុចរិតនៃកិច្ចដំណើរការនីតិវិធី គឺមានតាំងពីពេលចាប់ផ្តើមការស៊ើបអង្កេតមកម្ល៉េះ[185]។ កិច្ចការពារប្រយោជន៍យុត្តិធម៌ តម្រូវឱ្យមាន *"មិនត្រឹមតែអត្ថិភាពនៃយន្តការលុបបំបាត់ទំនាស់ផលប្រយោជន៍ក្រោយពីទំនាស់ផលប្រយោជន៍កើតឡើងឡើយ ប៉ុន្តែក៏តម្រូវឱ្យមានការទប់ស្កាត់មិនឱ្យមានទំនាស់បែបនេះមុនពេលដែលទំនាស់បែបនេះកើតឡើងដែរ"* [186]។

៩៧. យោងតាមអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានឱ្យដឹងថា នៅដំណាក់កាលបុរេជំនុំជម្រះ នៅពេលដែលមានការយល់ឃើញជាមុនដោយសមហេតុផលថាទំនាស់ផលប្រយោជន៍អាចកើតឡើង ដោយខុសពីការស្មានតែមួយមុខនោះ ការយល់ឃើញជាមុននេះគឺជាមូលដ្ឋានគ្រប់គ្រាន់មិនអនុញ្ញាតឱ្យមានតំណាងផ្លូវច្បាប់(តេស្តពិនិត្យអំពីការយល់ឃើញជាមុនដោយសមហេតុផល)[187]។ បទដ្ឋាននេះ គឺស្របជាមួយនឹងភាសាដែលប្រើប្រាស់នៅក្នុងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មេធាវី ដែលអនុវត្តនៅចំពោះមុខតុលាការ ICTY និង ICTR[188]។

---

[184] តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី *Editions Plon តទល់នឹងបារាំង* ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៤ ឯកសារ no. 58148/00 កថាខណ្ឌ ៣៤។ តុលាការជាតិផ្សេងៗ បញ្ជាក់ពីវិធីដោះស្រាយនេះ៖ *សូមមើល* ប្រទេសអាល្លឺម៉ង់ តុលាការរដ្ឋធម្មនុញ្ញសហព័ន្ធ រឿងក្តី Mephisto ឯកសារ BVerfGE 30, 173 ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៧១ និងរឿងក្តី Marlene Dietrich ឯកសារ BGH 1 ZR 49/97 ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៩៩៩ ទំព័រ ៦។ ប្រទេសបារាំង, Cass. Civ. 1ère, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៩។ ប្រទេសបារាំង, Cass. Civ. 1ère, ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០១០ ឯកសារ no 09-15.479 ។

[185] ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* សេចក្តីប្រកាស កថាខណ្ឌ ៣។

[186] ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* កថាខណ្ឌ ២៥។

[187] ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* សេចក្តីប្រកាស កថាខណ្ឌ ២។ ដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina* កថាខណ្ឌ ២៣។

[188] *សូមមើល* ក្រមសីលធម៌របស់តុលាការ ICTY មាត្រា ១៤(ឃ) និងតុលាការ ICTR ក្រមសីលធម៌ស្តីពីការអនុវត្តវិជ្ជាជីវៈសម្រាប់មេធាវីការពារក្តី មាត្រា ៩(៣)។

៩៨. សហមេធាវីដែលត្រូវបានចាត់តាំង ហាក់ដូចជាជំទាស់ទៅនឹងការអនុវត្តតេស្តពិនិត្យលើការយល់ឃើញជាមុនដោយសមហេតុផល ហើយនៅក្នុងការជំទាស់នេះ សហមេធាវីដែលត្រូវបានចាត់តាំងពឹងផ្អែកលើសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តី *Hadžiasanović* នៅតុលាការ ICTY ។ នៅក្នុងសេចក្តីសម្រេច *Hadžiasanović* អង្គជំនុំជម្រះសាលាដំបូង បានអនុវត្តបទដ្ឋាន "លទ្ធភាពជាក់ស្តែង"ក្នុងការវាយតម្លៃថាតើអតីតនិយោជិតម្នាក់នៃការិយាល័យរដ្ឋអាជ្ញារបស់តុលាការ ICTY មាន ឬក៏មិនមានទំនាស់ផលប្រយោជន៍ក្នុងការតំណាងឱ្យជនជាប់ចោទម្នាក់នៅចំពោះមុខតុលាការ ICTY [189]។ ទោះយ៉ាងណា បទដ្ឋាន "លទ្ធភាពជាក់ស្តែង"ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងក្រមសីលធម៌របស់តុលាការ ICTY សម្រាប់ទំនាស់ផលប្រយោជន៍របស់អតីតសមាជិកបុគ្គលិក ឬមន្ត្រីនៃតុលាការ ICTY ដែលក្នុងអំឡុងពេលការងាររបស់ខ្លួន បានចូលរួមដោយផ្ទាល់និងយ៉ាងច្រើននៅក្នុងបញ្ហាទាក់ទងនឹងរឿងក្តី ដែលខ្លួនមានបំណងធ្វើជាមេធាវីការពារក្តី[190]។ បទដ្ឋាននេះមិនអនុវត្តចំពោះទំនាស់ផលប្រយោជន៍របស់មេធាវីការពារក្តី ដែលកើតចេញពីការតំណាងឱ្យកូនក្តីម្នាក់ក្នុងពេលដំណាលគ្នា ឬធ្លាប់តំណាងឱ្យកូនក្តីម្នាក់ទៀតឡើយ។

៩៩. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថា នៅដំណាក់កាលស៊ើបអង្កេតនៃកិច្ចដំណើរការនីតិវិធី តេស្តពិនិត្យលើការយល់ឃើញជាមុនដោយសមហេតុផល គឺដោះស្រាយបានយ៉ាងសមស្របចំពោះតម្រូវការធានាឱ្យមានភាពយុត្តិធម៌ខាងកិច្ចដំណើរការនីតិវិធី និងទប់ស្កាត់មិនឱ្យមានទំនាស់ផលប្រយោជន៍មុនពេលដែលទំនាស់ផលប្រយោជន៍កើតឡើង[191]។

---

[189] ដីកាសម្រេច*Hadžihasanović* កថាខណ្ឌ ៥៣-៥៤។

[190] មាត្រា ១៤(គ)នៃក្រមសីលធម៌របស់តុលាការ ICTY។

[191] *សូមមើល* តុលាការ ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Gotovina និងអ្នកផ្សេងទៀត* ឯកសារ IT-06-90-AR73.2 *ដីកាសម្រេចលើបណ្តឹងតវ៉ាបន្ទាន់របស់ Ivan Čermak ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើទំនាស់ផលប្រយោជន៍របស់មេធាវី Čedo Prodanović និង Jadranka Sloković* ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៧ ("ដីកាសម្រេចលើបណ្តឹងតវ៉ា*Gotovina* ") កថាខណ្ឌ ១៦ និង ២៨។ *សូមមើលផងដែរ* ដីកាសម្រេច *Hadžihasanović* កថាខណ្ឌ ៤៥។

00968719



## II. ការចោទប្រកាន់អំពីអត្ថិភាពនៃទំនាក់ទំនងអង្គហេតុរវាង ការចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ និងដីកាចោទប្រកាន់ប្រឆាំងនឹងអៀង សារី

ក. តួនាទីរបស់ជនសង្ស័យ និងអៀង សារី ជាប់ពាក់ព័ន្ធនឹងដីកាបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ

១០០. ជនសង្ស័យ ត្រូវបានចោទប្រកាន់ថាជាលេខាកងពលលេខ ១៦៤ នៃកងទ័ពបដិវត្តន៍កម្ពុជា(ក.ប.ក) យ៉ាងហោចណាស់រវាងខែ មករា ឆ្នាំ ១៩៧៦ ដល់ខែ មេសា ឆ្នាំ ១៩៧៨ ហើយអាចពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មករា ឆ្នាំ ១៩៧៩[192]។ កងពលលេខ ១៦៤ ត្រូវបានចោទថារាយការណ៍ទៅសេនាធិការនៃ ក.ប.ក ដោយមាន សុន សេន ជាប្រធាន[193] ដែលជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍[194]។ បន្ថែមពីលើនេះ ជនសង្ស័យត្រូវបានចោទថាជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") ដែលជាហេតុការណ៍មួយត្រូវបានបញ្ជាក់ដោយ ខៀវ សំផន នៅក្នុងបទសម្ភាសន៍មួយជាមួយនឹងសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២[195]។ ការទទួលខុសត្រូវផ្នែកនយោបាយរបស់ជនសង្ស័យ ត្រូវបានចោទថារួមមានដូចជា ការអនុវត្តមាគ៌ាបក្សរបស់ ប.ក.ក នៅទូទាំងប្រទេស និងបញ្ជាឲ្យគណៈកម្មាធិការភូមិភាគ និងតំបន់ អនុវត្តសកម្មភាពស្របតាមមាគ៌ាបក្ស[196]។

១០១. យោងតាម ដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០២ បានឲ្យដឹងថា អៀង សារី គឺជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេស នៅរបបកម្ពុជាប្រជាធិបតេយ្យ និងជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក។ គាត់ក៏ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលក្នុងនេះ គាត់មាន"ឋានៈជាសមាជិកពេញសិទ្ធិ" [197] ។ ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ ចាត់ទុកគណៈកម្មាធិការអចិន្ត្រៃយ៍ ជាអង្គការមួយ"មានសមាសភាពដែលសុទ្ធតែជាថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៃបក្ស

---

[192] *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ* កថាខណ្ឌ ៨២។

[193] *ដីកាដំណោះស្រាយ* កថាខណ្ឌ ១២៥។

[194] *ដីកាដំណោះស្រាយ* កថាខណ្ឌ ៥៣។

[195] *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ* កថាខណ្ឌ ៨៣ និងសំណុំរឿង ០០៣ ឯកសារD1.3.33.15 កថាខណ្ឌ *កំណត់ហេតុនៃការស្តាប់ចម្លើយជនត្រូវចោទ (ខៀវ សំផន)* ទំព័រ ១១។

[196] *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ* កថាខណ្ឌ ៨៣។

[197] *ដីកាដំណោះស្រាយ* កថាខណ្ឌ ៥៣, ១០០១-១០០៤ និង ១១២៥។

កុម្មុយនីស្តកម្ពុជា” ហើយនៅក្នុងអង្គការនេះ អំណាចជាក់ស្តែង និងកិច្ចការគ្រប់គ្រងប្រចាំថ្ងៃរបស់ ប.ក.ក ត្រូវបានអនុវត្ត[198]។ យោងតាមដីកាដំណោះស្រាយនេះ ប.ក.ក ពឹងផ្អែកលើប្រព័ន្ធ “ដឹកនាំសមូហភាព” ដោយផ្អែកលើគោលការណ៍ “ប្រជាធិបតេយ្យប្រមូលផ្តុំ” មានន័យថា នៅថ្នាក់គណៈកម្មាធិការ សេចក្តីសម្រេចត្រូវធ្វើឡើងជារួម មិនមែនដោយសមាជិកម្នាក់ឡើយ[199]។ សមាជិកពេញសិទ្ធិ មានសិទ្ធិពិចារណា ពិភាក្សា និងចូលរួមធ្វើសេចក្តីសម្រេច “ក្នុងគ្រប់វិស័យទាំងអស់” [200]។ យោងតាមសាក្សីអ្នកជំនាញឈ្មោះDavid Chandler នៅក្នុងសំណុំរឿង០០២ បានឲ្យដឹងថា កំណត់ហេតុនៃអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ពិតជាបានបញ្ជូនទៅសមាជិកទាំងអស់នៃគណៈកម្មាធិការនេះ[201]។

ខ. ភាពត្រួតស៊ីគ្នារវាងរឿងក្តីប្រឆាំងនឹងជនសង្ស័យ និងអៀង សារី

i. ភាពត្រួតស៊ីគ្នានៅក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទ

១០២. ការត្រួតពិនិត្យទៅលើដីកាបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ និងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ បង្ហាញពីភាពត្រួតស៊ីគ្នាសត្យានុម័តនៅក្នុងការចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ និងអៀង សារី។ ជនសង្ស័យ ត្រូវបានចោទថាទទួលខុសត្រូវចំពោះការបោសសម្អាតកម្មាភិបាលកងពលលេខ ១៦៤ និងការចាប់ខ្លួន ហើយបញ្ជូនពួកគេទៅ ស-២១ រួមជាមួយនឹងជនជាតិវៀតណាម ថៃ និងជនបរទេសផ្សេងទៀតដែលចាប់បានដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ។ អៀង សារី ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ដូចជា ពីបទឧក្រិដ្ឋប្រព្រឹត្តនៅ ស-២១[202]។ ជនសង្ស័យ ក៏ត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅព្រលានយន្តហោះកំពង់ឆ្នាំង និងឧក្រិដ្ឋកម្មប្រព្រឹត្តនៅក្នុងអំឡុងពេលវាយប្រហារចូលដែនដីវៀតណាម ដែលបានអនុវត្តដោយកងពលលេខ ១៦៤

---

[198] *ដីកាដំណោះស្រាយ* កថាខណ្ឌ ៤១។

[199] *ដីកាដំណោះស្រាយ* កថាខណ្ឌ ៣៤។

[200] *ដីកាដំណោះស្រាយ* កថាខណ្ឌ ៣៥។

[201] សំណុំរឿង ០០២ ឯកសារ E1/91.1 *ប្រតិចារឹក* ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ២៦។

[202] *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ* កថាខណ្ឌ ៤៣, ៥២-៦២, ៨៦, ៨៩ និង *ដីកាដំណោះស្រាយ* កថាខណ្ឌ ៤២៤ និង ៤៣៣។

នៅឆ្នាំ ១៩៧៧ និងឆ្នាំ ៩៧៨។ អៀង សារី ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចគ្នានេះ[203]។

ii. ភាពត្រូតស៊ីគ្នានៅក្នុងការចោទប្រកាន់អំពីទម្រង់នៃទទួលខុសត្រូវ៖ សហឧក្រិដ្ឋកម្មរួម

១០៣. អៀង សារី ត្រូវបានចោទប្រកាន់ថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ ដូចជា តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម។ ជនសង្ស័យ តាមរយៈសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការមជ្ឈិម និង/ឬតំណែងរបស់គាត់ជាលេខាកងពលលេខ ១៦៤ ក៏ស្ថិតនៅក្នុងចំណោមជនដែលត្រូវបានចោទប្រកាន់ចំពោះសហឧក្រិដ្ឋកម្មរួមដែលបានបង្ហាញនៅក្នុងដីកាដំណោះស្រាយ នៅក្នុងសំណុំរឿង ០០២[204]។

iii. ភស្តុតាងជាក់ស្តែងអំពីការជាប់ពាក់ព័ន្ធរួមនៅក្នុងការចោទប្រកាន់ត្រួតស៊ីគ្នាមួយចំនួន

១០៤. ភស្តុតាងឯកសារដែលបានត្រួតពិនិត្យដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្ហាញថា ក្នុងសមាសភាពផ្សេងគ្នា ទាំង អៀង សារី និងជនសង្ស័យ មានការជាប់ពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់ត្រួតស៊ីគ្នាមួយចំនួនដូចបានរៀបរាប់ខាងលើ[205]។ ឧទាហរណ៍ នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ សុន សេន [206] រាយការណ៍ទៅអៀង សារី[207] និងមេដឹកនាំផ្សេងទៀតនៃកម្ពុជាប្រជាធិបតេយ្យ

---

[203] *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ* កថាខណ្ឌ ៤៧-៥១, ៦២, ៩៦-៩៧ និង*ដីកាដំណោះស្រាយ* កថាខណ្ឌ ៣៨៣-៣៩៨ និង ៨៣៦-៨៤០។

[204] *ដីកាដំណោះស្រាយ* កថាខណ្ឌ ១៥៦-១៥៩។

[205] នេះគឺជាការវាយតម្លៃជាក់ស្តែងដែលបានធ្វើឡើងសម្រាប់តែគោលបំណងវាយតម្លៃអត្ថិភាពនៃទំនាស់ផលប្រយោជន៍របស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការតំណាងឲ្យជនសង្ស័យ។

[206] ទោះបីជាសេចក្តីរាយការណ៍នេះត្រូវបានធ្វើឡើងដាក់ឈ្មោះ "ខៀវ"ក៏ដោយ ក៏ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជឿជាក់ថាជាក់ស្តែង ខៀវ គឺ សុន សេន។ *សូមមើល* សំណុំរឿង ០០២ ឯកសារ E3/70 *កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីឈ្មោះ ឡុញ ដុស* ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១១ ទំព័រ ៧។

[207] យោងតាមកថាខណ្ឌ ១០០០ នៃដីកាដំណោះស្រាយ បានឲ្យដឹងថា នៅក្នុងអំឡុងពេលរបប ប.ក.ក អៀង សារី បានប្រើឈ្មោះ បដិវត្តន៍ ហៅ "វ៉ាន់"។

ដោយផ្អែកលើព័ត៌មានទទួលបានពី "សមមិត្ត មុត" អំពីការចាប់ខ្លួនអ្នកនេសាទជនជាតិថៃ ៤នាក់[208]។ យោងតាមអត្ថបទសារព័ត៌មានចំនួនពីរអត្ថបទ បានឲ្យដឹងថា រវាងថ្ងៃទី ៤ ខែ កុម្ភៈ និងថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ អៀង សារី ជាប់ពាក់ព័ន្ធនឹងការចរចាដោះលែងអ្នកនេសាទថៃមួយចំនួន ដែលបានចាប់ខ្លួននៅដែនសមុទ្រដោយកងកម្លាំងកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ[209]។ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ ជនសង្ស័យ រាយការណ៍ទៅមេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិតេយ្យ រួមមាន អៀង សារី អំពីការពន្យារពេលដោះលែង "សៀម" [210]។

១០៥. យោងតាមអត្ថបទសារព័ត៌មានមួយទៀតបានឲ្យដឹងថា នៅខែ មិថុនា ឆ្នាំ ១៩៧៨ អៀង សារី បានដឹងអំពីការដាក់ឃុំឃាំងអ្នកនេសាទថៃនៅ "ការដ្ឋានការងារ" និងការសម្លាប់កសិករថៃដោយកងកម្លាំងខ្មែរក្រហម ហើយបានពិភាក្សាបញ្ហាទាំងនេះជាមួយនឹងតំណាងរដ្ឋាភិបាលថៃ[211]។

១០៦. នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ ជនសង្ស័យបានជូនដំណឹងទៅ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ រួមមាន អៀង សារី អំពីការចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាមចំនួន ១២០នាក់[212]។ នៅខែ មិថុនា ឆ្នាំ ១៩៧៨ អៀង សារី ត្រូវបានរាយការណ៍ថាបានបញ្ជាក់ថា កម្ពុជា បាន "វាយប្រហារទៅលើពួកឈ្លានពានវៀតណាម យ៉ាងអាម៉ាស់"[213]។

១០៧. សហមេធាវីដែលត្រូវបានចាត់តាំង បានជំទាស់ទៅនឹងភាពជឿជាក់បានរបស់អត្ថបទសារព័ត៌មានទាំងនោះដែលរាយការណ៍អំពីអៀង សារី ដោយបានបញ្ជាក់ថា កង្វះខាតមិនមានឈ្មោះម្ចាស់អត្ថបទ និងព័ត៌មានខ្លឹមសារផ្សេងទៀត មិនអាចឲ្យគេពិនិត្យទៅលើភាពពិតប្រាកដនៃអត្ថន័យអត្ថបទទាំងនោះបានទេ[214]។ ទោះយ៉ាងណា ការវាយតម្លៃលើអត្ថិភាពនៃលទ្ធភាពទំនាស់ផលប្រយោជន៍ ជាពិសេស

---

[208]សំណុំរឿង ០០៣ ឯកសារ D1.3.34.23 *ទូរលេខ ១៨* ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧។

[209]សំណុំរឿង ០០២ ឯកសារ E3/1751 *អត្ថបទសារព័ត៌មាន ចំណងជើង "ពាណិជ្ជកម្មថៃជាមួយកម្ពុជា"* ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ ទំព័រ ៤។ សំណុំរឿង ០០២ ឯកសារD108/28.222 *អត្ថបទសារព័ត៌មាន ចំណងជើង "កម្ពុជា យល់ព្រមដោះលែងអ្នកនេសាទថៃ"* ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៨ ទំព័រ ៦។

[210] សំណុំរឿង ០០៣ ឯកសារ D1.3.30.25 *ទូរសព្ទសំងាត់* ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨។

[211] សំណុំរឿង ០០២ ឯកសារ E3/1752 *សេចក្តីរាយការណ៍ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ* ខែ កក្កដា ឆ្នាំ ១៩៧៨។

[212] *ដូចជើងទំព័រខាងលើ*។

[213] *ដូចជើងទំព័រខាងលើ*។

[214] *សារណារបស់សហមេធាវីដែលត្រូវបានចាត់តាំង* កថាខណ្ឌ ៣១។

នៅដំណាក់ដំបូងនៃកិច្ចដំណើរការនីតិវិធី មិនតម្រូវឱ្យមានភស្តុតាងប្រាកដដាច់ខាតទេ ប៉ុន្តែតម្រូវឱ្យមានការពិនិត្យជាក់ស្តែងទៅលើភស្តុតាង។ ប្រសិនបើតម្រូវឱ្យមានភស្តុតាងប្រាកដដាច់ដាតនោះ ទំនាស់ផលប្រយោជន៍នៅដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធី នឹងមិនអាចទប់ស្កាត់បានឡើយ។ ការត្រួតពិនិត្យទៅលើយុត្តិសាស្ត្រអន្តរជាតិ បង្ហាញថា នៅក្នុងរឿងក្តីផ្សេងទៀត ចៅក្រមអន្តរជាតិ បានរកឃើញអត្ថិភាពនៃទំនាស់ផលប្រយោជន៍ ដោយផ្អែកលើតែការចោទប្រកាន់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[215]។ ដោយផ្អែកលើកាលបរិច្ឆេទ និងខ្លឹមសារនៃអត្ថបទទាំងនោះ ដែលស្របនឹងព័ត៌មានដែលជនសង្ស័យបានបញ្ជូនទៅមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជឿជាក់ថា ដោយផ្អែកលើការវិនិច្ឆ័យជាក់ស្តែង អត្ថបទទាំងនោះអាចជឿជាក់បាន។

១០៨. ភស្តុតាងក៏បង្ហាញពីទំនាក់ទំនងជាក់ស្តែងរវាងឧក្រិដ្ឋកម្មដែលបានចោទប្រឆាំងនឹងជនសង្ស័យនៅក្នុងសំណុំរឿង ០០៣ និងសហឧក្រិដ្ឋកម្មរួមដែលបានចោទនៅក្នុងសំណុំរឿង ០០២។ នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៦ នៅក្នុងការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំរបស់កម្ពុជាប្រជាធិបតេយ្យ សុន សេន[216] បាននិយាយអំពីភាពសំខាន់នៃការយកជ័យជំនះលើខ្មាំងរបស់ខ្មែរក្រហម ដោយបានបញ្ជាក់ថា "ត្រូវសំរិតសំរាំងសមាសភាពមិនល្អ ដាច់ខាត" [217] ។ នៅពេលដែលជនសង្ស័យឡើងនិយាយ គាត់បានសរសើរសកម្មភាពដែលមានបំណងវែកមុខ *"ពួកក្បត់ក្នុងបក្ស"* ហើយបានបញ្ជាក់ថា *"សមាសភាពមិនល្អ ឬខ្មាំងនៅតែពួនបន្លំបង្កប់បក្សទៀត"*។ ក្រោយពីប្រកាសថាគាត់ "យល់ស្របឯកភាព ជាមួយបក្សទាំងស្រុង"លើតម្រូវការដោះស្រាយវត្តមានខ្មាំងនៅក្នុងជួរបក្ស គាត់បានបញ្ជាក់ថា៖

*"ធ្វើម៉េច កុំឱ្យស្ថានការណ៍ជ្រួលហួស[...]កុំឱ្យស្ថានការណ៍វាពង្រីងពង្រីកខ្លួនបានឱ្យសោះ"*[218]។

---

[215] សេចក្តីសម្រេចបុរេជំនុំជម្រះ *Prlić* កថាខណ្ឌ ២៩-៣០។ ដីកាសម្រេចលើបណ្តឹងតវ៉ា *Mejakić* កថាខណ្ឌ ១២។ ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* កថាខណ្ឌ ២៣-២៤។ ដីកាសម្រេច *Delić* ទំព័រ ២-៣។

[216] ឈ្មោះហៅក្រៅមួយក្នុងចំណោមឈ្មោះហៅក្រៅរបស់ សុន សេន គឺ បង ៨៩។ *សូមមើល* សំណុំរឿង ០០១ ឯកសារ D99 ដីកាដំណោះស្រាយ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ២។

[217] សំណុំរឿង ០០៣ ឯកសារ D1.3.27.20 (វត្ថុតាងសាធារណៈនៅក្នុងសំណុំរឿង ០០២ ឯកសារ E3/152) *កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ្យ* ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៦ ERN 00183987។

[218] *ដូចដើងទំព័រខាងលើ* ERN 00183990។

១០៩. នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ នៅក្នុងទូរលេខមួយផ្ញើទៅ "គណៈ ៨៧០" (និងចម្លងជូន ដូចជា "បងវ៉ាន់" គឺអៀង សារី) ជនសង្ស័យបានបញ្ជាក់ថាបានទទួលទស្សនៈណែនាំរបស់បក្សស្តីពីវៀតណាម និងបានសន្យាការពារបក្ស និងបោសសម្អាតគ្មានស្ទាក់ស្ទើរសមាសភាពខ្មាំងបង្កប់ "*ជាយួន និងខ្មាំងដទៃទៀត*" [219] ។

១១០. គួរឲ្យកត់សម្គាល់ ការកសាង "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" ទាំងក្នុង និងក្រៅជួរ ប.ក.ក គឺជាគោលនយោបាយមួយក្នុងចំណោមគោលនយោបាយដែលបានរៀបចំ និងអនុវត្តដោយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ក្នុងការជំរុញឲ្យមានសហឧក្រិដ្ឋកម្មរួម។ បើយោងតាម ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ គោលនយោបាយនេះ "*ត្រូវបានអនុវត្តជាចំបងដោយសមាជិកនៃកងកម្លាំងសន្តិសុខ និងយោធានៃបក្សកុម្មុយនីស្តកម្ពុជា(សន្តិបាល)*" [220] ។ ជនសង្ស័យត្រូវបានចោទថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានចោទនៅក្នុងសំណុំរឿង ០០៣ ដូចជា តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម[221]។ ផែនការឧក្រិដ្ឋកម្មនៃសហឧក្រិដ្ឋកម្មរួមដែលបានចោទនេះ គឺត្រូវ"កំណត់សម្គាល់សមាជិក ក.ប.ក ដែលត្រូវបានចោទប្រកាន់ថាជាខ្មាំង ឬជនក្បត់ ហើយដើម្បីចាប់ និងដាក់ឃុំដោយខុសច្បាប់ ធ្វើបាបដោយអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់" [222]។

១១១. ដូច្នេះ មានទំនាក់ទំនងជាក់ស្តែងរវាងការប្រព្រឹត្តដែលត្រូវបានចោទថាបានធ្វើឡើងដោយជនសង្ស័យជាមួយសហឧក្រិដ្ឋកម្ម ដែលបានបង្ហាញនៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២។

---

[219] សំណុំរឿង០០៣ ឯកសារD1.3.34.60 *ទូរលេខយោធាកម្ពុជាប្រជាធិបតេយ្យពីមាស មុត ទៅគណៈ ៨៧០* ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ភាសាដែលប្រើប្រាស់ដោយជនសង្ស័យនៅក្នុងទូរលេខនេះ ឆ្លុះបញ្ចាំងដូចនឹងភាសាដែលប្រើនៅក្នុងទង់បដិវត្តន៍ ដែលជាទស្សនាវដ្តីឃោសនាចេញផ្សាយជារៀងរាល់ខែដើម្បីឆ្លុះបញ្ចាំងពីគោលនយោបាយរបស់ ប.ក.ក។ *សូមមើល ដីកាដំណោះស្រាយ* កថាខណ្ឌ ១០១ និង១៩០។

[220] *ដំណោះស្រាយ* កថាខណ្ឌ ១៥៦-១៥៩, ១៧៨ និង ១៨២។

[221] *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ* កថាខណ្ឌ ៣៣-៤១។

[222] *ដូចដើងទំព័រខាងលើ* កថាខណ្ឌ ៣៣។

iv. ភស្តុតាងអំពីទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមរវាងជនសង្ស័យ ជាមួយអៀង សារី

១១២. ភស្តុតាងឯកសារ បង្ហាញថា រវាងឆ្នាំ ១៩៧៧ និងឆ្នាំ១៩៧៨ បើមិនដោយផ្ទាល់ ឬក៏តាមរយៈសុន សេន ដែរ ជនសង្ស័យ បានរាយការណ៍ទៅមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ រួមមាន អៀង សារី អំពីបញ្ហាដែលជាចំណុចសំខាន់នៃការចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ រួមមានការចាប់ខ្លួននិងការសម្លាប់ជនជាតិវៀតណាមចំនួន ១២០ នាក់ និងការចាប់ខ្លួនអ្នកនេសាទថៃ[223]។ អៀង សារី ខ្លួនគាត់នៅក្នុងបទសម្ភាសន៍មួយជាមួយ Elizabeth Becker ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ បានបញ្ជាក់ថា សុន សេន រាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ អំពីបញ្ហាសន្តិសុខ និងបានបញ្ជាក់ទៀតថា សុន សេន ពឹងផ្អែកលើ "មនុស្សតំបន់"សម្រាប់ធ្វើសេចក្តីរាយការណ៍ទាំងនេះ ហើយអៀង សារី បានឮពីសេចក្តីរាយការណ៍អំពីបញ្ហាសន្តិសុខ[224]។

១១៣. យោងតាមសហមេធាវីដែលត្រូវបានចាត់តាំង អង្គហេតុដែលថា អៀង សារី មានឈ្មោះនៅក្នុងចំណោមអ្នកទទួលទូរលេខបញ្ជូនពីជនសង្ស័យ (ឬពីសុន សេន បញ្ជូនព័ត៌មានដែលទទួលបានពីជនសង្ស័យ)នោះ មិនមែនជាភស្តុតាងបញ្ជាក់ថា អៀង សារី ពិតជាទទួលបានទូរលេខទាំងនោះទេ។ ខណៈដែលភស្តុតាងនេះ អាចមិនមែនជាភស្តុតាងប្រាកដដាច់ខាតក៏ដោយ ក៏ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជឿជាក់ថា ដោយផ្អែកលើមូលដ្ឋានជាក់ស្តែង បង្ហាញថា អៀង សារី ទទួលបានសេចក្តីរាយការណ៍ដែលបានត្រួតពិនិត្យខាងលើ។

១១៤. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានពិចារណាទៅលើបទសម្ភាសន៍មួយដែលបានធ្វើឡើងជាមួយជនសង្ស័យ នៅខែ កក្កដា ឆ្នាំ ១៩៨១ ដោយក្នុងបទសម្ភាសន៍នេះ គាត់បានបញ្ជាក់ថា៖

> *"ប្រសិនបើអ្នកចង់ដឹងរឿងរ៉ាវគ្រប់យ៉ាងនៅក្នុងសម័យនោះ សូមទៅសួរ អៀង សារី ទៅ។ កុំសួរខ្ញុំ ឬមន្ត្រីមានឋានៈទាបៗផ្សេងទៀត។ អៀង សារី គឺជាអ្នកដឹកនាំ។ សម្រាប់ខ្ញុំ ខ្ញុំគ្មាន*

---

[223] សំណុំរឿង ០០៣ ឯកសារ D1.3.30.25 *ទូរសព្ទសំងាត់* ថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨។ សំណុំរឿង ០០៣ ឯកសារ D1.3.34.23 *ទូរលេខ ១៨* ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧។

[224] សំណុំរឿង ០០៣ ឯកសារ D4.1.1032 [ក៏មាននៅក្នុងឯកសារភស្តុតាង សំណុំរឿង ០០២ ឯកសារ E3/94] *បទសម្ភាសន៍ជាមួយ អៀង សារី ធ្វើឡើងដោយ Elizabeth Becker* ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៨១ ទំព័រ ៣។

*បញ្ហាជាមួយនឹងតុលាការឡើយ។ ខ្ញុំនឹងនិយាយរឿងរ៉ាវសព្វយ៉ាង៖ អ្វីដែលខ្ញុំបានដឹង និងបានធ្វើ។ មន្ត្រីមានឋានៈទាបត្រូវតែគោរពបញ្ជា*"[225]។

១១៥. យោងតាម សហព្រះរាជអាជ្ញាអន្តរជាតិ បានឱ្យដឹងថា នៅក្នុងបទសម្ភាសន៍នេះ ជនសង្ស័យ ទម្លាក់ការទទួលខុសត្រូវទៅ អៀង សារី ដោយផ្ទាល់ ហើយស្វះស្វែងឱ្យខ្លួនគាត់រួចខ្លួនពីការទទួលខុសត្រូវណាមួយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កត់សម្គាល់ថា អត្ថបទសម្ភាសន៍ ដែលយល់ថាដកស្រង់ពីខ្លឹមសារនេះ គឺមានន័យមិនច្បាស់លាស់មួយផ្នែក។ មិនច្បាស់ថាតើ ជនសង្ស័យ សំដៅ ឬក៏មិនសំដៅលើឧក្រិដ្ឋកម្មជាក់លាក់ដែលអ្នកទាំងពីរ ឥឡូវនេះ ត្រូវបានចោទថាទទួលខុសត្រូវ ឬក៏អ្នកទាំងពីរធ្លាប់ត្រូវបានចោទថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ ក្នុងករណីអៀង សារី ដែលបានស្លាប់ហើយ។ ទោះយ៉ាងណា ជនសង្ស័យ ពិតជាសំដៅលើ អៀង សារី ថាជា "អ្នកដឹកនាំ" ខណៈដែលគាត់ហាក់ដូចជាចង់ចាត់ទុកខ្លួនគាត់ថាជា "មន្ត្រីថ្នាក់ទាប"។ ចំណុចនេះ បូករួមជាមួយនឹងទូរលេខដែលបានពិចារណាខាងលើ បង្ហាញពីទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមរវាងអ្នកទាំងពីរ។ វាក៏បង្ហាញពីលទ្ធភាពយុទ្ធសាស្ត្រការពារក្តី ដែលជនសង្ស័យអាចសម្រេចស្វែងរកដើម្បីការពារក្តីខ្លួនឯង ប្រសិនបើគាត់ត្រូវបានចោទជាផ្លូវការ និងបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែលបានចោទនៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ។

v. សេចក្តីសន្និដ្ឋានលើអត្ថិភាពនៃទំនាក់ទំនងអង្គហេតុ និងទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមជាក់ស្តែងរវាងអៀង សារី ជាមួយជនសង្ស័យ

១១៦. ដោយផ្អែកលើភាពត្រួតស៊ីគ្នានៅក្នុងការចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ និងអៀង សារី និងដោយពិចារណាទៅលើភស្តុតាងដែលបានពិនិត្យខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថាមានទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធរវាងរឿងក្តីរបស់ជនសង្ស័យ ជាមួយអៀង សារី។

១១៧. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានពិចារណាទៅលើសមាជិកភាពរបស់អៀង សារី នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាអង្គការកំពូលនៅក្នុងក្របខ័ណ្ឌអង្គការចាត់តាំងរបស់កម្ពុជា

---

[225] សំណុំរឿង ០០៣ ឯកសារ D1.3.33.16 *កិច្ចសម្ភាសជាមួយ មាស មុត ធ្វើឡើងដោយ Christine Chameau* ខែ កក្កដា ឆ្នាំ ១៩៩១ ទំព័រ១-២។

ប្រជាធិបតេយ្យ។ យោងតាមដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០២ បានឱ្យដឹងថា គណៈកម្មាធិការអចិន្ត្រៃយ៍ បានបង្កើតគោលនយោបាយ រួមមានការកម្ទេចខ្មាំងរបស់ ប.ក.ក ។ ភស្តុតាងនេះបង្ហាញថា ជនសង្ស័យ បានសន្យាអនុវត្តគោលនយោបាយនេះ។ បន្ថែមពីលើនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាឃើញថា ជនសង្ស័យ ដែលជាប្រធានកងពលលេខ ១៦៤ នៃ ក.ប.ក បានផ្ញើសេចក្ដីរាយការណ៍ បើមិនដោយផ្ទាល់ ឬតាមរយៈសុន សេន ទៅឱ្យ អៀង សារី ហើយនៅក្នុងបទសម្ភាសន៍មួយ គាត់បាននិយាយសំដៅទៅ អៀង សារី ថាជា "អ្នកដឹកនាំ"។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថា ធាតុផ្សំទាំងនេះ ជាក់ស្ដែងបង្កើតឱ្យមានអត្ថិភាពនៃទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមយ៉ាងជិតស្និទ្ធរវាងជនសង្ស័យ ជាមួយអៀង សារី។

## III. អាច ឬមិនអាចព្យាករណ៍ជាមុនដោយសមហេតុផលថា ទំនាក់ទំនងអង្គហេតុ និងទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមជាក់ស្ដែង នឹងនាំឱ្យមានទំនាស់ផលប្រយោជន៍

១១៨. ក្នុងករណីដែលមេធាវីណាម្នាក់តំណាងឱ្យកូនក្ដីណាម្នាក់នៅក្នុងរឿងក្ដីមួយដែលជាប់ពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងរឿងក្ដីដែលគាត់ធ្លាប់តំណាងឱ្យកូនក្ដីម្នាក់ផ្សេងទៀតនោះ មេធាវីនោះ ត្រូវតែអាចស្វែងរកប្រយោជន៍ល្អបំផុតឱ្យកូនក្ដីបច្ចុប្បន្ន នៅក្នុងរបៀបដែលមិនបំផ្លាញប្រយោជន៍អតីតកូនក្ដីរបស់ខ្លួន។ នៅក្នុងបរិបទនៃការស៊ើបអង្កេតព្រហ្មទណ្ឌ និងការជំនុំជម្រះក្ដីព្រហ្មទណ្ឌ មេធាវីត្រូវតែអាចផ្ដល់យោបល់ប្រឹក្សាទៅកូនក្ដី អំពីជម្រើសទាំងអស់ដែលអាចមាន ហើយត្រូវស្វែងរកយ៉ាងយកចិត្តទុកដាក់ និងគ្មានដែនកំណត់នូវយុទ្ធសាស្ត្រ វិធីការពារក្ដី និងការស៊ើបអង្កេត និងវិធីត្រួតពិនិត្យដេញដោល ដែលជាប្រយោជន៍ល្អបំផុតសម្រាប់កូនក្ដី[226] ។ គ្មានអ្វីបន្តិចសោះដែលធ្វើឱ្យអស់ករណីយកិច្ចដែលមេធាវីមានចំពោះកូនក្ដី។ នៅពេលដំណាលគ្នានេះដែរ មេធាវី មានកាតព្វកិច្ចមិនអនុវត្តអ្វីដែលប៉ះពាល់ដល់ប្រយោជន៍អតីតកូនក្ដីរបស់ខ្លួន។

១១៩. ដោយពិចារណាទៅលើសេចក្ដីសន្និដ្ឋានខាងលើស្ដីពីអត្ថិភាពនៃទំនាក់ទំនងអង្គហេតុ និងទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមជាក់ស្ដែង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឥឡូវនេះនឹងពិនិត្យថាតើ អាចឬមិនអាចព្យាករណ៍ជាមុនដោយសមហេតុផលថា ទំនាស់ផលប្រយោជន៍អាចកើតឡើងនៅក្នុងសំណុំ

---

[226] *សូមមើល* ដីកាសម្រេចលើបណ្ដឹងតវ៉ា *Mejakić* កថាខណ្ឌ ១៥។

រឿង ០០៣។ ក្នុងការវាយតម្លៃនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នឹងពិចារណាទៅលើជំហរនៅក្នុងសំណុំរឿង ០០២ ដែលសហមេធាវីដែលត្រូវបានចាត់តាំង បានអនុវត្តដើម្បីការពារអៀង សារី ដោយបានស្វះស្វែងឲ្យកូនក្តីរបស់ខ្លួនឃ្លាតឆ្ងាយពី "មជ្ឈិមបក្ស" និងបានស្វះស្វែងបង្ហាញថា គាត់មិនជាប់ពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅ ស-២១ ឡើយ[227]។ នៅក្នុងការវាយតម្លៃនេះនឹងពិចារណាផងដែរលើលទ្ធភាពអនុភាពសម្រាលបន្ទុកតាមរយៈការអនុវត្តតាមបញ្ជាថ្នាក់លើ និងការបង្ខិតបង្ខំ[228] ព្រមទាំងតាមរយៈការសហការជាមួយសហព្រះរាជអាជ្ញា និងអាជ្ញាធរតុលាការ[229]។

---

[227] សំណុំរឿង ០០២ ឯកសារ -E1/61.1 *ប្រតិចារឹក* ថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៩៨-១១៩។ សំណុំរឿង ០០២ ឯកសារ E1/95.1 *ប្រតិចារឹក* ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៦៣-៦៧។

[228] *សាលក្រម ឌុច* កថាខណ្ឌ ៦០៧-៦០៨។ ក្រោយមក ការពិចារណានេះត្រូវបានបញ្ជាក់នៅក្នុងសំណុំរឿង ០០១ នៅអង្គជំនុំជម្រះតុលាការកំពូល រឿងក្តី*សហព្រះរាជអាជ្ញា តទល់នឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច* ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ ឌុច) ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៣៦០។ *សូមមើលផងដែរ* តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូង រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Erdemović *សាលក្រមផ្តន្ទាទោស* ថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៧។ តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូង រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Krstić *សាលក្រម* ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៧១៤។ តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូង រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Todorović *សាលក្រមផ្តន្ទាទោស* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ១១១-១១២។ តុលាការ ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Jelisić *សាលដីកា* ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ១០១។ តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូង រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Rutaganira *សាលក្រម* ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៥ កថាខណ្ឌ ១៦១។ *សូមមើលផងដែរ* លក្ខន្តិកៈនៃ ICC មាត្រា ៣៣ លក្ខន្តិកៈតុលាការ ICTY មាត្រា ៧(៤) លក្ខន្តិកៈតុលាការ ICTR មាត្រា ៦(៤) លក្ខន្តិកៈតុលាការ SCSL មាត្រា ៦(៤) និងលក្ខន្តិកៈតុលាការSTL មាត្រា ៣(៣)។

[229] *សាលក្រម ឌុច* កថាខណ្ឌ ៦០៩។ សាលដីកាលើបណ្តឹងឧទ្ធរណ៍ឌុច កថាខណ្ឌ ៣៦៦។ តុលាការ ICC វិធានស្តីពីនីតិវិធី និងភស្តុតាង វិធាន ១៤៥(២)(ក)(ii)។ តុលាការ ICTY វិធានស្តីពីនីតិវិធី និងភស្តុតាង វិធាន ១០១(ខ) (ii) ។ តុលាការ ICTR វិធានស្តីពីនីតិវិធី និងភស្តុតាង វិធាន ១០១(ខ)(ii) និងតុលាការ SCSL វិធានស្តីពីនីតិវិធី និងភស្តុតាង វិធាន ១០១(ខ) (ii)។ *សូមមើលផងដែរ* តុលាការ ICTY អង្គជំនុំជម្រះសាលាឧទ្ធរណ៍ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Galić *សាលដីកា* ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ៤៣៤។ តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូង រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Blaškić *សាលក្រម* ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ៧៧៤។

00968729



## ក.លទ្ធភាពរបស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការស្វែងរកវិធីស៊ើបអង្កេតនិងយុទ្ធសាស្ត្រការពារក្តីទាំងអស់ដែលអាចមាន

១២០. នៅក្នុងបរិបទឧក្រិដ្ឋកម្មអន្តរជាតិ ជាធម្មតាដែលជនជាប់សង្ស័យ ឬជាប់ចោទពីបទឧក្រិដ្ឋបង្វែរកំហុសទម្លាក់ទៅថ្នាក់លើណាម្នាក់ក្នុងគោលបំណងព្យាយាមផាត់ចេញការទទួលខុសត្រូវផ្ទាល់ខ្លួន។ បន្ថែមពីលើនេះទៀត ការអនុវត្តដោយសារការបង្ខិតបង្ខំ និង/ឬបញ្ជាថ្នាក់លើ អាចមានអនុភាពសម្រាលទោសដែលអាចមាន។ ផលប្រយោជន៍ជាក់ស្តែងនៃការប្រើប្រាស់យុទ្ធសាស្ត្របែបនេះ មានលក្ខណៈធំធេងណាស់ ជាពិសេសនៅក្នុងបរិបទនៃការផ្តន្ទាទោស ហើយត្រូវបានទទួលស្គាល់យ៉ាងច្រើនពីសំណាក់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងៗ[230]។

១២១. ដោយពិចារណាទៅលើទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធរវាងការចោទប្រកាន់ប្រឆាំងនឹងជនសង្ស័យ និងអៀង សារី ទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមជាក់ស្តែងយ៉ាងជិតស្និទ្ធរវាងអ្នកទាំងពីរ និងពិចារណាទៅលើតំណែងជាន់ខ្ពស់របស់អៀង សារី នៅ ប.ក.ក នោះ ទើបអាចព្យាករណ៍ជាមុនដោយសមហេតុផលថា ជនសង្ស័យអាចឆ្លៀតប្រើប្រាស់យុទ្ធសាស្ត្រការពារក្តីដែលមានបំណងបង្វែរកំហុសទៅថ្នាក់លើ ហើយតាមរយៈការធ្វើដូច្នេះ គាត់អាចឆ្លើយដាក់ អៀង សារី ឱ្យជាប់នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទនៅក្នុងសំណុំរឿង ០០៣។ ជនសង្ស័យក៏អាចសម្រេចជំទាស់ទៅនឹងយុត្តាធិការរបស់ អ.វ.ត.ក ដែលកំណត់ត្រឹម“មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ” និង“អ្នកទទួលខុសត្រូវខ្ពស់បំផុត”សម្រាប់ឧក្រិដ្ឋកម្មដែលប្រព្រឹត្តរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ដោយព្យាយាមកាត់បន្ថយឱ្យបានអប្បបរមានូវកម្រិតការចូលរួមរបស់ខ្លួននៅក្នុងឧក្រិដ្ឋកម្មដែលបានចោទ ហើយបង្កើនការទទួលខុសត្រូវរបស់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងនោះ អៀង សារី គឺជាសមាជិក[231]។ បទសម្ភាសន៍នៅខែ កក្កដា ឆ្នាំ ១៩៩១ របស់ជនសង្ស័យ ដែលបានពិភាក្សាខាងលើ ផ្តល់ការបង្ហាញមួយថា គាត់អាចសម្រេចប្រកាន់យកវិធីការពារក្តីទាំងនេះ។

---

[230] *សូមមើល* ជើងទំព័រខាងលើលេខ 228។

[231] មាត្រា ១ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

១២២. ទោះយ៉ាងណា ការស្វែងរកយុទ្ធសាស្ត្រការពារក្តីដែលឆ្លើយដាក់ អៀង សារី ឱ្យជាប់នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នឹងជនសង្ស័យ នឹងបង្កើតឱ្យមានទំនាស់ផលប្រយោជន៍សម្រាប់សហមេធាវីដែលត្រូវបានចាត់តាំង ដែលនៅជាប់ករណីយកិច្ចរក្សាភាពស្មោះត្រង់ជាមួយអតីតកូនក្តីរបស់ខ្លួន[232]។

១២៣. ទំនាស់ផលប្រយោជន៍នេះ អាចមានបញ្ហាជាប់ពាក់ព័ន្ធមួយចំនួន នៅដំណាក់ផ្សេងៗនៃកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនសង្ស័យ។ នៅដំណាក់កាលស៊ើបអង្កេត ទំនាស់នេះអាចកម្រិតលទ្ធភាពរបស់សហមេធាវីដែលត្រូវបានចាត់តាំង ក្នុងការស្នើ សហចៅក្រមស៊ើបអង្កេត សុំស្តាប់ចម្លើយសាក្សី ឬស្វែងរកយុទ្ធវិធីស៊ើបសួរជាក់លាក់ណាដែលអាចឆ្លើយដាក់ថ្នាក់លើនៃរបបកម្ពុជាប្រជាធិបតេយ្យ ឱ្យជាប់នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទនៅក្នុងសំណុំរឿង ០០៣។ នេះគឺជាបញ្ហាពិសេសនៅក្នុងបរិបទរបស់ អ.វ.ត.ក ដែលការខកខានមិនបានភស្តុតាងមួយចំនួននៅអំឡុងពេលស៊ើបអង្កេត អាចប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយក្នុងការដាក់ភស្តុតាងនោះឱ្យទទួលយកនៅពេលជំនុំជម្រះក្តី [233]។ ជាងនេះទៀត ប្រសិនបើសហចៅក្រមស៊ើបអង្កេត សម្រេចរៀបចំឱ្យមានការដេញដោលតទល់គ្នា សហមេធាវីដែលត្រូវបានចាត់តាំង អាចមានដែនកំណត់នៅក្នុងលទ្ធភាពរបស់ខ្លួនក្នុងការលើកឡើងសំណួរដែលអាចឆ្លើយដាក់អតីតកូនក្តីរបស់ខ្លួន។ ដូចគ្នានេះដែរ ប្រសិនបើជនសង្ស័យត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះវិញ ករណីយកិច្ចរបស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការរក្សាភាពស្មោះត្រង់ជាមួយអៀង សារី អាចកម្រិតលទ្ធភាពរបស់សហមេធាវីក្នុងការពិចារណា ផ្តល់អនុសាសន៍ ឬអនុវត្តយុទ្ធសាស្ត្រការពារក្តីណាមួយ៉ាង រួមមាន ការកោះហៅសាក្សី និងការស្វះស្វែងរកវិធីសាស្ត្រពិនិត្យដេញដោល[234] ។

---

[232] *សូមមើល* ដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina* កថាខណ្ឌ ២៧-២៨។

[233]វិធានផ្ទៃក្នុង ៥៥(១០) អនុញ្ញាតឱ្យភាគីនានា ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត បំពេញកិច្ចស៊ើបសួរដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបអង្កេត។ យោងតាមវិធាន ៨៧(៤) នៅអំឡុងពេលសវនាការនៃកិច្ចដំណើរការនីតិវិធី ជនជាប់ចោទអាចដាក់សំណើសុំឱ្យទទួលយកភស្តុតាងថ្មី ប៉ុន្តែត្រូវធ្វើឱ្យ អង្គជំនុំជម្រះសាលាដំបូង ជឿជាក់ថា ភស្តុតាងនោះពុំអាចរកបាននៅដំណាក់កាលស៊ើបអង្កេត។

[234]កត្តាទាំងនេះត្រូវបានពិចារណាដោយ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុងការវាយតម្លៃថាតើទំនាស់ផលប្រយោជន៍ទំនង ឬមិនទំនងជាប៉ះពាល់ជាអចិន្ត្រៃយ៍ដល់កិច្ចការរដ្ឋបាលតុលាការ។ *សូមមើល*ដីកាសម្រេចលើបណ្តឹងតវ៉ា *Mejakić* កថាខណ្ឌ ១៥ ដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina* កថាខណ្ឌ ២៧-២៨ និង សេចក្តីសម្រេចបុរេជំនុំជម្រះ *Prlić* កថាខណ្ឌ ១៥។

## **ខ. ការសហការជាមួយ អ.វ.ត.ក**

១២៤. បន្ថែមពីលើបញ្ហាការបង្ខិតបង្ខំ និងបញ្ហាថ្នាក់លើ ការសហការជាមួយ អ.វ.ត.ក ក៏អាចបង្កើតឱ្យមានកត្តាស្ថានសម្រាលដែរ។ ការផ្តល់ ឬការបញ្ជាក់អំពីព័ត៌មានដែលសហព្រះរាជអាជ្ញាមិនបានដឹង[235] ការទទួលស្គាល់អង្គហេតុ[236] ការជួយរៀបចំប្រតិបត្តិការដែលនាំឱ្យមានការចាប់ខ្លួនជនសង្ស័យផ្សេងទៀត[237] ការសារភាពកំហុស[238] និងការយល់ព្រមផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីផ្សេងទៀត ត្រូវបានចាត់ទុកថាជាការសហការ[239]។

---

[235] តុលាការ ICTR អង្គជំនុំជម្រះសាលាដំបូង រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Serugendo *សាលក្រម* ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ៦១-៦២។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Dragan Nikolić,* សំណុំរឿងលេខ IT-94-2-S សាលក្រមផ្តន្ទាទោស (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ២៥៣ (ក្នុងសាលក្រមនេះ ជនជាប់ចោទ បានផ្តល់ "ព័ត៌មានលម្អិតយ៉ាងច្រើន"អំពីឧក្រិដ្ឋកម្ម និងអ្នកប្រព្រឹត្តនៅក្នុងក្រុងរបស់គាត់ ព្រមទាំងអំពីទំនាក់ទំនងរបស់ពួកគេជាមួយថ្នាក់ដឹកនាំ និងទិសដៅថ្នាក់ដឹកនាំ)។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Miroslav Deronjić,* សំណុំរឿងលេខ IT-02-61-S សាលក្រមផ្តន្ទាទោស (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ កថាខណ្ឌ ២៤២-២៦០(ក្នុងសាលក្រមនេះ ជនជាប់ចោទបានផ្តល់ព័ត៌មានលក្ខណៈពិសេស និងជាការបញ្ជាក់ ទៅឱ្យរដ្ឋអាជ្ញា ស្តីពីឧក្រិដ្ឋកម្ម និងអ្នកប្រព្រឹត្តដែលពីមុនគេមិនបានដឹង រួមជាមួយនឹងព័ត៌មានដើមទាក់ទងនឹងការធ្វើសង្គ្រាម)។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Erdemovic* សំណុំរឿងលេខ IT-96-22-T សាលក្រមផ្តន្ទាទោស ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ១៧(ក្នុងសាលក្រមនេះ ជនចាប់ចោទបានផ្តល់ជូនរដ្ឋអាជ្ញានូវព័ត៌មានថ្មីស្តីពីអ្នកប្រព្រឹត្ត និងឧក្រិដ្ឋកម្ម បានបង្ហាញអត្តសញ្ញាណមេបញ្ជា និងអ្នកសម្លាប់ បានផ្តល់ព័ត៌មានអំពីរចនាសម្ពន្ធយោធាដែលឈានដល់ការចេញដីកាចាប់ខ្លួន)។ រឿងក្តី *រដ្ឋអាជ្ញាលតទល់នឹង Miroslav Bralo* សំណុំរឿងលេខ IT-95-17-A សាលក្រមផ្តន្ទាទោស ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០០៧ ទំព័រ ១៨-៣៦(ក្នុងសាលក្រមនេះ ជនជាប់ចោទបានផ្តល់ព័ត៌មានអំពីឧក្រិដ្ឋកម្មដែលមិនមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងបានលម្អិតអំពីគោលបំណងរើសអើងរបស់ពួកគេ)។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Obrenović* សំណុំរឿងលេខ IT-02-60/2-S សាលក្រមផ្តន្ទាទោស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៣ ទំព័រ ៣៧-៣៩(ក្នុងសាលក្រមនេះ ជនជាប់ចោទ បានផ្តល់ព័ត៌មានអំពីមជ្ឈដ្ឋានការងារផ្ទៃក្នុងនៃថ្នាក់ដឹកនាំ បានអនុញ្ញាតឱ្យអ្នកស៊ើបអង្កេតឆែកឆេរទ្រព្យសម្បត្តិរបស់កងពលតូចទោះបីជាមានហានិភ័យថាអ្នកស៊ើបអង្កេតអាចរកឃើញភស្តុតាងបទឧក្រិដ្ឋក៏ដោយ និងបានប្រគល់អាវុធជូនអ្នកស៊ើបអង្កេត ដើម្បីធ្វើការពិនិត្យ ព្រមទាំងបានជួបជាមួយរដ្ឋអាជ្ញា ជាច្រើនដង)។

[236] តុលាការ ICTR អង្គជំនុំជម្រះសាលាដំបូង រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Musema *សាលក្រម និងការផ្តន្ទាទោស* ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ១០០៧។

[237]តុលាការ ICTR អង្គជំនុំជម្រះសាលាដំបូង រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Serushago *សាលក្រមផ្តន្ទាទោស* ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៣២។

១២៥. សហមេធាវីដែលត្រូវបានចាត់តាំង បានបញ្ជាក់ថា "ដូចបានបង្ហាញតាមរយៈការលះបង់សិទ្ធិ គ្មានកូនក្ដីណាម្នាក់ បានដឹងពីអ្វីដែលអាចប៉ះពាល់ដល់កូនក្ដីម្នាក់ទៀតឡើយ" [240]។ ទោះយ៉ាងណាការលះបង់សិទ្ធិរបស់ជនសង្ស័យ មិនបញ្ជាក់ច្បាស់លាស់អំពីចំណេះដឹងរបស់គាត់អំពីតួនាទី និងការអនុវត្តរបស់អៀង សារី[241]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានទទួលផងដែរនូវការជូនដំណឹងពីជនសង្ស័យអំពីសេចក្ដីសម្រេចរបស់គាត់ក្នុងការអនុវត្តសិទ្ធិនៅស្ងៀមមិនឆ្លើយតបទាំងនៅក្នុងសំណុំរឿង ០០២ និង០០៣[242]។ ជម្រើសនេះមានពេញលេញនៅក្នុងសិទ្ធិរបស់ជនសង្ស័យ។ ទោះយ៉ាងណា ជនដែលដំបូងគ្មានបំណងសហការជាមួយនឹងអាជ្ញាធរតុលាការ ប៉ុន្តែក្រោយមក អាចសម្រេចសហការវិញ។ ស្រដៀងគ្នានេះដែរ យោបល់ប្រឹក្សារបស់មេធាវីណាម្នាក់ទៅកូនក្ដីរបស់ខ្លួនអាចប្រែប្រួល ឧទាហរណ៍ ដោយផ្អែកលើមូលដ្ឋានថាពីមុនគ្មានភស្តុតាង។ ជាពិសេស ចំណុចនេះមានពិតប្រាកដនៅដំណាក់កាលដំបូងនៃកិច្ចដំណើរការនីតិវិធី។ ដូចបានអង្កេតដោយគណៈកម្មការ USSC ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY បានដកស្រង់ និងឯកភាពតាមនៅក្នុងដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ Gotovina ។

---

[238]តុលាការ ICTR អង្គជំនុំជម្រះសាលាដំបូង រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Rugambarara សាលក្រមផ្ដន្ទាទោស* ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ៣០ ("ចម្លើយសារភាពទោស អាចមានអនុភាពស្ពានសម្រាលទោស ដោយ៖ បង្ហាញពីវិប្បដិសារីការស្ដាយក្រោយ ការចូលរួមចំណែកក្នុងការផ្សះផ្សាគ្នាឡើងវិញ ការបង្ហាញការពិត ការលើកទឹកចិត្តឱ្យជនប្រព្រឹត្តផ្សេងទៀតចេញមុខ និងជួយមិនឱ្យការស៊ើបអង្កេត និងការជំនុំជម្រះក្ដីចំណាយពេលវែងឆ្ងាយ ដូច្នេះចំណាយពេលវេលា ការខិតខំប្រឹងប្រែង និងធនធានបានតិច ព្រមទាំងអង្គហេតុដែលថា សាក្សីមានអារម្មណ៍ ធូរស្រាលពេលផ្ដល់ភស្តុតាងនៅក្នុងតុលាការ")។ *សូមមើលផងដែរ* តុលាការ ICTR អង្គជំនុំជម្រះសាលាដំបូង រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង* Nzabirinda សាលក្រមផ្ដន្ទាទោស ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ កថាខណ្ឌ ៦៥។ តុលាការ ICTR អង្គជំនុំជម្រះសាលាដំបូង រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Bisengimana* សាលក្រមផ្ដន្ទាទោស ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ កថាខណ្ឌ ១២៦។

[239]តុលាការICTR អង្គជំនុំជម្រះសាលាដំបូង រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Serushago សាលក្រមផ្ដន្ទាទោស* ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៣៣។ តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូង រឿងក្ដី *រដ្ឋអាជ្ញាតទល់នឹង Todorović សាលក្រមផ្ដន្ទាទោស* ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១ កថាខណ្ឌ ៨៥។

[240]សំណុំរឿង០០៣ ឯកសារD56/4/1 *សំណើសុំបន្ថែមចំនួនទំព័រ និងសារណារបស់សហមេធាវី ស្ដីពីលទ្ធភាពទំនាស់ផលប្រយោជន៍នៅក្នុងការតំណាងលោកមាស មុត នៅក្នុងសំណុំរឿង ០០៣* ថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣៥។

[241] សំណុំរឿង០០៣ ឯកសារ D56/4/1.2 *ការជូនដំណឹងរបស់មាស មុត អំពីចេតនាប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយ និងការលះបង់ចោលនូវទំនាស់ផលប្រយោជន៍ដែលអាចកើតមាន* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២។

[242] *ដូចដើងទំព័រខាងលើ*។

"ភាពទំនងនឹងកើតឡើង និងទំហំនៃទំនាស់ផលប្រយោជន៍កកើតដំបូង ត្រូវបានដឹងជាទូទៅថា ពិបាកព្យាករណ៍ជាមុនណាស់ សូម្បីតែអ្នកដែលយល់ដឹងទាំងស្រុងទៅលើការជំនុំជម្រះក្តីព្រហ្មទណ្ឌក៏ដោយ។ កម្រមានមេធាវីណាម្នាក់ដែលនឹងមានសំណាងគ្រប់គ្រាន់អាចដឹងការពិតទាំងអស់ពីកូនក្តីរបស់ខ្លួន មិនសូវបានដឹងទាំងស្រុងមុនពេលមានសវនាការលើអ្វីដែលសាក្សីម្នាក់...នឹងនិយាយនៅក្នុងសវនាការ។ សក្ខីកម្មមួយចំនួនដ៏តិចតួចដែលមិនបានព្យាករណ៍ជាមុន ឬឯកសារតែមួយដែលមិនបានដឹង ឬមិនបានជូនដំណឹងជាមុន អាចកែប្រែយ៉ាងខ្លាំងទៅលើទំនាក់ទំនងរវាងចុងចោទជាច្រើននាក់។ ការមិនអាចព្យាករណ៍បានទាំងនេះគឺលំបាកល្មមរួចទៅហើយសម្រាប់មេធាវីក្នុងការវាយតម្លៃ ហើយកាន់តែលំបាកថែមទៀតក្នុងការជូនដំណឹងតាមរយៈការពន្យល់ទៅចុងចោទព្រហ្មទណ្ឌណាម្នាក់ដែលមិនដឹងអំពីភាពលម្អិតនៃក្រមសីលធម៍ច្បាប់"[243]។

១២៦. សហមេធាវីដែលត្រូវបានចាត់តាំង ស្ថិតនៅក្រោមកាតព្វកិច្ចត្រូវផ្តល់យោបល់ប្រឹក្សាទៅ ជនសង្ស័យអំពីជម្រើសដែលមានទាំងអស់ រួមមានការសហការដោយស្មោះ និងពេញលេញនៅក្នុងសំណុំរឿង ០០២ និង០០៣[244]។ ទោះយ៉ាងណា ការសហការនេះ អាចមានសំអាងហេតុរំពឹងថារួមបញ្ចូលទាំងការពិភាក្សាអំពីតួនាទីរបស់អៀង សារី នៅគណៈកម្មាធិការអចិន្ត្រៃយ៍ និងទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទនៅក្នុងសំណុំរឿង ០០៣។ ស្រដៀងគ្នានេះដែរ ប្រសិនបើជនសង្ស័យត្រូវបានកោះហៅឱ្យផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២[245] ហើងប្រសិនបើគាត់សន្និដ្ឋានថា គាត់មានប្រយោជន៍ល្អបំផុតក្នុងការផ្តល់សក្ខីកម្មនោះ អាចព្យាករណ៍ជាមុនដោយសមហេតុផលថា គាត់នឹងត្រូវសួរសំណួរអំពីតួនាទីរបស់អៀង សារី ដែលលែងជាជនជាប់ចោទក៏ដោយ ក៏នៅមានឈ្មោះនៅក្នុងដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២ ជាសមាជិកម្នាក់នៃសហឧក្រិដ្ឋកម្មរួមជាមួយនឹងជនជាប់ចោទ ខៀវ

[243] *សូមមើល ដីកាសម្រេចលើបណ្តឹងតវ៉ា* Gotovina កថាខណ្ឌ ៣៣ លេខ 98។ *សូមមើលផងដែរ* សេចក្តីសម្រេចបុរេជំនុំជម្រះ *Prlić* កថាខណ្ឌ ២៩។

[244] *សូមមើល ដីកាសម្រេចលើបណ្តឹងតវ៉ា Mejakić* កថាខណ្ឌ ១៣។

[245] នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា សវនាការលើភស្តុតាងនៅក្នុងសំណុំរឿង ០០២/២ ត្រូវចាប់ផ្តើមក្នុងពេលឆាប់ៗដែលអាចធ្វើទៅបានបន្ទាប់ពីសេចក្តីសន្និដ្ឋានបញ្ចប់ការដេញដោលនៅក្នុងសំណុំរឿង ០០២/១ *សូមមើល* សំណុំរឿង ០០២ ឯកសារ *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២* ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ កថាខណ្ឌ ៧៦។

សំផន និងនួន ជា[246]។ គួរកត់សម្គាល់ ឧក្រិដ្ឋកម្មមួយចំនួនដែលអាចជាផ្នែកមួយនៃសំណុំរឿង ០០២/២ ត្រួតស៊ីគ្នាជាមួយនឹងឧក្រិដ្ឋកម្មដែលបានចោទប្រឆាំងនឹងជនសង្ស័យនៅក្នុងសំណុំរឿង ០០៣[247]។

១២៧. ប្រសិនបើកាលៈទេសៈកើតឡើងដោយជនសង្ស័យនឹងមានប្រយោជន៍ដោយសារការលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតប និងដោយសារការសហការជាមួយនឹងអាជ្ញាធរតុលាការនោះ ករណីយកិច្ចរបស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការរក្សាភាពស្មោះត្រង់ជាមួយអៀង សារី អាចកម្រិតលទ្ធភាពរបស់ខ្លួនក្នុងការផ្តល់ជូនជនសង្ស័យនូវយោបល់ប្រឹក្សាដែលនឹងពង្រឹងប្រយោជន៍ល្អបំផុតរបស់ជនសង្ស័យ។ ដូច្នេះ មានលទ្ធផលមួយកើតឡើង គឺ នឹងមិនមានតំណាងផ្លូវច្បាប់ជាមេធាវីដែលមិនមានទំនាស់ផលប្រយោជន៍ឡើយ។

### គ. ករណីកិច្ចរបស់សហមេធាវីដែលត្រូវបានចាត់តាំងក្នុងការរក្សាការសម្ងាត់ឱ្យ អៀង សារី

១២៨. សហព្រះរាជអាជ្ញាអន្តរជាតិ ផ្តល់ទឡ្ហីករណ៍ថា ទំនាស់ផលប្រយោជន៍ ក៏អាចកើតឡើងផងដែរទាក់ទងនឹងព័ត៌មានសម្ងាត់ដែលអៀង សារី អាចបានផ្តល់ជូន សហមេធាវីដែលត្រូវបានចាត់តាំងដោយព័ត៌មានទាំងនោះអាចមានប្រយោជន៍ដល់ជនសង្ស័យ ប៉ុន្តែផ្ទុយពីប្រយោជន៍របស់អៀង សារី។ យោងតាមអង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្តី *Hadžihasanović* បានឱ្យដឹងថា ភាគីដែលស្នើសុំប្តឹងជិតចិត្តប្រឆាំងនឹងមេធាវី គឺមានបន្ទុកត្រូវបញ្ជាក់ពីអត្ថិភាពនៃទំនាស់ផលប្រយោជន៍ណាមួយ៉ាង[248]។ នៅក្នុងរឿងក្តី *Jean-Pierrre Bemba Gombo* អង្គជំនុំជម្រះ III នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) តម្រូវឱ្យមាន "ភស្តុតាង"ដែលបញ្ជាក់ថាមេធាវី មានព័ត៌មានសម្ងាត់ដែលអាចនាំឱ្យមាន

---

[246]ធាតុផ្សំមួយនៃគោលការណ៍សហឧក្រិដ្ឋកម្មរួម គឺអត្ថិភាពនៃ"ពហុជន"ដែលបានប្រព្រឹត្តជំរុញឱ្យមានផែនការរួមនេះ។ ដោយសារមូលហេតុនេះ ការប្រព្រឹត្តរបស់អៀង សារី នឹងនៅតែជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០២/២។

[247]*សូមមើលសំណុំរឿង* ០០២ ឯកសារ E284 *សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ បន្ទាប់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣* ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៧១-៧៤ និងដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរលើកទីពីរ ទំព័រ ១៤-២១។ *សូមមើលផងដែរ* ដីកាសម្រេចលើបណ្តឹងតវ៉ា *Mejakić* កថាខណ្ឌ ១៣។

[248]តុលាការ ICTY អង្គជំនុំជម្រះសាលាដំបូង *រដ្ឋអាជ្ញា តទល់នឹង Hadžihasanović និងអ្នកផ្សេងទៀត* ឯកសារ IT-01-47-PT *ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំពិនិត្យឡើងវិញលើសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលតុលាការក្នុងការចាត់តាំងលោក Rodney Dixo ជាសហមេធាវី ឱ្យជនជាប់ចោទ Kubura* ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០០២ ("ដីកាសម្រេច*Hadžihasanović*") កថាខណ្ឌ ៥៣។

00968735



ទំនាស់ផលប្រយោជន៍[249]។ នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានផ្តល់ភស្តុតាងបញ្ជាក់ថា សហមេធាវីដែលត្រូវបានចាត់តាំង មានព័ត៌មានដែលអៀង សារី បានផ្តល់ជូនជាការសម្ងាត់ ហើយព័ត៌មាននោះអាចសំខាន់ដល់ការការពារក្តីរបស់ជនសង្ស័យ។

**ឃ.សេចក្តីសន្និដ្ឋានលើអត្ថិភាពនៃទំនាស់ផលប្រយោជន៍**

១២៩. ទំនាក់ទំនងអង្គហេតុរវាងរឿងក្តីប្រឆាំងនឹងជនសង្ស័យ និងអៀង សារី រួមមានទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមជាក់ស្តែងរវាងអ្នកទាំងពីរ គឺធ្វើឱ្យប្រយោជន៍របស់អ្នកទាំងពីរ មានលក្ខណៈផ្ទុយខុសគ្នាជាសត្យានុម័ត។ ដោយសារសហមេធាវីដែលត្រូវបានចាត់តាំងមានករណីយកិច្ចរក្សាភាពស្មោះត្រង់ជាមួយអៀង សារី ទើបអាចព្យាករណ៍ជាមុនដោយសមហេតុផលថា សហមេធាវីដែលត្រូវបានចាត់តាំងអាចស្ថិតនៅក្នុងតួនាទីមួយដែលនឹងមិនអាចផ្តល់យោបល់ប្រឹក្សាជូនជនសង្ស័យអំពីយុទ្ធសាស្ត្រការពារក្តី និងមិនអាចស្វែងរកយុទ្ធសាស្ត្រការពារក្តីដែលអាចប៉ះពាល់ដល់អៀង សារី ខណៈដែលយុទ្ធសាស្ត្រនោះអាចមានប្រយោជន៍ដល់ជនសង្ស័យ។ ដូច្នេះ អាចព្យាករណ៍ជាមុនដោយសមហេតុផលថា សហមេធាវីដែលត្រូវបានចាត់តាំង អាចត្រូវ "បង្ខំឱ្យប៉ះពាល់ដល់ករណីយកិច្ច[របស់ខ្លួន]ក្នុងការរក្សាភាពស្មោះត្រង់ ឬប៉ះពាល់ដល់ការតស៊ូមតិយ៉ាងស្វិតស្វាញឱ្យ [ជនសង្ស័យ] ដោយសារជ្រើសរើស ឬលាយលំប្រយោជន៍ខុសគ្នា ឬប្រឆាំងគ្នារវាងអតីតកូនក្តី ឬកូនក្តីបច្ចុប្បន្ន" [250]។

១៣០. ជាសេចក្តីសន្និដ្ឋាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញថា ប្រសិនបើបញ្ជាក់ពីការតែងតាំងសហមេធាវីដែលត្រូវបានចាត់តាំងនោះ អាចព្យាករណ៍ជាមុនដោយសមហេតុផលថាទំនាស់ផលប្រយោជន៍មួយចំនួនអាចកើតឡើងនៅពេលតំណាងឱ្យជនសង្ស័យ។

---

[249] តុលាការ ICC តុលាការ *Jean-Pierre Bemba Gombo* *សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំលុបចោលការតែងតាំងអ្នកប្រឹក្សាផ្នែកច្បាប់ប្រចាំក្រុមការពារក្តី* ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១០ សំណុំរឿងលេខICC-01/05-01/08 កថាខណ្ឌ ៤៥។

[250] ដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina* កថាខណ្ឌ ៤៥។

00968736



## IV. ទំនាស់ផលប្រយោជន៍ អាចលះបង់បាន ឬអត់

១៣១. ទាំង ជនសង្ស័យ និងអៀង សារី បានដាក់ឯកសារលះបង់សិទ្ធិជាលាយលក្ខណ៍អក្សរដោយលះបង់ទំនាស់ផលប្រយោជន៍ណាមួយដែលអាចកើតឡើងមកពីការតំណាងដោយសហមេធាវីដែលត្រូវបានចាត់តាំង[251]។

១៣២. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានករណីយកិច្ចធានាថា សិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានជំនួយគាំទ្រប្រកបដោយប្រសិទ្ធភាពពីមេធាវី និងភាពសុចរិតនៃកិច្ចដំណើរការនីតិវិធី មិនត្រូវស្ថិតនៅក្នុងសភាពគ្រោះថ្នាក់ឡើយ។ ប្រសិនបើមានការសម្រេចថា ហានិភ័យកើតចេញពីទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬអាចកើតឡើង ដូចជាថា ហានិភ័យបែបនោះនឹងត្រូវប៉ះពាល់ដល់សិទ្ធិរបស់ជនសង្ស័យ ឬជនជាប់ចោទក្នុងការទទួលបានការស៊ើបអង្កេត ឬការជំនុំជម្រះក្តីយ៉ាងឆាប់រហ័ស និងប្រកបដោយយុត្តិធម៌[252] ឬប៉ះពាល់ដល់កិច្ចការរដ្ឋបាលតុលាការត្រឹមត្រូវនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អាចចាត់វិធានការទប់ស្កាត់ រួមមានការចេញដីកាបង្គាប់ឲ្យដកមេធាវី ឬបដិសេធមិនបញ្ជាក់ពីការតែងតាំងមេធាវី ទោះបីជាមានការលះបង់សិទ្ធិអំពីទំនាស់ផលប្រយោជន៍យ៉ាងណាក៏ដោយ។ ម្យ៉ាងវិញទៀត បញ្ហាជាប់ពាក់ព័ន្ធនៃទំនាស់មួយចំនួនអាចជាទំនាស់ដែលកូនក្តីដែលត្រូវរងផលប៉ះពាល់ មិនអាចលះបង់បានឡើយ[253]។

១៣៣. រឿងក្តីប្រឆាំងនឹងជនសង្ស័យ មានលក្ខណៈស្មុគស្មាញណាស់ ដូចរឿងក្តីប្រឆាំងនឹងអៀង សារី ដែរ។ ឧក្រិដ្ឋកម្មដែលបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីពីរ ត្រូវបានចោទថាប្រព្រឹត្តនៅក្នុងរយៈកាលជិតបីឆ្នាំ នៅក្នុងបរិបទនៃជម្លោះប្រដាប់អន្តរជាតិស្រករគ្នាចំនួនពីរ នៅទីតាំង

---

[251] សំណុំរឿង០០៣ ឯកសារ D56/4/1.2 *ការជូនដំណឹងរបស់មាស មុត អំពីចេតនាប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយ និងការលះបង់ចោលនូវទំនាស់ផលប្រយោជន៍ដែលអាចកើតមាន* ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២។

[252] *សូមមើល* មាត្រា ១៤ នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ ១៩៦៦ ដែលអាចអនុវត្តបាននៅ អ.វ.ត.ក យោងតាមមាត្រា ១៣នៃកិច្ចព្រមព្រៀង អ.វ.ត.ក។

[253] ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* កថាខណ្ឌ ១៦ និង ១៧ ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* សេចក្តីប្រកាស កថាខណ្ឌ ៣ ដីកាសម្រេចលើបណ្តឹងតវ៉ា*Mejakić* កថាខណ្ឌ ៨ និង ១៤-១៥ និងដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina* កថាខណ្ឌ ១៦, ៣៥ និង ៥៥។ *សូមមើលផងដែរ* មាត្រា ៧.៤ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី។

ឧក្រិដ្ឋកម្មផ្សេងគ្នាមួយចំនួន ហើយជាប់ពាក់ព័ន្ធនឹងជនរងគ្រោះរាប់ពាន់នាក់[254]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ក៏មានការចោទប្រកាន់ទាក់ទងនឹងដំណើរការប្រព្រឹត្តទៅរបស់ ក.ប.ក និងទំនាក់ទំនងរបស់ ក.ប.ក ជាមួយនឹងអង្គការគ្រប់គ្រងមជ្ឈិមផ្សេងៗរបស់កម្ពុជាប្រជាធិបតេយ្យ[255]។ ចុងក្រោយបំផុត ជនសង្ស័យត្រូវបានចោទថា ទទួលខុសត្រូវព្រហ្មទណ្ឌតាមរយៈទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ[256]។

១៣៤. នៅក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើជនសង្ស័យយល់ឃើញថា សហមេធាវីដែលត្រូវបានចាត់តាំងស្ថិតនៅក្នុងតួនាទីមួយដែលមិនអាចផ្តល់យោបល់ប្រឹក្សាដល់គាត់ និងមិនអាចស្វែងរកវិធីការពារក្តីដែលគាត់ចាត់ទុកថាមានប្រយោជន៍ដល់គាត់បានទេ នោះ កាលៈទេសៈបែបនេះគឺជាកាលៈទេសៈពិសេស ដូច្នេះគាត់អាចដកការលះបង់សិទ្ធិរបស់គាត់វិញ ហើយគាត់នឹងមានសិទ្ធិផ្លាស់ប្តូរមេធាវី[257]។ ជាធម្មតា ការវាយតម្លៃរបស់បុគ្គលណាម្នាក់ទៅលើអ្វីដែលជាប្រយោជន៍ល្អបំផុតសម្រាប់គាត់ អាចប្រែប្រួល ហើយនឹងប្រែប្រួលគួរឱ្យកត់សម្គាល់ គឺអាស្រ័យលើភស្តុតាងដែលលេចចេញនៅក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធីតុលាការ។ ដូចគ្នានេះដែរ សហមេធាវីដែលត្រូវបានចាត់តាំង អាចចាត់វិធានការដកខ្លួនពីការតំណាងឱ្យជនសង្ស័យនៅក្នុងអំឡុងពេលស៊ើបអង្កេត ឬនៅក្នុងអំឡុងពេលជំនុំជម្រះក្តីណាមួយនាពេលអនាគត។ រឿងនេះអាចកើតឡើងប្រសិនបើសហមេធាវីដែលត្រូវបាន

[254] *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ* កថាខណ្ឌ ២៨-៣២ និង ៤២-៦៦។

[255] *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ* កថាខណ្ឌ ១២-១៧។

[256] ទម្រង់នៃការទទួលខុសត្រូវទាំងនេះគឺ៖ ការធ្វើផែនការ ញុះញង់ បញ្ជា ជួយ និងជំរុញ ប្រព្រឹត្ត(តាមរយៈបុគ្គលផ្ទាល់ ឬក៏តាមរយៈការចូលរួមរបស់គាត់នៅក្នុងសហឧក្រិដ្ឋកម្មរួម)។ បន្ថែមពីលើនេះទៀត ជនសង្ស័យត្រូវបានចោទថាទទួលខុសត្រូវក្នុងនាមជាថ្នាក់លើរបស់អ្នកនៅក្រោមបង្គាប់ដែលបានប្រព្រឹត្តបទឧក្រិដ្ឋ (ការទទួលខុសត្រូវបញ្ជាថ្នាក់លើ)។ *សូមមើល* ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ កថាខណ្ឌ ៩៦-៩៨។

[257] មាត្រា ៧.២ នៃបទបញ្ជារដ្ឋបាលរបស់អង្គភាពគាំពារការពារក្តី ចែងថា ជនសង្ស័យ ជនត្រូវចោទ ឬជនជាប់ចោទ អាចត្រូវបានអនុញ្ញាតឱ្យផ្លាស់ប្តូរសហមេធាវី នៅក្នុងកាលៈទេសៈពិសេស។ យោងតាមយុត្តិសាស្ត្រតុលាការ ICTY កូនក្តីអាចដកការលះបង់សិទ្ធិវិញនៅពេលណាមួយ។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Prlić និងអ្នកផ្សេងទៀត* ឯកសារIT0474-PT *សេចក្តីសម្រេចលើសំណើសុំតែងតាំងមេធាវី* ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២00៤ កថាខណ្ឌ ២0។ លទ្ធភាពដែលកូនក្តីអាចដកការយល់ព្រម និងបញ្ចប់ការតំណាងជាមេធាវី ក៏ត្រូវបានទទួលស្គាល់ផងដែរនៅកថាខណ្ឌ ២0 នៃខ្លឹមសារវិធាន ១.៧ នៃវិធានគំរូស្តីពីការអនុវត្តវិជ្ជាជីវៈរបស់គណៈមេធាវីអាមេរិក។

ចាត់តាំង យល់ឃើញថាខ្លួនស្ថិតនៅក្នុងតួនាទីមួយមិនអាចផ្តល់យោបល់ប្រឹក្សាឱ្យជនសង្ស័យ ដោយមិនឱ្យរំលោភលើករណីយកិច្ចរបស់ខ្លួនក្នុងការរក្សាភាពស្មោះត្រង់ជាមួយអៀង សារី ឬប្រសិនបើសហមេធាវីដែលត្រូវបានចាត់តាំង មិនអាចស្វែងរកយុទ្ធសាស្ត្រការពារក្តីណាដែលអាចជាប្រយោជន៍ទាំងស្រុងសម្រាប់ជនសង្ស័យ[258]។

១៣៥. ការរក្សាកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស និងប្រយោជន៍របស់ជនរងគ្រោះ និងសាក្សី ត្រូវបានពិចារណាថាជាកត្តាជាប់ពាក់ព័ន្ធនៅក្នុងការសម្រេចថាតើ ទំនាស់ផលប្រយោជន៍អាចត្រូវបានលះបង់ឬអត់[259]។ នៅក្នុងរឿងក្តីដែលមានភាពស្មុគស្មាញ និងវិសាលភាពធំបែបនេះ ប្រសិនបើជនសង្ស័យដកវិញនូវការលះបង់សិទ្ធិរបស់គាត់ដែលត្រូវតំណាងដោយសហមេធាវីដែលត្រូវបានចាត់តាំង ឬមេធាវីដកខ្លួននៅដំណាក់កាលក្រោយមកទៀតនៃការស៊ើបសួរ ឬនៅក្នុងពេលជំនុំជម្រះក្តីណាមួយនាពេលអនាគត នោះវានឹងពន្យារពេលកិច្ចដំណើរការនីតិវិធីគួរឱ្យកត់សម្គាល់។ នោះនឹងត្រូវការពេលវេលាក្នុងការជ្រើសរើស និងតែងតាំងសហមេធាវីថ្មី ហើយសហមេធាវីថ្មីនេះនឹងត្រូវការពេលវេលាដើម្បីយល់ដឹងសំណុំរឿង ឬកំណត់ហេតុនៃការជំនុំជម្រះក្តី និងប្រឹក្សាជាមួយជនសង្ស័យ ដើម្បីបង្កើតយុទ្ធសាស្ត្រការពារក្តី។ នៅក្នុងកាលៈទេសៈបែបនេះ ការប៉ះពាល់ដល់ជនសង្ស័យ ជនរងគ្រោះ និងសាក្សី ព្រមទាំងកិច្ចការរដ្ឋបាលតុលាការ នឹងកើតមានឡើង។

១៣៦. ដោយផ្អែកលើអ្វីដែលបានលើកឡើងខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា សហមេធាវីដែលត្រូវបានចាត់តាំង មានទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាននៅក្នុងការតំណាងឱ្យជនសង្ស័យ ហើយទំនាស់នេះមិនអាចផ្សះផ្សាបានដោយសារកូនក្តីយល់ព្រមជាមួយការតំណាងនេះឡើយ។

---

[258] លទ្ធភាពដកការយល់ព្រមវិញ និងការពន្យារពេលកិច្ចដំណើរការនីតិវិធីដោយសារបញ្ហានេះគឺជាកត្តាមួយក្នុងចំណោមកត្តាផ្សេងៗដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានពិចារណានៅក្នុងការសម្រេចថាទំនាស់ផលប្រយោជន៍អាចប៉ះពាល់ជាអចិន្ត្រៃយ៍ដល់កិច្ចការរដ្ឋបាលតុលាការ *សូមមើល* ដីកាសម្រេចលើបណ្តឹងតវ៉ា កថាខណ្ឌ ១៥។

[259] ដីកាសម្រេច *Hadžihasanović* កថាខណ្ឌ ៤៤-៤៥ ដីកាសម្រេច *Mejakić* កថាខណ្ឌ ៧ និង ១៥ និងសេចក្តីសម្រេចបុរេជំនុំជម្រះ កថាខណ្ឌ ១៥។

## V. សុពលភាពនៃការលះបង់សិទ្ធិដែលដាក់ដោយសហមេធាវីដែលត្រូវបានចាត់តាំង

១៣៧. ដោយសម្រេចថា ទំនាស់ផលប្រយោជន៍នេះគឺជាទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សាបាន ទើបមិនចាំបាច់ពិនិត្យថាតើ ការលះបង់សិទ្ធិរបស់ជនសង្ស័យ និងអៀង សារី មានសុពលភាព ឬ អត់នោះទេ។ ទោះយ៉ាងណា ដោយពិចារណាទៅលើកង្វះខាតនៃវិធានជាធរមាន និងយុត្តិសាស្ត្រនៅ អ.វ.ត.ក ស្តីពីលក្ខខណ្ឌតម្រូវសម្រាប់ការលះបង់សិទ្ធិដែលមានសុពលភាព ទើប សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា ដើម្បីជាប្រយោជន៍យុត្តិធម៌ ត្រូវដោះស្រាយបញ្ហានេះដោយសង្ខេប។

១៣៨. ជាទូទៅ ការយល់ព្រមទទួលតំណាងផ្លូវច្បាប់របស់កូនក្តីណាម្នាក់ដែលអាចរងផលប៉ះពាល់ គប្បីត្រូវចាត់ទុកថាការយល់ព្រមដែលបានធ្វើឡើងដោយទទួលបានព័ត៌មានពេញលេញ ដោយគ្មានការបង្អាញផ្ទុយពីនេះឡើយ។ ទោះយ៉ាងណា គោលការណ៍នេះ ត្រូវតែមានតុល្យភាពជាមួយនឹងករណីយកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលត្រូវធានាឲ្យមានភាពយុត្តិធម៌ និងភាពសុចរិតនៃកិច្ចដំណើរការនីតិវិធី។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវតែជឿជាក់ថា ជនសង្ស័យ និងអៀង សារី បានដឹងអំពីបញ្ហាជាប់ពាក់ព័ន្ធទាំងអស់ដែលអាចកើតឡើងដោយសារសហមេធាវីដែលត្រូវបានចាត់តាំងធ្វើជាតំណាងឲ្យខ្លួនក្នុងពេលដំណាលគ្នា (ឬក្នុងពេលបន្តបន្ទាប់ក្រោយមកទៀត)[260]។

១៣៩. ការលះបង់សិទ្ធិដែលផ្តល់ដោយសហមេធាវីដែលត្រូវបានចាត់តាំង មិនមានភាពលម្អិតគ្រប់គ្រាន់ដើម្បីឲ្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជឿជាក់ថា បញ្ហាជាប់ពាក់ព័ន្ធទាំងអស់ដែលអាចកើតចេញពីទំនាស់នេះត្រូវបានពិភាក្សាគ្រប់ជ្រុងជ្រោយជាមួយកូនក្តី ហើយការយល់ព្រមរបស់ជនសង្ស័យ និងអៀង សារី ត្រូវបានធ្វើឡើងដោយទទួលបានព័ត៌មាន។

១៤០. ក្នុងន័យនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនយល់ស្របជាមួយនឹងទឡ្ហីករណ៍របស់សហមេធាវីដែលត្រូវបានចាត់តាំង ដែលថា ដើម្បីឲ្យឯកសារលះបង់សិទ្ធិកាន់តែលម្អិត ជនសង្ស័យនឹងត្រូវតែបង្ហាញយុទ្ធសាស្ត្រការពារក្តី បើមិនអញ្ចឹងទេ នឹងត្រូវតែបង្ហាញព័ត៌មានដែលប៉ះពាល់គាត់។ ការលើកឡើងនៅក្នុងការលះបង់សិទ្ធិអំពីដែនកំណត់ផ្សេងៗ ដែលទំនាស់ផលប្រយោជន៍នឹងមានទៅលើយុទ្ធសាស្ត្រការពារក្តីមួយចំនួន មិនមានន័យថាបង្ហាញពីយុទ្ធសាស្ត្រការពារក្តី ដែលកូនក្តីនឹងពិតជា

[260] ដីកាសម្រេចលើបណ្តឹងតវ៉ា *Prlić* កថាខណ្ឌ ២៧ និងដីកាសម្រេចលើបណ្តឹងតវ៉ា *Gotovina* កថាខណ្ឌ ៣២-៣៣។

សម្រេចប្រកាន់យកឡើយ។ ចំណុចនេះត្រូវបានគាំទ្រដោយយុត្តិសាស្ត្ររឿងក្តីអន្តរជាតិ ដែលតម្រូវឲ្យការលះបង់សិទ្ធិ មានការពិភាក្សាអំពីបញ្ហាជាប់ពាក់ព័ន្ធ និងដែនកំណត់ទាំងអស់ដែលទំនាស់ផលប្រយោជន៍អាចមានទៅលើយុទ្ធសាស្ត្រការពារក្តីជនសង្ស័យ[261]។

១៤១. នៅក្នុងករណីដែលទំនាស់ផលប្រយោជន៍អាចលះបង់បាន កម្រិតនៃភាពលម្អិតនៃការលះបង់សិទ្ធិ អាចមានបញ្ហាជាប់ពាក់ព័ន្ធសំខាន់ៗ។ នៅពេលដែលការលះបង់សិទ្ធិ មិនមានភាពលម្អិតគ្រប់គ្រាន់ ជនដែលត្រូវបានផ្តន្ទាទោស អាចតវ៉ាថា ខ្លួនមិនបានយល់ទាំងស្រុងអំពីបញ្ហាជាប់ពាក់ព័ន្ធទាំងអស់នៃទំនាស់ផលប្រយោជន៍ដែលបានលះបង់ ហើយអាចប្តឹងតវ៉ាប្រឆាំងនឹងការផ្តន្ទាទោសគាត់ ដោយផ្អែកលើមូលដ្ឋានថាមានជំនួយគាំទ្រគ្មានប្រសិទ្ធភាពពីមេធាវីការពារក្តី[262]។

## ច. សេចក្តីសន្និដ្ឋាន

១៤២. ដោយផ្អែកលើទំនាក់ទំនងអង្គហេតុយ៉ាងជិតស្និទ្ធដែលមានរវាងរឿងក្តីប្រឆាំងនឹងជនសង្ស័យ និងអៀង សារី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា បញ្ហាដែលសហមេធាវីដែលត្រូវបានចាត់តាំងតំណាងឲ្យជនសង្ស័យ គឺជាប់ពាក់ព័ន្ធយ៉ាងសំខាន់ជាមួយនឹងបញ្ហាដែលសហមេធាវីដែលត្រូវបានចាត់តាំងតំណាងឲ្យ អៀង សារី។ ក៏មានការបង្ហាញឃើញអំពីទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោមយ៉ាងជិតស្និទ្ធរវាងអ្នកទាំងពីរផងដែរ។ ទោះជាក្រោយមរណភាពរបស់អៀង សារី ក៏ដោយ ក៏សហមេធាវីដែលត្រូវបានចាត់តាំង នៅមានករណីយកិច្ចរក្សាភាពស្មោះត្រង់ជាមួយគាត់ រួមមានការការពារសេចក្តីថ្លៃថ្នូរ និងកេរ្តិ៍ឈ្មោះរបស់គាត់។ ដោយសារករណីយកិច្ចនេះ ទើបអាចព្យាករណ៍ជាមុនដោយ

---

[261] *ដូចជើងទំព័រខាងលើ*។

[262] តម្រូវការឲ្យ ជំនួយពីមេធាវី ត្រូវមាន"ប្រសិទ្ធភាព" ត្រូវបានបញ្ជាក់ដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប នៅក្នុងរឿងក្តី *Arctico តទល់នឹងអ៊ីតាលី* សំណុំរឿងលេខ 6694/74 ថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៨០ កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* រឿងក្តី *Poitrimol តទល់នឹងបារាំង* សំណុំរឿងលេខ 14032/88 ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ កថាខណ្ឌ ៣៤ និង ៣៨។ យោងតាមអង្គជំនុំជម្រះសាលាដំបូងនៃតុលាការICTY ជំនួយគ្មានប្រសិទ្ធភាពពីមេធាវីដែលបានបង្កឲ្យមានយុត្តិនិសេធ អាចជាមូលដ្ឋាននៃការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការផ្តន្ទាទោស *សូមមើល* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Krajišnik* ឯកសារ IT-00-39-A សាលដីកា លើបណ្តឹងឧទ្ធរណ៍ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៩ កថាខណ្ឌ ៤២។

សមហេតុផលថា ទំនាស់ផលប្រយោជន៍អាចកើតឡើង ហើយសហមេធាវីដែលត្រូវបានចាត់តាំងអាចស្ថិតនៅក្នុងតួនាទីមួយដែលមិនអាចផ្តល់យោបល់ប្រឹក្សាដល់ជនសង្ស័យ និងមិនអាចស្វែងរកវិធីការពារក្តីខណៈដែលអាចមានប្រយោជន៍ដល់ជនសង្ស័យ ប៉ុន្តែអាចឆ្លើយដាក់ អៀង សារី ឱ្យជាប់ពាក់ព័ន្ធជាមួយនឹងឧក្រិដ្ឋកម្មដែលបានចោទនៅក្នុងសំណុំរឿង ០០៣ ។ បញ្ហាជាប់ពាក់ព័ន្ធនៃទំនាស់ផលប្រយោជន៍នេះដែលអាចព្យាករណ៍ជាមុនថានឹងកើតឡើងនៅក្នុងសំណុំរឿង ០០៣ គឺជាបញ្ហាជាប់ពាក់ព័ន្ធដែលអាចប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនសង្ស័យក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងកិច្ចការរដ្ឋបាលតុលាការ។ ដោយសារមូលហេតុទាំងនេះ ទើបសហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា ទំនាស់ផលប្រយោជន៍ទាំងនេះមិនអាចផ្សះផ្សាបាន ហើយមិនអាចលះបង់បានឡើយ។

**តាមសំអាងហេតុដូចបានលើកឡើងខាងលើ ខ្ញុំ MARK B. HARMON** ៖

១៤៣. **សម្រេច**ថា សំណើសុំបដិសេធ ត្រូវទទួលយក។

១៤៤. **អនុញ្ញាត**តាមសំណើសុំបន្ថែមចំនួនទំព័រ និងដាក់ឯកសារជាភាសាអង់គ្លេសមុន ហើយដាក់ឯកសារជាភាសាខ្មែរនៅតាមក្រោយ។

១៤៥. **អនុញ្ញាត**តាមសំណើសុំបដិសេធ។

១៤៦. **ស្នើ** អង្គភាពគាំពារការពារក្តី ចាត់វិធានការចាំបាច់ ដើម្បីចាត់តាំងសហមេធាវីថ្មី ឱ្យជនសង្ស័យ ឱ្យបានឆាប់រហ័សតាមការជាក់ស្តែង។

ភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

**ចៅក្រម Mark B. Harmon**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co-Investigating Judge**